ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 19-Dec-2011, 08:45
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១**

**ម៉ោង ០៩: ០១នាទី**

**សវនាការលើកទី១១**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

កញ្ញា ណាតាចា វ៉ិស៊ែល រីស៊ឺ
*(Ms. Natacha WEXELS-RISER)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក វីល្លៀម ស្មីត *(Mr.William Smith)*

លោក ឌេល លីសាក់ *(Mr. Dale LYSAK)*

លោក សេង ប៊ុនឃាង

លោក ច័ន្ទ តារាស្មី

លោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន

*(Mr. Michiel PESTMAN)*

លោក អេនឌ្រូ អ៊ីនូហ្ស៊ី

*(Mr. Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកធួរ វ៉ែកគែន

*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ហុង គឹមសួន

លោក សំ សុគង់

លោក ឡោ ជុនធី

លោក វ៉េន ពៅ

កញ្ញា ម៉ុច សុវណ្ណារី

លោកស្រី គ្រីស្ទីន ម៉ាទីណូ

*(Ms. Chritine MARTINAU)*

លោក អូលីវីយេ៉ បាហ៊ូញ

*(Mr. Olivior BAHOUGNE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

**មន្ត្រីអង្គភាពគាំពារសាក្សី/អ្នកជំនាញ៖**

លោក ញ៉ែម សំណាង

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍ | អង់គ្លេស |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក អេនឌ្រូ អ៊ីនូហ្វ៊ី | អង់គ្លេស |
| លោក អាកទួរ វែកគែន | បារាំង |
| លោក នួន ជា | ខ្មែរ |

# ខ្លឹមសង្ខេប

**ការសួរសំណួរទៅសាក្សី ឡុង នរិន្ទ** (TCW-395) (តាមប្រព័ន្ធសោតទស្សន៍)

ស្ួរដោយលោក ម៉ៃខល ផេសមិន ផ្តើមពី .................................................. ទំព័រ ០១

សួរដោយលោក ម៉ៃខល កាណាវាស ផ្តើមពី .................................................. ទំព័រ ០៩

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី .................................................. ទំព័រ ២៣

**ការសួរសំណួរទៅជនជាប់ចោទ នួន ជា**

សួរដោយលោក ឌេល លីសាក់ ផ្តើមពី .................................................. ទំព័រ ៣០

# កិច្ចដំណើរការនីតិវិធី

[០៩:០១:២៥]

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

តាមផែនការដែលបានគ្រោងទុកនៅព្រឹកនេះ អង្គជំនុំជម្រះបន្តស្ដាប់សក្ខីកម្មសាក្សី ឡុង នរិន្ទ តាមមធ្យោបាយសោតទស្សន៍ពីកន្លែងដែលគាត់រស់នៅមកជាមួយនឹងអង្គជំនុំជម្រះ។ ហើយកាលពីម្សិលមិញ គឺយើងបានដំណើរការដល់មេធាវីការពារក្ដី នួន ជា ហើយមេធាវីការពារក្ដី នួន ជា នៅពេលវេលាខ្លះទៀត នៅដប់មីនុតទៀតក្នុងការសួរសំណួរទៅកាន់សាក្សីរូបនេះ។

សួស្ដីលោក ឡុង នរិន្ទ។

**លោក ឡុង នរិន្ទ៖**

ជម្រាបសួរ។

**ប្រធានអង្គជំនុំ៖**

លោក ឡុង នរិន្ទ នៅថ្ងៃនេះយើងបន្តនូវការស្ដាប់សក្ខីកម្មរបស់លោកតទៅទៀត ហើយប្រសិនបើយើងប្រព្រឹត្តទៅបានល្អនោះទំនងជា មួយព្រឹកនេះយើងនឹងអាចចប់ហើយ។ ហើយជាបន្តទៅនេះ សូមប្រគល់វេទិកាទៅមេធាវីអន្តរជាតិការពារក្ដីឲ្យលោក នួន ជា ដើម្បីបន្តសំណួរចំពោះសាក្សីរូបនេះ ហើយលោកមានពេលដប់នាទីទៀតតែប៉ុណ្ណោះ។ បាទ, សូមអញ្ជើញ!

[០៩:០៣:២០]

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក ម៉ៃខល ផេសមិន៖**

ជម្រាបសួរ! ខ្ញុំមេធាវីការពារក្ដី ខ្ញុំមើលសាក្សីអត់ឃើញ។

ជម្រាបសួរលោក ឡុង នរិន្ទ។ កាលពីរសៀលម្សិលមិញនោះ ខ្ញុំបានសាកសួរសំណួរខ្លះអំពីកិច្ចប្រជុំដែលប្រារព្ធធ្វើឡើងនៅប-១ ដែលអៀង សារី គាត់បានប្រាប់សហការីរបស់លោកថា គាត់នឹងមិនអនុញ្ញាតឲ្យមានការចាប់ខ្លួនទេនៅពេលដែលគាត់មិននៅ។

**ស៖** ហើយសំណួរខ្ញុំពីម្សិលមិញនេះ គឺខ្ញុំសួរថា តើអ្នកណាបានប្រាប់លោកនៅក្នុងកិច្ចប្រជុំនោះ?

**លោក ញ៉ែម សំណាង៖**

អ៊ឺយល់សំណួរទេអ៊ំ?

លោក អៀង សារី បាននិយាយថាអត់មានឲ្យអ្នកណានាំមនុស្សចេញពីប-១ ហ្នឹងទេបើគាត់មិននៅ។ ហើយសំណួរសួរថា តើអ្នកណាប្រាប់អ៊ំអ៊ីចឹង?

**លោក ឡុង នរិន្ទ៖**

**ឆ៖** អត់ទេ។ ជាចំហក្នុងការប្រជុំ។

**ស៖** សំណួរខ្ញុំសួរថា អ្នកណាជាអ្នកប្រាប់លោកកិច្ចប្រជុំ ដោយសារថាលោកមិនបានចូលរួមប្រជុំនៅក្នុងអង្គប្រជុំនោះទេ។ អ្នកណាប្រាប់លោកថាមិនឲ្យចាប់ខ្លួន លោក អៀង សារី ថាមិនឲ្យចាប់ខ្លួនទេ បើសិនណាជាគាត់អវត្តមានក៏ដោយ?

**ឆ៖** មិនបាននិយាយថា ចាប់ខ្លួនអ៊ីចឹងទេ គ្រាន់តែនិយាយថា កុំឲ្យអ្នកណាចូល មិនឲ្យអ្នកណាមកយកបុគ្គលិកទៅណាហ្នឹង អត់បានទេ អត់។

**លោក ញ៉ែម សំណាង៖**

សំណួរចង់សួរអ៊ំថា តើអ្នកណាប្រាប់អ៊ំអ៊ីចឹង?

**លោក ឡុង នរិន្ទ៖**

**ឆ៖** អាហ្នឹង គាត់និយាយក្នុងពេលប្រជុំក្រសួង ដល់អ៊ីចឹងទៅខ្ញុំស្ដាប់តាមហ្នឹង។

**ស៖** នៅក្នុងឆ្នាំ២០០៧ លោកជម្រាបជូនសហចៅក្រមស៊ើបអង្កេតថា លោកមិនបានចូលរួមប្រជុំនោះទេ ហើយនៅក្នុងកំណត់នោះ គឺថាលោក គាត ឈន់ ជាអ្នកប្រាប់លោក តើវាដូច្នោះមែនទេ?

[០៩:០៦:១៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ ដោយសារថា សហមេធាវីការពារក្ដីបានបង្ហាញនូវសេចក្ដីថ្លែងមួយ គឺថាសួរនូវសំណួរមិនត្រឹមត្រូវ។ សូមអភ័យទោសលោកប្រធាន ការជំទាស់នោះគឺថា

លោកមេធាវីការពារក្តីបានលើកឡើងមិនត្រឹមត្រូវទេនូវអ្វីដែលលោក ផេសមិន បានសួរនូវចម្លើយសំណួរនេះ។ គាត់គួរណាស់តែសួរ អាននូវកំណត់ហេតុស្តាប់ចម្លើយនេះជាមុនសិន មុននឹងសាកសួរមកសំណួរនេះ។ យើងគ្រាន់តែចង់ឲ្យសួរថា នៅពេលមេធាវីការពារក្តីលើកឡើងនូវកំណត់ស្តាប់ចម្លើយមុនៗគឺថាគាត់គួរអានកំណត់ហេតុស្តាប់ចម្លើយនោះជាមុនឲ្យបានច្បាស់លាស់។

[០៩:០៧:២៧]

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** លោក ឡុង នរិន្ទ នៅក្នុងឆ្នាំ២០០៧ លោកបានជម្រាបជូនសហចៅក្រមស៊ើបអង្កេតដោយលោកបានលើកឡើងពីឈ្មោះលោក គាត ឈន់ នេះ ចំនួនប្រាំដង។ លោកចាំទេ កាលពីសប្តាហ៍មុន? ប៉ុន្តែពីម្សិលមិញនេះ គឺថាលោកអត់បានលើកឡើងពីឈ្មោះលោក គាត ឈន់ នេះម្តងណាសោះ។ តើលោកមានអារម្មណ៍ថា មិនមានសម្ពាធអីមួយដើម្បីលើកឡើងពីឈ្មោះគាត់ ឬនិយាយអំពីសក្ខីកម្មនេះទេ?

[០៩:០៨:០៥]

**លោក ញ៉ែម សំណាង៖**

អ៊ំយល់ទេអ៊ំ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** ស្តាប់អត់ទាន់។ គាត់សួរម៉េច? ថាម៉េច?

**លោក ញ៉ែម សំណាង៖**

សួរថា អង្គាល់ពីអ៊ំឆ្លើយទៅនឹងសហចៅក្រមស៊ើបអង្កេត ពីឆ្នាំ២០០៧ហ្នឹង គឺអ៊ំបានលើកនិយាយពីឈ្មោះលោក គាត ឈន់ ហ្នឹង ចំនួនប្រាំដង តែពីម្សិលមិញនេះ អ៊ំអត់បានលើកនិយាយអំពីឈ្មោះលោក គាត ឈន់ ទេ ថាតើក្នុងការផ្តល់សក្ខីកម្មនោះ អ៊ំមានសម្ពាធអ្វីពីខាងក្រៅទេអ៊ំ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** អត់ទេ អត់មានទេ។

**ស៖** តើមានអ្នកណាមកជួបលោកទេ ក្រោយឆ្នាំ២០០៧ មកជួបលោក សាកសួរលោកពាក់ព័ន្ធទៅនឹងសក្ខីកម្មដែលលោកបានផ្តល់ជូនតុលាការនោះ?

**ឆ៖** អត់មានទេ។

[០៩:០៩:១០]

**ស៖** តើលោក គាត ឈន់ គាត់មាន-- គាត ឈន់ គាត់មានតួនាទីបច្ចុប្បន្នជាអ្វីដែរ នៅក្នុងរដ្ឋាភិបាល?

**ឆ៖** គាត់សួរខ្ញុំ?

**លោក ញ៉ែម សំណាង៖**

បាទៗ។

**លោក ឡុង នរិន្ទ៖**

**ឆ៖** អត់ទេ ខ្ញុំអត់ដឹងទេ។ ដឹងគាត់ធ្វើទេ ឥឡូវហ្នឹង។ ហើយក៏មិនដែលបានជួបគ្នាផង ពីមុនកាលទៅណា ខ្ញុំក៏ទៅជាមួយគាត់ដែរ ដែលទៅអង្គការសហប្រជាជាតិ។

**ស៖** លោកមិនដឹងថា គាត់គឺជារដ្ឋមន្ត្រីក្រសួងហរិញ្ញវត្ថុ និងជាឧបនាយករដ្ឋមន្ត្រីនៅក្នុងរាជរដ្ឋាភិបាលកម្ពុជាសព្វថ្ងៃនេះទេឬ?

**ឆ៖** ខ្ញុំអត់ដឹងទេបាទ។

**ស៖** ហើយលោកមានជ្រាបទេ ថាហេតុអ្វីបានជាលោក គាត ឈន់ បដិសេធមិនចូលខ្លួនមកផ្តល់សក្ខីកម្មនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត?

**ប្រធានអង្គជំនុំ៖**

សំណួរនេះក្រៅអង្គហេតុ ហើយសាក្សីមិនបាច់ឆ្លើយទេ។ ហើយមេធាវីពេលវេលាលោកជិតអស់ហើយ ហើយលោកគួរតែត្រូវបានប្រើប្រាស់ពេលវេលាឲ្យមានប្រសិទ្ធភាពនៅក្នុងការសួរដេញដោល។ អង្គជំនុំជម្រះបានជម្រាបតាំងពីដើមមកអំពីលក្ខខណ្ឌនានានៃការដេញដោល មិនគប្បីសួរដេញដោលនូវបញ្ហាក្រៅអង្គហេតុ។ លោកអាចតសំណួរផ្សេងទៀតបាន ប៉ុន្តែចៀសវាងនូវសំណួរក្រៅអង្គហេតុ មិនពាក់ព័ន្ធសំណួរច្រំដែល សំណួរដឹកមុខ សំណួរឧបមាវិធី ឬក៏សំណួរនាំឲ្យសាក្សីធ្វើសេចក្តីសន្និដ្ឋាន។

[០៩:១១:២៧]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន ខ្ញុំមិនមានសំណួរអ្វីបន្ថែមទៀតទេ។

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណ។ ជាកិច្ចបន្តនេះអង្គជំនុំជម្រះសូមប្រគល់វេទិកាជូនទៅសហមេធាវីការពារក្តីឱ្យលោក អៀង សារី ហើយមុនសួរថា អង្គជំនុំជម្រះមុននឹងផ្តល់វេទិកាថា តើក្រុមមេធាវីការពារក្តីក្រុមអៀង សារី ហ្នឹងត្រូវការពេលវេលាប៉ុន្មានក្នុងការសួរដេញដោលសាក្សីរូបនេះ?

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម សូមគោរពអង្គសវនាការ។ ដូចយើងខ្ញុំបានជម្រាប ប្រហែលជាខាងដើមយើងប្រើនាទីប្រហែលជា ១៥នាទី ទៅ៤៥នាទីប៉ុណ្ណឹង។ យើងប៉ាន់ប្រមាណឃើញប៉ុណ្ណឹង ហើយយើងព្យាយាមបង្រួញសំណួររបស់យើងឱ្យខ្លី តាមដែលអាចធ្វើទៅបាន។

[០៩:១២:៤១]

**ប្រធានអង្គជំនុំ៖**

បាទសូមអញ្ជើញលោកមេធាវីចាប់ផ្តើមសួរសំណួរ!

**លោក អាង ឧត្តម៖**

សូមធ្វើការកត់សម្គាល់មួយចំនួន យើងខ្ញុំបានស្តាប់ខ្សែអាត់ថតសំឡេងនៃបទសម្ភាសន៍លោកឡុង នរិន្ទ ជាមួយនឹងបុគ្គលិករបស់សហចៅក្រមស៊ើបអង្កេត និងដោយយោងទៅលើកាតព្វកិច្ចវិរភាពរបស់យើងខ្ញុំ គឺការដែលត្រូវបំពេញឱ្យត្រឹមត្រូវ ឱ្យពេញលេញ និងឱ្យអស់ពីលទ្ធភាព។ យើងខ្ញុំបានពិនិត្យ ផ្ទៀងផ្ទាត់ទៅនឹងប្រតិចារឹកជាលាយលក្ខណ៍អក្សរនៃកិច្ចសម្ភាសន៍នេះសម្រាប់ជាឯកសារយោងដល់អង្គជំនុំជម្រះ និងដល់ភាគី។ គឺឯកសារ D91/3.1 យើងខ្ញុំកត់សម្គាល់ឃើញថា ប្រតិចារឹកទើបតែផ្តល់ជូនមកយើងខ្ញុំនាពេលថ្មីៗនេះប៉ុណ្ណោះ ហើយមិនបានបកប្រែជាភាសាអង់គ្លេស ឬជាភាសាបារាំងទេ។ យើងខ្ញុំបានធ្វើការនេះ គឺដើម្បីប្រៀបធៀបប្រតិចារឹកទាំងមូលនៃកិច្ចសម្ភាសន៍នេះ ទៅនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សីនោះ គឺឯកសារ 91/3 ដែលជាសេចក្តីសង្ខេបនេះកិច្ចសម្ភាសន៍របស់លោកឡុង នរិន្ទ បានធ្វើឡើងជាមួយនឹងការិល័យសហចៅក្រមស៊ើបអង្កេត ហើយដែលការិយាល័យសហព្រះរាជអាជ្ញាបានយោងជាសំអាងនៅក្នុងការសាកសួរសាមីសាក្សីរបស់ខ្លួន ដែលភាសាអង់គ្លេសគេហៅថា *ដាយរិច អ៊ិចសាមីណេសិន*។ យើងខ្ញុំបានពិនិត្យផ្ទៀតផ្ទាត់លើខ្សែអាត់ថតសំឡេង និងប្រតិចារឹកនោះដើម្បីសម្គាល់រកមើលភាពមិនសមស្របគ្នាទៅនឹងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហើយនិង

ដើម្បីសម្គាល់រកមើលចំណុចដោះបន្ទុក ដែលមិនមាននៅក្នុងកំណត់ហេតុស្ដាប់ចម្លើយសាក្សីនោះ។ យើងខ្ញុំកត់សម្គាល់-- យើងខ្ញុំចង់ទាញចំណាប់អារម្មណ៍របស់តុលាការទៅលើព័ត៌មានដូចតទៅនេះ៖

កំណត់ហេតុស្ដាប់ចម្លើយសាក្សីនោះ មិនត្រឹមត្រូវទាំងស្រុងឡើយ។ នៅពេលពិនិត្យសាចុះសាឡើងនៅប្រតិចារឹកនៃកិច្ចសម្ភាសន៍របស់លោក ឡុង នរិន្ទ ដែលត្រូវបានធ្វើជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត។ ប៉ុន្តែកំហុសឆ្គងទាំងនេះមិនសូវមានសារៈសំខាន់ជាសារវន្តដែលតម្រូវឲ្យយើងខ្ញុំទាញចំណាប់អារម្មណ៍របស់អង្គជំនុំជម្រះ នាពេលនេះឡើយ។

[០៩:១៦:៣៩]

អ្វីដែលគួរឲ្យបារម្ភខ្លាំងបំផុតសម្រាប់ខ្សែអាត់ថតសំឡេង និងប្រតិចារឹកនោះគឺថា អ្នកបកប្រែភាសាក្រៅតែធ្វើការបកប្រែភាសាក៏បានសួរសំណួរ និងឆ្លើយសំណួរផ្សេងៗទៅកាន់សាក្សី ហើយពេលខ្លះថែមទាំងបានអានឲ្យអ្នកប្រតិចារឹកកត់ត្រាតាមផង។ ការនេះមាននៅស្ទើរគ្រប់ទំព័រនៃប្រតិចារឹកដែលមានកម្រាស់ ៩៨ទំព័រ។ ហើយតាមការពិចារណារបស់យើងខ្ញុំ គឺថាវាមិនសមរម្យនិងមិនលក្ខណៈវិជ្ជាជីវៈទាល់តែសោះ។

ឧទាហរណ៍ នៅទំព័រ៧ នៃឯកសារ D91/3 មានប្រាំបីលើកដែលអ្នកបកប្រែចូលរួមនៅក្នុងកិច្ចពិភាក្សា។ ហើយនៅទំព័រ៨ មានពីរលើក នៅទំព័រ៩ មានបួនលើក នៅទំព័រ១០ មានប្រាំមួយលើក នៅទំព័រ១១ មានបួនលើក និងទំព័រ១២មានប្រាំលើក។ល។

[០៩:១៨:២២]

ឧទាហរណ៍បន្ថែមមួយទៀត ដែលបានមកពីប្រតិចារឹក ដែលគូសបញ្ជាក់អំពីកង្វល់ដែលយើងខ្ញុំបានលើកឡើងពីមុនមក គឺមាននៅក្នុងទំព័រ៩៤ នៃប្រតិចារឹក។ ខ្ញុំសូមអានឧទាហរណ៍នេះ តែមួយគត់ដើម្បីឆ្លុះបញ្ចាំង។ ខ្ញុំចាប់ផ្ដើមពីទំព័រ៩២ "អ្នកបកប្រែ៖ លោកគ្រូ-- អ្នកបកប្រែសួរ៖ លោកគ្រូដែលអញ្ជើញទៅទេ ប-៣០ នោះណា?" ហើយលោក នរិន្ទ ឆ្លើយ៖ "ប-៣០ ខ្ញុំមិនដឹងនៅត្រង់ណាផង"។ អ្នកបកប្រែសួរ៖ "ចុះ ប-៣១, ប-៣២?" ទំព័រ៩៣ លោក នរិន្ទ ឆ្លើយ៖ "ប-៣១, ប-៣២ ហ្នឹងក៏អត់ដឹង មិនដឹងនៅត្រង់ណាទេ"។ អ្នកបកប្រែសួរ៖ "ដែលឮសូរគេនិយាយ ប-៣០, ៣១, ៣២ ទេ?" ឃ្លាចុងក្រោយនៃទំព័រ៩៣ អ្នកស៊ើបអង្កេតបញ្ជាក់៖ ហោ ណាំហុង ប-៣២។ ទំព័រ៩៤ អ្នកស៊ើបអង្កេតសួរ៖ លោកគ្រូអត់ដឹង? លោក នរិន្ទ ឆ្លើយ៖ ហោ ណាំហុង។ អ្នកបកប្រែបញ្ជាក់៖ ហោ ណាំហុង ទទួលខុសត្រូវ ប-៣២ កាលនុំង។ លោក នរិន្ទ ឆ្លើយ៖ មិនមែន ហោ ណាំហុង នៅនេះទេ

នៅបឹងត្របែកទេ? ទេ ដូចបឹងត្របែក ហោ ណាំហុង ដូចទទួលខុសត្រូវបឹងត្របែក។ អ្នកស៊ើបអង្កេតសួរ និងសម្រេច ប-៣០ ឈ្មោះអី? ហេង អ៊ុន មិនបាច់ដាក់ទេ គាត់អត់ដឹងដែរ”។

នេះជាឧទាហរណ៍តូចមួយដែលយើងបានដកស្រង់ប៉ុណ្ណោះ។ តាមពិត ការធ្វើបែបនេះនាំឱ្យចោទជាបញ្ហាអំពីរបៀប បែបបទរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលបានបំពេញកិច្ចស៊ើបសួររបស់ខ្លួននៅក្នុងសំណុំរឿង០០២។

[០៩:២១:៥៦]

ហើយតាមការផ្ទុះបញ្ហាំងនេះ វាផ្តល់ជំនឿថែមទៀតដល់សំណើសុំបំពេញកិច្ចស៊ើបសួរលើកទីបីរបស់យើង និងញត្តិរបស់យើងខ្ញុំដែលបាននៅចំពោះមុខអង្គជំនុំជម្រះនេះ ដែលស្នើសុំឱ្យមានសវនាការដេញដោលផ្ទាល់មាត់ទៅលើការបំពេញកិច្ចស៊ើបសួរតាមផ្លូវតុលាការនេះ។ ហើយវាក៏គាំទ្រដល់សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ និងញត្តិរបស់យើងខ្ញុំនេះផងដែរ។

ដើម្បីភាពងាយស្រួលដល់អង្គជំនុំជម្រះ និងជាព័ត៌មានបន្ថែមទាក់ទងទៅនឹងកង្វល់ ក្តីបារម្ភរបស់យើងខ្ញុំ និងថាតើបញ្ហាទាំងនេះប៉ះពាល់យ៉ាងដូចម្តេច? យ៉ាងណាខ្លះដល់សិទ្ធិជាចម្បងរបស់លោក អៀង សារី ក្នុងការទទួលបានកិច្ចជំនុំជម្រះដោយយុត្តិធម៌។ យើងខ្ញុំសូមយោងអង្គជំនុំជម្រះទៅលើសំណើរបស់លោក អៀង សារី សុំឱ្យបំពេញកិច្ចស៊ើបសួរលើកទីបី។ គឺឯកសារ D--។

[០៩:២៣:៣១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនជំទាស់អ្វីទេចំពោះអ្វីដែលលោកមេធាវីការពារក្តីចង់សួរទៅសាក្សី។ ប៉ុន្តែពេលនេះមិនមែនទាន់ជាពេលមួយដែលត្រូវបង្ហាញនូវអារម្មណ៍ណាមួយ ឬក៏សួរនូវលើកឡើងនូវចំណុចបែបនេះទេ ដោយសារថាយើងមានប្រតិចារឹកពេញលេញរួចទៅហើយ។ ហើយខ្ញុំសូមឱ្យមេធាវីការពារក្តីត្រឡប់ទៅសួរសំណួរគាត់ផ្ទាល់ៗតែម្តងទៅ។

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណសហព្រះរាជអាជ្ញា ដែលបានធ្វើការកត់សម្គាល់ដូច្នេះ។ អីចឹងបញ្ហានេះអង្គជំនុំជម្រះសួរទៅលោកមេធាវីការពារក្តីលោក អៀង សារី តើមានសំណួរអ្វីសួរដល់សាក្សីរូបនេះ ដែលឬ

ទេ? បើមិនមានសំណួរទេ គឺអង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកធ្វើការថ្លែងរបស់របៀបនេះតទៀតទេ។ ហើយទុកការជជែកពិភាក្សាបញ្ហាអង្គច្បាប់នេះនៅពេលក្រោយ ដោយពេលវេលាគឺមិនអំណោយផលដល់សាក្សីរូបនេះនៅក្នុងការផ្តល់សក្ខីកម្មនោះឡើយ។ ប្រសិនបើលោកមិនមានសំណួរទេ គឺឲ្យច្បាស់លាស់ យើងនឹងប្រគល់វេទិកានេះទៅឲ្យមេធាវីក្រុមផ្សេងទៀត។

[០៩:២៤:៥២]

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន! ក៏ប៉ុន្តែដោយសារសំណួររបស់យើងវាទាក់ទងទៅលើឯកសារចំនួនបីដែលមិនស៊ីសង្វាក់គ្នា។ យើងខ្ញុំគ្រាន់តែចង់ទាញចំណាប់អារម្មណ៍ទៅលើភាពមិនស៊ីសង្វាក់គ្នានៃឯកសារបី។ ទីមួយ គឺកំណត់ហេតុសួរចម្លើយរបស់លោក អៀង សារី ដែលធ្វើជាមួយនឹងសហចៅក្រមស៊ើបអង្កេត។ ទីពីរ ប្រតិចារឹកជាលាយលក្ខណ៍អក្សរ។ ទីបី ខ្សែអាត់សំឡេងនៃកិច្ចសម្ភាសន៍ទាំងមូល វាមិនស៊ីសង្វាក់គ្នា។ ពីព្រោះការសួរចម្លើយវាយោងទៅលើឯកសារទាំងបីនេះ។ យើងខ្ញុំគ្រាន់តែចង់បង្ហាញថា ឯកសារទាំងបីរនេះ មិនស៊ីសង្វាក់ មិនឆ្លើយគ្នា និងមិនត្រឹមត្រូវប៉ុណ្ណោះ ដែលយើងខ្ញុំសូមទាញចំណាប់អារម្មណ៍តែប៉ុណ្ណឹង។ រីឯសំណួរ ខ្ញុំនិងសហភាតារបស់ខ្ញុំនឹងបន្ត បន្ទាប់ពីខ្ញុំធ្វើកំណត់សម្គាល់នេះចប់។ បើមិនអនុញ្ញាតឲ្យខ្ញុំថ្លែងបញ្ជាក់ពីភាពចម្រូងចម្រាសនៃឯកសារទាំងបីនេះដែលជាមូលដ្ឋាននៃការសួរចម្លើយទេ ខ្ញុំ-- យើងខ្ញុំយល់ថា នឹងមានភាពខ្វះចន្លោះហើយ--

[០៩:២៦:២៤]

**ប្រធានអង្គជំនុំ៖**

មិនអនុញ្ញាតទេ។ ឥឡូវសូមតាំងសំណួរ បើលោកអត់តាំងសំណួរទេ យើងប្រគល់វេទិកាទៅឲ្យមេធាវីផ្សេងទៀត។

**លោក អាង ឧត្តម៖**

ខ្ញុំសូមអនុញ្ញាតឲ្យសហភាតាខ្ញុំបន្ត។

**លោក ម៉ៃខល កាណាវាស៖**

សូមគោរពលោកប្រធាន! សូមគោរពលោក លោកស្រីចៅក្រម សូមគោរពលោក ឡុង នរិន្ទ។ ខ្ញុំមិនចង់លើកឡើងនូវបញ្ហាដែលសហភាតារបស់ខ្ញុំលើកឡើង គឺថាយើងបានយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញា ថាអ្វីៗទាំងអស់ត្រូវតែបកប្រែឲ្យទៅជាភាសាផ្លូវការទាំងបីរបស់តុលាការ។ ហើយយើង

មានកំណត់ហេតុសង្ខេបបានមកពីការិយាល័យសហព្រះរាជអាជ្ញា ពាក់ព័ន្ធទៅនឹងព័ត៌មានដែលយើងត្រូវសាកសួរ។

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** លោក ឡុង នរិន្ទ ទីមួយខ្ញុំសូមបង្ហាញណែនាំលោកឲ្យស្គាល់ខ្ញុំ។ ខ្ញុំឈ្មោះ ម៉ែខល កាណាវាស។ ខ្ញុំជាមេធាវីការពារក្តីរួមគ្នាជាមួយនឹងលោក អាង ឧត្តម គឺការពារលោក អៀង សារី។ ក្រោយពីលោកបានផ្តល់កិច្ចសម្ភាសន៍មក អស់រយៈពេលពីរថ្ងៃនេះ ក្នុងពីរថ្ងៃនោះគឺថា តើសហព្រះរាជអាជ្ញាមានផ្តល់-- សូមទោស តើសហចៅក្រមស៊ើបអង្កេតមានផ្តល់ឱកាសឲ្យលោកពិនិត្យមើលចម្លើយនេះ ឬក៏អាននូវប្រតិចារឹក ហើយនៅក្នុងពេលដើម្បីកែតម្រូវអ្វីដែលលោកបានផ្តល់ជាចម្លើយនៅក្នុងពេលសម្ភាសន៍នោះ?

**លោក ញ៉ែម សំណាង៖**

យល់ទេអ៊ំ? យល់សំណួរគេសួរទេ? ឮទេ?

[០៩:២៨:៣០]

**លោក ឡុង នរិន្ទ៖**

**ឆ៖** អត់។ សួរខ្ញុំអំមិញ? តើគេសួរថាម៉េច ខ្ញុំអត់ដឹង អត់បាន--

**លោក ញ៉ែម សំណាង៖**

សួរថា --

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** ខ្ញុំសូមសួរសំណួររបស់ខ្ញុំម្តងទៀត លោកត្រូវបានផ្តល់ការសម្ភាសន៍ពីរថ្ងៃ មួយថ្ងៃគឺមានរយៈពេលប្រាំបីម៉ោង ហើយក្រោយមកទៀត លោកបានផ្តល់ការសម្ភាសន៍រយៈពេល៤៥នាទី ថ្ងៃបន្ទាប់។ បន្ទាប់ពីការសម្ភាសន៍ទាំងពីរថ្ងៃនេះមក តើលោកមានបានទទួលឱកាសដើម្បីអាន ឬក៏ពិនិត្យនូវប្រតិចារឹក-- នូវកំណត់ហេតុនេះឡើងវិញទេ?

**ឆ៖** អត់ទេ អត់បាន។ ឈប់សម្រាក ពីព្រោះវា--

**ស៖** មុននឹងផ្តល់សក្ខីកម្មនៅក្នុងសក្ខីកម្មនៅក្នុងសវនាការនេះ តើលោកមានបានទទួលឱកាសដើម្បីអានប្រតិចារឹកណា នៅត្រង់ទំព័រណាខ្លះនៃប្រតិចារឹកទាំងមូលដែលលោកបានផ្តល់កាលពីពេលនោះដែរឬទេ?

**លោក ញ៉ែម សំណាង៖**

អ៊ឹំយល់សំណួរទេ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** ខ្ញុំអត់បានអានទេ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** សូមអរគុណលោក។ ហើយសំណួរចុងក្រោយ លោកបានឆ្លើយហើយតាមខ្ញុំដឹង តើលោកដែលមានពេលវេលាណាដើម្បីធ្វើការប្រៀបធៀបទំព័រណាមួយនៃបទសម្ភាសន៍លោកជាមួយនឹង-- នៅក្នុងសេចក្ដីសង្ខេបនៃកំណត់ហេតុស្ដាប់ចម្លើយរបស់សហចៅក្រមស៊ើបអង្កេត?

**លោក ញ៉ែម សំណាង៖**

យល់ទេអ៊ឹំ?

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** លោក ឡុង នរិន្ទ លោកយល់សំណួរខ្ញុំដែរ ឬក៏ខ្ញុំគួរតែសួរលោកម្ដងទៀត?

**លោក ញ៉ែម សំណាង៖**

អ៊ឹំយល់សំណួរទេអ៊ឹំ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** អត់ដឹងគាត់សួរថាម៉េច?

**ស៖** ខ្ញុំសូមសួរលោកម្ដងទៀត តាមរយៈប្រតិចារឹកដែលលោកបានផ្ដល់ជូនគឺសំណួរចម្លើយៗដែលមានទាំងអស់៩៨ទំព័រ គឺអ្នកស៊ើបអង្កេត គាត់បានសង្ខេបមកត្រឹមតែ៩ទំព័រ តើលោកមានបានទទួលឱកាសណាមួយ ដើម្បីធ្វើការប្រៀបធៀបប្រតិចារឹក ចំនួន៩៨ទំព័រទាំងមូល ជាមួយនឹងសេចក្ដីសង្ខេបប្រតិចារឹកតែ៩ទំព័រនេះដែរឬទេ?

[០៩:៣១:៤៦]

**ឆ៖** អត់បានធ្វើទេ។

**ស៖** សូមអរគុណលោក។ វាអាចជាការត្រឹមត្រូវ ដែលគួរនិយាយថា ក្រោយពីឆ្នាំ១៩៧៩ លោកបានទទួលព័ត៌មានខ្លះៗនូវអ្វី ដែលអាចនឹងបានកើតមានឡើងចន្លោះពីឆ្នាំ១៩៧៥ ដល់១៩៧៩?

**លោក ញ៉ែម សំណាង៖**

យល់សំណួរទេអ៊ំ?

**លោក ឡុង នរិន្ទ៖**

អត់យល់ទេ។ គាត់សួរថាម៉េចអំមិញ?

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ខ្ញុំនឹងសួរក្នុងទម្រង់ផ្សេងវិញ។ តើលោកអាចជម្រាបយើងខ្ញុំដែរឬទេថា ក្រោយឆ្នាំ១៩៧៩ លោកបានអានព័ត៌មានមួយចំនួន អំពីអំឡុងពេលហេតុការណ៍ ដែលកើតឡើងចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ ១៩៧៩ តើមានបានអានព័ត៌មានទាក់ទងនឹងរយៈពេលនោះដែរឬទេ?

**ឆ៖** ពីរយៈពេល៧៥ ដល់៧៩។

**លោក ញ៉ែម សំណាង៖**

ក្រោយពីឆ្នាំ១៩៧៩មក តើអ៊ំមានបានអានព័ត៌មានចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដែរទេ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** ខ្ញុំអត់បានអានទេ ព័ត៌មានអី។

**ស៖** ហើយលោកបានជម្រាបទៅដល់បុគ្គលផ្សេងថា លោកមិនដែលនិយាយអំពីអំឡុងពេលឆ្នាំ ៧៥ ដល់៧៩ ទៅប្រាប់នរណាគេផ្សេងទេ មែនដែរឬទេ?

**លោក ញ៉ែម សំណាង៖**

អ៊ំយល់ទេអ៊ំ?

**លោក ឡុង នរិន្ទ៖**

គាត់ថាពី៧៥ទៅ៧៦ហ្នឹង ខ្ញុំបាននិយាយប្រាប់នរណាអ៊ីចេះ! យ៉ាងម៉េចហ្នឹង?

**លោក ញ៉ែម សំណាង៖**

ចង់និយាយថា លោកអ៊ំមានបាននិយាយព័ត៌មានអ្វី អំពីចន្លោះឆ្ន១៩៧៥ ទៅឆ្នាំ១៩៧៩ ហ្នឹងមាន បាននិយាយទៅប្រាប់អ្នកណាទេអ៊ំ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** ខ្ញុំភ្លេចអស់ហើយ មិនដឹង។

[០៩:៣៤:៣៦]

**ស៖** តើត្រឹមត្រូវដែរឬទេថា មានហេតុការណ៍មួយចំនួនជាច្រើន ដែលលោកមិនបានចងចាំ តើពិតជាត្រឹមត្រូវដែរឬទេ?

**លោក ញ៉ែម សំណាង៖**

អ៊ំយល់សំណួរទេអ៊ំ? យល់ទេ? អ៊ំយល់សំណួរអំមិញទេ?

**លោក ឡុង នរិន្ទ៖**

អត់។

**លោក ញ៉ែម សំណាង៖**

សំណួរអំមិញសួរថា តើហេតុការណ៍មួយចំនួនអំឡុងក្រោយមកនេះ តើអ៊ំអត់បានមានការចងចាំ តើពិតមែនទេ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** បាទ, ខ្ញុំអត់ចងចាំទេ មិនសូវចងចាំអីទេ។

**ស៖** លោកបានផ្តល់ឱកាស ហើយលោកប្រហែលជាយល់ច្រឡំ មានការយល់ច្រឡំទៅលើហេតុការណ៍ដែលកើតឡើងនៅអំឡុងពេលនោះមួយចំនួន មែនដែរឬទេ?

**លោក ញ៉ែម សំណាង៖**

យល់សំណួរទេអ៊ំ?

**លោក ឡុង នរិន្ទ៖**

អត់យល់ មិនដឹងគាត់ថាម៉េច?

**លោក ញ៉ែម សំណាង៖**

មេធាវីសួរថា តើអ៊ំមានការយល់ច្រឡំខ្លះទេនូវហេតុការណ៍នៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ណាអ៊ំ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** យល់ច្រឡំយ៉ាងម៉េចទេ។

**ស៖** នៅពេលនេះ ខ្ញុំសូមរំឭកឡើងនៅពេលដែលលោកត្រឡប់ទៅប៉ៃកាំង លោកបានជម្រាបថា លោកចាកចេញពីប្រាក ហើយធ្វើដំណើរទៅប៉ៃកាំង ហើយលោកចាំទេថា បានជម្រាបអង្គសវនាការលើចំណុចហ្នឹង?

**លោក ម៉ៃខល កាណាវ៉ាស៖**

នៅពេលនេះ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំមិនបានឮចម្លើយរបស់សាក្សីក្នុងចន្លោះពេលមួយចំនួន ប្រហែលជាគាត់ហត់ ហើយនៅក្នុងថ្ងៃនេះមិនអាចផ្តល់សក្ខីកម្មបាន ដូច្នេះហើយគាត់មិនបានឆ្លើយតប សូម្បីតែសំណួរងាយៗក៏ដោយ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមជំទាស់ក្នុងការលើកឡើងដូច្នេះពីខាងមេធាវីការពារក្តី។ ខ្ញុំសង្កេតឃើញថាវាមិនមានភាពខុសគ្នានៅក្នុងស្ថានភាពនៃការពិនិត្យទៅលើសាក្សីតាមរយៈវីដេអូនេះទេ។ យើងនឹងព្យាយាមធ្វើឱ្យបានល្អ តាមតែអាចយើងធ្វើទៅបាន ប៉ុន្តែវាមិនជាការលើកឡើងត្រឹមត្រូវក្នុងការផ្តល់ការសង្កេតបែបនេះនោះទេ។

[០៩:៣៧:៥៩]

**លោក ម៉ៃខល កាណាវ៉ាស៖**

លោកប្រធានអាចសាកសួរទៅលោក ឡុង នរិន្ទ ថាតើលោក ឡុង នរិន្ទ មានលទ្ធភាពនឹងអាចផ្តោតអារម្មណ៍ ផ្ចង់អារម្មណ៍ស្តាប់ យល់ និងឆ្លើយតបទៅនឹងសំណួរដែរឬទេ? ទោះបីជាគាត់អង្គុយនៅទីនេះក៏ដោយ។

**ប្រធានអង្គជំនុំ៖**

លោក ឡុង នរិន្ទ តើលោកមានស្តាប់នូវការសួររបស់មេធាវីបានដែរឬទេ?

**លោក ឡុង នរិន្ទ៖**

ស្តាប់អត់បាន គាត់សួរថាម៉េច? ទេ សំណួរនេះខ្ញុំយល់ ខ្ញុំដឹងថាសួរពីរឿងថា មេធាវីនោះ។

**ប្រធានអង្គជំនុំ៖**

ឥឡូវបើស្តាប់បាន គឺអង្គជំនុំជម្រះបន្តការសួរដេញដោលចំពោះរូបលោកបន្តទៅទៀត ហើយសូមលោកផ្ចង់អារម្មណ៍ ដើម្បីឆ្លើយនឹងសំណួរៗរបស់មេធាវីដែលនឹងសួរ។ ហើយពេលវេលាទំនងជាមិនឆ្លងទៅដល់ល្ងាចទេ បានន័យថានៅព្រឹកនេះយើងនឹងប្រឹងប្រែងធ្វើកិច្ចការនេះឲ្យចប់ ក្នុងការយកស្តាប់សក្ខីកម្មរបស់លោក។ អ៊ំអាចបន្តការឆ្លើយនឹងសំណួរដែលនឹងបន្តការសួរនៅព្រឹកនេះបានទេ?

**លោក ញ៉ែម សំណាង៖**

អ៊ំឮចៅក្រមសួរទេអ៊ំ?

**លោក ឡុង នរិន្ទ៖**

បាទ។

**លោក ញ៉ែម សំណាង៖**

អឺំអាចបន្តសួរឆ្លើយដេញដោលបានទៀតទេអ៊ំ?

**លោក ឡុង នរិន្ទ៖**

ទេ ឥឡូវហ្នឹងឈឺក្បាល ហើយរួយ-ក។

[០៩:៣៩:៤០]

**លោក ញ៉ែម សំណាង៖**

តើអ៊ំអាចបន្តទៀតបានទេអ៊ំ?

**ប្រធានអង្គជំនុំ៖**

ឥឡូវសូមអញ្ជើញបន្ត ហើយមេធាវីសូមតាំងសំណួរឱ្យខ្លីៗ ហើយសូមឱ្យអ្នកបកប្រែ គឺបកប្រែឱ្យបានច្បាស់លាស់ ហើយនិងយឺតៗ ដើម្បីឱ្យស្តាប់បានក្នុងករណីដែលមានបញ្ហាខ្លះ អង្គជម្រះអនុញ្ញាតឱ្យលោក ញ៉ែម សំណាង អាចរំឭកអំពីសំណួរដែលសួរដោយភាគីនានាទៅកាន់គាត់ ដើម្បីឱ្យគាត់បានស្តាប់យល់អំពីសំណួរនឹងអាចឆ្លើយបាន។ ហើយតាមខ្ញុំយល់ មិនមែនប្រហែលជាប៉ុណ្ណឹងទេ វាអាចមកពីឧបករណ៍ផងដែរ ក្នុងការរៀបចំឧបករណ៍ហ្នឹង ដាក់ហ្នឹងខ្លាចបាំងមនុស្ស។ អ៊ីចឹងហើយបានជានាំឱ្យមានគម្លាតឆ្ងាយរវាងត្រចៀកមាត់និយាយជាមួយនឹងឧបករណ៍។ វាក៏អាចនាំឱ្យសំឡេងហ្នឹង វាអាចថយដែរ អាហ្នឹងការគិតគូររបស់អ្នកបច្ចេកទេសដែលគួរពិនិត្យលើបញ្ហានេះ ក្នុងករណីនេះដែលយើងត្រូវធ្វើនៅលើកក្រោយៗទៀត ប្រសិនបើមាន។

សូមអញ្ជើញបន្ត! តាំងសំណួរឡើងវិញ សំណួរចុងក្រោយអម្បាញ់មិញនេះ។

[០៩:៤០:៥៥]

**លោក ម៉ៃខល កាណាវ៉ាស៖**

សូមអរគុណប្រធាន។

**សួរដោយលោក ម៉ៃខល កាណាវ៉ាស៖**

**ស៖** លោក ឡុង នរិន្ទ តើលោកចងចាំដែរឬទេ ថាលោកបានចាកចេញពីប្រាក ហើយទៅធ្វើដំណើរទៅប៉េកាំង ប្រហែលជាក្នុងឆ្នាំ១៩៧១ តើលោកចាំទេ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** ចេញទៅ ចាកចេញពីស្រុកខ្មែរទៅរៀនឯក្រៅ អាហ្នឹងខ្ញុំចាកចេញពី៦០ ឆ្នាំសិក្សា៦០ មក ៦១។

**លោក ញ៉ែម សំណាង៖**

សំណួរចង់សួរថា អ៊ំបានចាកចេញពីទីក្រុងប្រាក នៅប្រទេសឆេកូស្លូវ៉ាគី ទៅកាន់ទីក្រុងប៉េកាំង ប្រទេសចិនណាអ៊ំ ប្រហែលជានៅក្នុងចន្លោះឆ្នាំ៧១។ តើហ្នឹងពិតមែនទេ?

**ឆ៖** បាទ, ខ្ញុំរៀនចប់។ មែនទែនខ្ញុំប្រលងចប់អស់ហើយហ្នឹង ខ្ញុំចាកចេញពីឆេកូមក មកចូល នៅប៉េកាំង ដោយសារព្រះកុរុណាលោក។ កាលនុ៎ង ព្រះករុណា សីហនុ លោកធ្វើសេចក្ដីអំពាវនាវពី ប៉េកាំងទៅ។ ខ្ញុំបាន ខ្ញុំមកចូលប៉េកាំងហ្នឹង ហើយដល់ខ្ញុំ--

[០៩:៤២:១៤]

**ប្រធានអង្គជំនុំ៖**

អ៊ំៗ ឡុង នរិន្ទ គឺសំណួរគេសួរសំណួរសួរតែត្រឹមថា តើលោកនៅចងចាំដែរឬទេ អំពីការចាក ចេញដំណើរពីទីក្រុងប្រាក ប្រទេសឆេកូហ្នឹងទៅកាន់ទីក្រុងប៉េកាំងក្នុងអំឡុងឆ្នាំ៧១។ បើលោកចាំ ចាំ តែប៉ុណ្ណឹងទៅបានហើយ។ ពាក្យកម្ពុជាមានន័យថាម៉េច នៅផ្លូវតុលាការគេថាសួរអីឆ្លើយហ្នឹង។ បើគេ សួរតែប៉ុណ្ណឹងទេ ឆ្លើយតបតែប៉ុណ្ណឹងបានហើយ។ អ៊ំយល់ទេ អ៊ំហាត់នឿយ ដល់ពេលអ៊ំទៅបកស្រាយ ន័យផ្សេងទៀត គឺវានាំឲ្យខាតពេល ហើយមានកាន់តែហត់នឿយទៀត។ អ៊ីចឹងអាស្រ័យលើសំណួរ ហើយសំណួរឥឡូវហ្នឹងកំពុងខិតខំដើម្បីឲ្យមានការតាំងសំណួរខ្លីៗជាក់ច្បាស់ ដើម្បីឲ្យអ៊ំងាយយល់នៅ ក្នុងឆ្លើយតប។

សូមអញ្ជើញបន្តសំណួរទៀត លោកមេធាវី។

[០៩:៤៣:១១]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** នៅពេលដែលលោកនៅទីក្រុងប៉េកាំង លោកបានទាក់ទងជាមួយនឹងព្រះករុណា ឬក៏អត់ បានទាក់ទងទេ នៅពេលដែលព្រះករុណាជាសម្ដេចនៅពេលនោះ? តើលោកបានទាក់ទងឬក៏អត់?

**លោក ឡុង នរិន្ទ៖**

**ឆ៖** ហ្នឹងខ្ញុំបានទាក់ទង។

**ស៖** ក្នុងអំឡុងពេលនោះ ព្រះករុណាបានរៀបចំពិធីបង់កេមួយសម្រាប់ភ្ញៀវកិត្តិយស ហើយនិងអ្នកដែលជាបងប្អូនប្រជាជនរបស់គាត់ តើលោកបានចូលរួមដែរឬទេ?

**ឆ៖** ខ្ញុំមិនចាំទេ។

**ស៖** តើលោកចងចាំទេថា ព្រះអង្គបានទូរស័ព្ទហៅលោកក្នុងថ្ងៃនោះ ឬក៏ទាំងយប់ផងដែរ ដើម្បីឲ្យលោកទៅលេងកីឡាជាមួយនឹងព្រះអង្គ?

**ឆ៖** ខ្ញុំមិនចាំ។

**ស៖** តើលោកចាំដែរឬទេថា លោកបាននិយាយជាមួយនឹងលោក ហ្វីលីព ហ្សូត ដែលគាត់បាននិពន្ធសៀវភៅមួយក្បាលអំពីលោក ប៉ុល ពត?

[០៩:៤៥:០៥]

**លោក ញ៉ែម សំណាង៖**

យល់សំណួរទេអ៊ំ? អ៊ំយល់សំណួរទេអ៊ំ?

**លោក ឡុង នរិន្ទ៖**

អត់ មិនដឹងសួរថាម៉េចផង។

**លោក ញ៉ែម សំណាង៖**

សួរថា តើអ៊ំបាននិយាយជាមួយនឹងលោក ហ្វីលីព ហ្សូត ជាអ្នកនិពន្ធសៀវភៅនិយាយអំពីប៉ុល ពត។

**លោក ឡុង នរិន្ទ៖**

ហ្វីលីព ហ្សូត ម៉េច?

**លោក ញ៉ែម សំណាង៖**

សុំឈ្មោះអ្នកនិពន្ធម្តងទៀត? អធ្យាស្រ័យ។

**ស៖** ឈ្មោះ ហ្វីលីព ហ្សូត។

**លោក ញ៉ែម សំណាង៖**

ហ្វីលីព ហ្សូត។

**លោក ឡុង នរិន្ទ៖**

**ឆ៖** ហ្វីលីព ហ្សូត អី មិនចាំទេ។

[០៩:៤៥:៥៩]

**ស៖** ខ្ញុំចាត់ទុកថា លោកមិនបានចាំថា លោកបានពិភាក្សាអំពី ប-១៥ មិនមែន ប-២០ នោះទេ តើពិតជាដូច្នោះដែរឬទេ?

**ឆ៖** ប-១៥ ខ្ញុំចេញពីប-១៥--

**លោក ញ៉ែម សំណាង៖**

អ៊ំយល់សំណួរទេអ៊ំ?

**លោក ឡុង នរិន្ទ៖**

អត់ អំមិញហ្នឹងគឺ--

**លោក ញ៉ែម សំណាង៖**

សូមតាំងសំណួរម្តងទៀត។

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** នៅក្នុងការដែលលោកជជែកពិភាក្សាជាមួយនឹងលោក ហ្វីលីព ហ្សូត។ លោក ឡុង នរិន្ទ លោកបានត្រឹមតែពិភាក្សាអំពីមន្ទីរប-១៥ តែប៉ុណ្ណោះ។ លោកមិនបានពិភាក្សាជជែកអំពីប-២០ នោះទេ តើពិតជាដូច្នោះដែរឬទេ?

**ឆ៖** អត់ដឹង ប-២៧ ហ្នឹង នៅត្រង់ណាផង។

[០៩:៤៧:១៩០]

**លោក ញ៉ែម សំណាង៖**

សំណួរថា កាលដែលលោកពិភាក្សាជាមួយលោក ហ្វីលីព ហ្សូត ហ្នឹង តើអ៊ំបាននិយាយតែអំពី ប-១៥ ហើយអ៊ំពុំបានជជែកអំពី ប-២០ នោះទេ តើជាការពិតដែរឬទេ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** អាហ្នឹងការពិតហើយមើលទៅ។ ខ្ញុំចាំអ៊ីចឹង។

**ស៖** លោកប្រហែលជាមានការច្រឡូលច្របល់ច្រឡំ ប-១៥ និងប-២០ តើលោកមានច្រឡំ ប-១៥ និងប-២០ ដែរឬទេ?

**ឆ៖** អំមិញគាត់មាននិយាយពី ប-២៣។

**លោក ញ៉ែម សំណាង៖**

អត់ទេអ៊ំ សំណួរសួរថា តើអ៊ំមានការច្រឡំរវាង ប-១៥ និងប-២០ ដែរឬទេ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** អត់ច្រឡំទេ។

**ស៖** តើលោកចាំដែរឬទេ ថាលោកបាននិយាយជាមួយនឹងលោក ហ្វីលីព ហ្សូត នៅមន្ទីរ១៥ តើលោកពិតជាបាននិយាយដូច្នោះដែរឬទេ អំពីមន្ទីរ១៥?

**ឆ៖** មន្ទីរ១៥។

**ស៖** មន្ទីរប-១៥។

[០៩:៤៨:៥៤]

**លោក ញ៉ែម សំណាង៖**

តើអ៊ំបាននិយាយជាមួយនឹងលោក ហ្វីលីព ហ្សូត ហ្នឹងអំពីប-១៥?

**លោក ឡុង នរិន្ទ៖**

**ឆ៖** ខ្ញុំមិនដឹងអ្នកណាផង ហ្វីលីព ហ្សូត អី។

**ស៖** សូមអរគុណ។ ប្រសិនបើខ្ញុំយល់ការផ្តល់ចម្លើយរបស់លោកអ៊ំ។ លោកត្រឹមតែជាអ្នកវាយឯកសារតែប៉ុណ្ណោះ នៅពេលដែលលោកធ្វើការនៅក្រសួងការបរទេសនៅពេលនោះ តើពិតជាត្រឹមត្រូវដែរឬទេ?

**លោក ញ៉ែម សំណាង៖**

សួរថា តើអ៊ំផ្តល់ចម្លើយថាអ៊ំគ្រាន់តែជាអ្នកវាយអង្គុលីលេខ នៅក្រសួងការបរទេសតែប៉ុណ្ណឹង តើជាការពិតទេអ៊ំ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** ការពិត អាហ្នឹងជាការពិត។

[០៩:៥០:០០]

**ស៖** តើត្រឹមត្រូវដែរឬទេថា លោកមិនបានទទួល និងមើលព័ត៌មានមួយចំនួននោះទេ ដោយសារតែលោកធ្វើការងារត្រឹមតែអ្នកវាយអង្គុលីលេខតែប៉ុណ្ណោះ តើពិតជាដូច្នោះដែរឬទេ?

**ឆ៖** ខ្ញុំស្ដាប់អត់បាន។ និយាយញាប់ពេក។

**ស៖** ឧទាហរណ៍ ក្នុងនាមជាអ្នកវាយអង្គុលីលេខ លោកក៏បានគេអញ្ជើញឱ្យទៅចូលរួមដប់ដង ឱ្យប្រជុំពិភាក្សាបញ្ហាអំពីគោលនយោបាយ តើមានការប្រជុំដូច្នោះដែរឬទេ? មានអញ្ជើញអ៊ំទៅចូលរួម ដូច្នោះដែរឬទេ?

**លោក ញ៉ែម សំណាង៖**

ស្ដាប់បានទេ? ស្ដាប់បានទេអ៊ំ?

**លោក ឡុង នរិន្ទ៖**

ស្ដាប់បាន។ សំណួរគាត់ហ្នឹងចង់សួរថាម៉េច?

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** តើលោកបានចូលរួមការប្រជុំណាមួយដែរឬទេ? ដែលនៅពេលប្រជុំពេលនោះមានការពិភាក្សាគ្នាអំពីបញ្ហាគោលនយោបាយ ឧទាហរណ៍ និយាយអំពីទំនាក់ទំនងរបស់ប្រទេសកម្ពុជា ជាមួយនឹងប្រទេសដទៃ។

**ឆ៖** អាហ្នឹងវា ខ្ញុំត្រូវតែទៅជាមួយគេជាមួយឯង អ៊ីចឹងទៅស្ដាប់--

**ស៖** ថាតើមានកម្មាភិបាលផ្សេងទៀតដែរឬទេ ដែលធ្វើការនៅក្នុងក្រសួងការបរទេស ដែលកម្មាភិបាលផ្សេងអាចដឹងព័ត៌មានពេញលេញ និងច្បាស់ជាងលោក?

[០៩:៥២:១៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

លោកប្រធានយើងសូមជំទាស់សំណួរនេះ ខ្ញុំមិនដឹងថា តើសាក្សីគាត់ដឹងអំពីបុគ្គលផ្សេង សាក្សីដែលអាចដឹងព័ត៌មានច្រើនជាងគាត់ដោយរបៀបណានោះទេ។ ដូច្នេះហើយមេធាវីគួរតែសួរសំណួរមួយក្នុងទម្រង់ផ្សេង ប្រសិនបើសួរសំណួរបែបនេះមិនត្រឹមត្រូវនោះទេ។

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំរីករាយនឹងសួរសំណួរឡើងវិញ។

**ស៖** លោក ឡុង នរិន្ទ តើលោកមានមេគ្រប់គ្រងពីលើលោកដែរ ឬទេ?

**លោក ញ៉ែម សំណាង៖**

តើអ៊ំមានមេគ្រប់គ្រងពីលើអ៊ំទៀតទេអ៊ំ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** បាទ, ខ្ញុំមាន។

**លោក ញ៉ែម សំណាង៖**

មេគ្រប់គ្រងនៅក្រសួងការបរទេសនោះណាអ៊ំ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** មាន។

**ស៖** ថាតើនៅពីលើលោក ចន្លោះនៅពីលើលោកទៅដល់លោក អៀង សារី តើមាននរណាគេនៅពេលលើលោក? មានប៉ុន្មានដែរ គ្រប់គ្រងប៉ុន្មាននាក់ដែរ ដែលគ្រប់គ្រងលើលោកអ៊ំនុ៎ង?

**ឆ៖** មានលោក សួង ស៊ីគឿន ជាប្រធានផ្នែកខ្ញុំ។

**ស៖** ហើយតើលោក ស៊ីគឿន ហ្នឹងគាត់មានអ្នកគ្រប់គ្រងពីលើគាត់ទៀតដែរឬទេ?

**ឆ៖** មានអ្នកគ្រប់គ្រង គឺខ្ញុំ--

**ស៖** នរណាគេដែរ ដែលគ្រប់គ្រងពីលើគាត់?

**ឆ៖** កាលហ្នឹង គឺលោក សួង ស៊ីគឿន។

**លោក ញ៉ែម សំណាង៖**

សំណួរចង់ដឹងថា មានអ្នកណាដែលជាមេរបស់លោក សួង ស៊ីគឿន ទៀតអ៊ីចឹងអ៊ំ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** ពេលទៅទៀត ខ្ញុំមិនដឹងជាគាត់មាននរណាទៀត ឬអត់ទេ ប៉ុន្តែបែប-- មិនបែបអីទេ គឺនៅពីលើគាត់ទៅទៀតហ្នឹងអាហ្នឹងទាល់តែសួរគាត់បានដឹង ខ្ញុំ-- ព្រោះអង្គាល់ហ្នឹង វាខណ្ឌ--

[០៩:៥៥:00]

**ស៖** ចុះក្មួយរបស់ ប៉ុល ពត តើក្មួយប្រុសរបស់ ប៉ុល ពត នោះមានធ្វើការនៅក្រសួងការបរទេសដែរឬទេ?

**លោក ឡុង នរិន្ទ៖**

សួរស្អីចេះ? ផែនការរបស់ ប៉ុល ពត--

**លោក ញ៉ែម សំណាង៖**

ស្ទូរថា ក្មួយប្រុសរបស់លោក ប៉ុល ពត មានធ្វើការនៅក្រសួងការបរទេសដែរទេ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** អត់ទេ។ អត់មានមកធ្វើការនៅការបរទេសទេ គឺក្មួយប្រុសរបស់គាត់មានពីរនាក់ មាន លោក សូរ ហុង ហើយនិងលោកម្នាក់ទៀតឈ្មោះអីហើយទេ--។

**ស៖** សូរ ហុង តើលោក សូរ ហុង នោះគាត់មានធ្វើការនៅក្រសួងការបរទេសនោះដែរឬទេ?

**ឆ៖** គ្រាន់តែមានឈ្មោះទេ អត់ឃើញមកធ្វើការទេ មកនេះអីទេ មកអង្គុយអីនៅក្នុងក្រសួង នោះអត់ឃើញទេ។

[០៩:៥៦:២៨]

**ស៖** ដូច្នេះនៅថ្ងៃនេះលោកឆ្លើយថា តាមអ្វីដែលខ្ញុំយល់ថាលោក សូរ ហុង មិនដែលទៅធ្វើការ នៅក្រសួងការបរទេសនោះទេ។ តើពិតជាដូច្នោះដែរឬទេ?

**ឆ៖** អត់ៗមកធ្វើការនៅក្នុងក្រសួងការបរទេសនេះទេ មកអង្គុយនៅការិយាល័យអត់មានទេ។

**ស៖** នេះជាសំណួរចុងក្រោយរបស់ខ្ញុំ តើលោកប្រហែលជាប៉ុន្មានឆ្នាំកន្លងមកនេះ លោកមាន ការច្រឡំច្របូកច្របល់ទៅនឹងហេតុការណ៍ដែលបានកើតឡើងកាលពីមុន ដែលលោកត្រូវបានគេសួរឲ្យ ឆ្លើយនៅពេលនេះ តើពិតជាដូច្នោះដែរឬទេ?

**លោក ញ៉ែម សំណាង៖**

អ៊ំយល់សំណួរទេអ៊ំ?

**លោក ឡុង នរិន្ទ៖**

(ឮមិនច្បាស់) គាត់សួរថាម៉េច?

**លោក ញ៉ែម សំណាង៖**

សួរថា តើអ៊ំមានការច្របូកច្របល់ច្រឡំគ្នាខ្លះទេ កន្លងមកនោះណា? ទាក់ទងនឹងការផ្តល់ ចម្លើយ។

**លោក ឡុង នរិន្ទ៖**

**ឆ៖** ខ្ញុំមិនដឹងជាយ៉ាងម៉េចទេ បែបខ្ញុំមានការច្របូកច្របល់ហើយ។

[០៩:៥៨:០៥]

**លោក ម៉ៃខល ការណាវាស៖**

សូមអរគុណលោកច្រើន។ តាងនាមឲ្យលោក អៀង សារី និងលោក អាង ឧត្តម ខ្ញុំសូមថ្លែងអំណរគុណចំពោះលោកដែលបានមកផ្តល់សក្ខីកម្មនៅក្នុងពេលនេះ។ សូមអរគុណច្រើន សូមអរគុណលោកប្រធាន និងអង្គសវនាការ។

**ប្រធានអង្គជំនុំ៖**

បាទ, សូមអរគុណ។

ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកដែរហើយ ហើយដោយសារស្ថានភាពសុខភាពសាក្សីរូបនេះមានវ័យចំណាស់ផង។ ដូច្នេះអង្គជំនុំជម្រះប្រកាសសម្រាក ២០នាទីចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់ម្ភៃនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សូមអញ្ជើញ!

**លោក អាកទ្វរ វែកគែន៖**

បាទ, សូមអរគុណលោកប្រធាន។ ខ្ញុំក្រោកឈរនេះ ពីព្រោះខ្ញុំគិតថាជាការសំខាន់សម្រាប់តុលាការក្នុងការដឹងថា មេធាវីរបស់លោក ខៀវ សំផន មិនចង់ពន្យារពេលក្នុងការស្តាប់សាក្សីនេះទៀតទេ។ អ៊ីចឹងទុកឲ្យសាក្សីហ្នឹងព្យាបាលជំងឺឈឺក្បាលរបស់ខ្លួនទៅ។

បាទ, អ៊ីចឹងដើម្បីឲ្យច្បាស់លាស់ខ្ញុំចង់ជម្រាបថា ខ្ញុំពុំមានសំណួរអីចោទសួរទៅសាក្សីនោះទេ។

[០៩:៥៩:៤១]

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណ ហើយបើនិយាយច្បាស់ៗអ៊ីចឹង គឺងាយស្តាប់គ្នា។ មេធាវីគប្បីនិយាយច្បាស់ៗកុំឲ្យវាពិបាកក្នុងការពិចារណាបន្ថែមទៀត។

បាទ, សូមអញ្ជើញ លោក ឡុង នរិន្ទ អាចបន្តពីរបីសំណួរទៀតមុននឹងបញ្ចប់ ដោយសារខាងអង្គជំនុំជម្រះនៅមានសំណួរចង់-- មានបំណងសួរចំពោះលោក។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ, សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** នេះគឺជាការបំភ្លឺនោះទេ។ នៅផ្នែកបញ្ចប់នៃកំណត់របស់ការស្តាប់ចម្លើយរបស់លោកនោះ ដែលធ្វើដោយអ្នកស៊ើបអង្កេតរបស់ការិយាល័យចៅក្រមស៊ើបអង្កេត គឺមានការបញ្ជាក់ដូចតទៅនេះ៖

អានកំណត់ហេតុដែលបានធ្វើអាន ហើយសាក្សីពុំមានជំទាស់អ្វីទេ ហើយសុខចិត្តចុះហត្ថលេខា។

ហើយក៏មានបញ្ជាក់ផងដែរថា ឯកសារចម្លងមួយច្បាប់ ឬក៏ឯកសារច្បាប់ដើមមួយក្នុងចំណោមឯកសារច្បាប់ដទៃទៀតត្រូវបានប្រគល់ជូនទៅឲ្យសាក្សីនេះ។ កិច្ចនេះបញ្ចប់ និងត្រូវបានចុះហត្ថលេខា ហើយនិងមានផ្តិតមេដៃដោយលោក ឡុង នរិន្ទ។ តើ ឡុង នរិន្ទ អាចបញ្ជាក់ថា ការបញ្ជាក់ទាំងអស់នេះពិតជាត្រឹមត្រូវដែរឬទេ? ហើយលោកចាំរឿងរ៉ាវទាំងអស់នេះដែរឬទេ?

[១០:០២:២៥]

**លោក ញ៉ែម សំណាង៖**

យល់ទេអ៊ំ?

**លោក ឡុង នរិន្ទ៖**

អត់យល់!

**លោក ញ៉ែម សំណាង៖**

លោកចៅក្រមសួរថា នៅទំព័រចុងក្រោយហ្នឹង គឺអ៊ំបានយល់ព្រមអំពីការស៊ើបសួររបស់បុគ្គលិកការិយាល័យសហចៅក្រមស៊ើបអង្កេតនៅឆ្នាំ២០០៧ ហ្នឹង អ៊ំបានផ្តិតមេដៃទទួលឯកសារហ្នឹង ហើយគេមានកូពីមួយច្បាប់ទុកឲ្យអ៊ំ។ ថាតើឯកសារស៊ើបអង្កេតហ្នឹង អ៊ំបានទទួលយ៉ាងម៉េចទេអ៊ំ?

**លោក ឡុង នរិន្ទ៖**

ឯកសារដែលខ្ញុំដាក់នៅត្រង់នេះៗ?

**លោក ញ៉ែម សំណាង៖**

ឯកសារកាលពីឆ្នាំ២០០៧ ណាអ៊ំ ដែលគេមកស៊ើបសួរអ៊ំកាលពីឆ្នាំ២០០៧ ណាអ៊ំ។ អ៊ំចាំទេកាលពីឆ្នាំ២០០៧?

**លោក ឡុង នរិន្ទ៖**

២០០៧ អត់ចាំទេ។ ឈ្មោះអីហ្នឹងក៏អត់--

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** តើនៅកន្លែងហ្នឹង តើអ្នកគាំពារដល់សាក្សី អ្នកជំនាញហ្នឹង មានឯកសារនុ៎ងទេ? តើលោកមានឯកសារនុ៎ងទេ? ដែលខ្ញុំយល់ឃើញថា-- ដោយខ្ញុំគិតថា ឯកសារនុ៎ងបានប្រគល់ជូនលោក ឡុង នរិន្ទ ហើយមុននឹងពេលយើងស្តាប់យកចម្លើយនេះ។ អ៊ីចឹងប្រហែលជាគាត់អាចអានឯកសារនេះ។ គឺថា D91/3។

[១០:០៤:០៨]

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំមិនធ្វើការ មិនមែនថាចង់កាត់សម្តីទេ មិនមែនថាមាន៩៨ទំព័រ នោះទេ គឺប្រាំបួនទំព័រតែប៉ុណ្ណោះ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

កាណាវាស បើសិនជាលោកយល់នោះ ស្តាប់ខ្ញុំហ្នឹង យើងដឹងថាឯកសារដែលការស្តាប់យកចម្លើយនោះ គឺថាវាជាឯកសារ D91/3។ តើអង្គភាពគាំពារដល់សាក្សី/អ្នកជំនាញនោះមានឯកសារ D91/3នេះទេ ដែលជាឯកសារស្តាប់យកចម្លើយដែលធ្វើដោយការិយាល័យសហចៅក្រមស៊ើបអង្កេត។

[១០:០៥:០០]

**លោក ញ៉ែម សំណាង៖**

សូមជម្រាបលោកចៅក្រម កាលពីថ្ងៃទី០៦ សប្តាហ៍មុននោះខ្ញុំបានអានឲ្យលោក នរិន្ទ ស្តាប់ម្តងហើយ ដោយសារគាត់ពុំអាចអានដោយខ្លួនឯងបាន។ ហើយឯកសារនោះនៅមាននៅក្នុងដៃរបស់ខ្ញុំចំនួន ០៩ ទំព័រ ហើយឯកសារលេខ D91/3 គឺមាននៅក្នុងដៃរបស់ខ្ញុំបាទ។ សូមជម្រាបប្រសាសន៍ទាន។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** នៅចុងឯកសារហ្នឹងវាមានចុះហត្ថលេខា ហើយនិងស្នាមមេដៃរបស់សាក្សី។ តើលោក ឡុង នរិន្ទ ទទួលស្គាល់ហត្ថលេខារបស់ខ្លួនដែរឬទេ?

**លោក ញ៉ែម សំណាង៖**

លោកចៅក្រមសួរថា តើអ៊ំទទួលស្គាល់ហត្ថលេខា និងស្នាមមេដៃរបស់អ៊ំដែរឬទេ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** ស្នាមមេដៃនេះ ស្នាមមេដៃ--។ ហត្ថលេខានេះក៏ហត្ថលេខាខ្ញុំ ព្រោះមានអក្សរបាវាំង។

**ស៖** ដើម្បីបំភ្លឺ គឺថាគាត់មិនចាំថាគេអានរបាយការណ៍ហ្នឹង-- កំណត់ហេតុហ្នឹងឲ្យគាត់ទេ។ អ៊ីចឹងបានន័យថា លោក គឺថាលោកមិនចាំអង្គាល់នុ៎ងគឺថាគេឲ្យកំណត់ហេតុហ្នឹងឲ្យអានទេ ឬក៏យ៉ាងណា?

[១០:០៦:៤១]

**លោក ញ៉ែម សំណាង៖**

លោកចៅក្រមសួរថា តើអ៊ំចាំទេ អង្គាល់ដែលខ្ញុំអានឲ្យអ៊ំស្ដាប់ កាលដែលខ្ញុំមកជួបអ៊ំអាទិត្យមុនហ្នឹង?

**លោក ឡុង នរិន្ទ៖**

**ឆ៖** អត់ចាំ! អត់ចាំទេ។

**ស៖** តើគាត់ចាំដែរទេ ថាអង្គាល់នោះនុ៎ង គេបានបង្ខំគាត់ឲ្យគាត់ចុះហត្ថលេខាលើកំណត់ហេតុហ្នឹង?

**លោក ញ៉ែម សំណាង៖**

តើអ៊ំចាំទេថា កាលនោះគេបង្ខំឲ្យអ៊ំផ្ដិតមេដៃ ហើយនិងចុះហត្ថលេខា?

**លោក ឡុង នរិន្ទ៖**

**ឆ៖** នេះៗអត់ទេ។ ខ្ញុំផ្ដិតខ្លួនឯងហើយអាហ្នឹង។ ហើយហត្ថលេខាហ្នឹង ហត្ថលេខាស៊ីញ៉េអក្សរបារាំង ហ្នឹងខ្ញុំចាំ។

[១០:០៧:២៣]

**ស៖** អ៊ីចឹងដែលពេលចុះហត្ថលេខាហ្នឹង តើលោកពេលដែលចុះហត្ថលេខាហ្នឹងលោកដឹងថានេះលោកទទួលស្គាល់ការ សេចក្ដីថ្លែងការណ៍របស់លោកដែរឬទេ កាលនុ៎ង?

**ឆ៖** កាល--

**លោក ញ៉ែម សំណាង៖**

អ៊ីចឹងអ៊ំចុះហត្ថលេខា និងផ្ដិតមេដៃហ្នឹង អ៊ំបានទទួលស្គាល់សេចក្ដីថ្លែងការណ៍របស់អ៊ំហើយមែនទេអ៊ំ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** បាទ។ ព្រោះខ្ញុំបានស្ដាប់ហើយ។

**ស៖** សំណួរចុងក្រោយ។ បើតាមលោក ឡុង នរិន្ទ ហ្នឹង តើសេចក្ដីប្រកាសហ្នឹងនៅក្នុងកំណត់ហេតុហ្នឹង វាស៊ីគ្នានឹងអ្វីដែលលោកបានជម្រាបជូនទៅដល់អ្នកស៊ើបអង្កេតដែរឬទេ?

**លោក ញ៉ែម សំណាង៖**

ថាតើកំណត់ហេតុហ្នឹងវាស៊ីគ្នានឹងអ្វីដែលអ៊ំបានឲ្យទៅក្រុមស៊ើបអង្កេតដែរទេ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** កំណត់ហេតុនេះ មិនដឹងស៊ើបអង្កេតពីអង្កាល់ណា។

**ស៖** បាទ, សំណួរហ្នឹងមិនមែនសួរថា តើលោកដឹង ចង់ដឹងថាឲ្យលោកចាំថា ពេលណាដែលលោកផ្ដល់ចម្លើយនេះទេ។ សំណួរគឺចង់ដឹងថា តើអ្វីដែលសរសេរនៅក្នុងកំណត់ហេតុហ្នឹង ដូចនឹងអ្វីដែលលោកបានរៀបរាប់ប្រាប់អ្នកស៊ើបអង្កេតដែរឬក៏អត់?

បើនិយាយនិយាយឲ្យច្បាស់ទៅថា តើវាមានកំហុសអីនៅក្នុងកំណត់ហេតុហ្នឹងដែរឬទេ?

**ឆ៖** មែនទែនវានៅក្នុងហ្នឹងអស់ហើយ។ គាត់សួរបន្ថែម។

[១០:១០:១៨]

**លោក ញ៉ែម សំណាង៖**

លោកចៅក្រមសួរថា កំណត់ហេតុរបស់អ៊ំដែលធ្វើនេះ គឺវាស៊ីគ្នាជាមួយនឹងអ្វីដែលអ៊ំបានឆ្លើយទៅនឹងសហចៅក្រមស៊ើបអង្កេតដែរឬទេ? ព្រោះឯកសារនេះ ខ្ញុំបានអានជូនអ៊ំកាលពីថ្ងៃទី៦ ហ្នឹងម្ដងហើយណាអ៊ំណា។

**លោក ឡុង នរិន្ទ៖**

**ឆ៖** ប៉ុន្តែអង្កាល់ដែលចៅក្រមស៊ើបអង្កេតហ្នឹងគឺចាំអាន៎ុង(ឮមិនច្បាស់)។ ឥឡូវហ្នឹងតែ-- ខ្ញុំភ្លេចច្រើន។

**ស៖** បាទ, សូមអរគុណលោក ឡុង នរិន្ទ។

**លោក ម៉ៃខល កាណាវ៉ាស៖**

លោកប្រធាន។ ខ្ញុំមិនចង់ឲ្យកំណត់ហេតុនេះបង្ហាញថា លោកសាក្សីគាត់មិនមានលទ្ធភាពក្នុងការផ្ទៀងផ្ទាត់ និងប្រៀបធៀបទៅលើចម្លើយពីមុន និងចម្លើយសង្ខេបនេះទេ។ ដូច្នេះហើយ ខ្ញុំចង់សាកសួរសំណួរមួយចំនួនទៅគាត់ ប្រសិនបើមិនអនុញ្ញាតនោះទេ គឺខ្ញុំសូមឲ្យបកប្រែនូវកំណត់ហេតុប្រតិចារឹកទាំងមូលជាភាសាខ្មែរ អង់គ្លេស និងបារាំង។ ដោយសារបញ្ហានេះហើយ ទើបលោក អាង

ឧត្តម បានលើកឡើងបញ្ហានេះឡើង។ ដូច្នេះ អ្វីដែលយើងលើកឡើងអម្បាញ់មិញ ថាតើសេចក្ដីសង្ខេបហ្នឹងវាផ្ទុះបញ្ចាំងទៅនឹងឯកសារដើមដែរឬទេ? ហើយសាក្សី គាត់បានស្ដាប់ និងអាននូវសក្ខីកម្មដែលគាត់បានផ្ដល់។ ដូច្នេះហើយពេលខ្លះទៅ ប្រសិនបើយើងមិនបញ្ជាក់ឲ្យត្រឹមត្រូវនោះទេ ឯកសារភស្តុតាងវាមិនអាចជឿជាក់បាននោះទេ។ សាក្សីមួយរូបនេះ គឺគាត់អាចមានការភ្លេចភ្លាំង ទៅលើហេតុការណ៍មួយចំនួនដែលបានកើតឡើង។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតសួរសំណួរមួយ ឬក៏ពីរបីសំណួរទៀតទៅដល់សាក្សី។

[១០:១២:៤០]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ ដោយសារកំណត់ត្រានេះគឺច្បាស់លាស់ហើយ ពាក់ព័ន្ធទៅនឹងសេចក្ដីសង្ខេបចំនួន៩ទំព័រនេះ គឺមិនចាំអីត្រូវសួរសំណួរទៅលើកំណត់ហេតុសង្ខេបនេះទៀតទេ។ ហើយតាមដែលខ្ញុំយល់ ខ្ញុំបានស្ដាប់ឮថា មេធាវីជាតិរបស់លោក អៀង សារី គឺថាមានការខុសគ្នាជាខ្លាំងរវាងឯកសារទាំងពីរ។ យើងខ្ញុំគាំទ្រថា ប្រតិចារឹកគួរតែជាប្រតិចារឹកមួយពេញលេញ ហើយត្រូវផ្ដល់ទៅឲ្យសាក្សី ហើយខ្ញុំមិនជំទាស់អ្វីទៅនឹងការលើកឡើងសំណើសុំរបស់លោក ម៉ៃខល កាណាវាស ទេដែលថា ត្រូវផ្ដល់ប្រតិចារឹកទៅឲ្យសាក្សីអាននៅពេលក្រោយ។ ហើយប៉ុន្តែនៅចំពោះមុខសាក្សីនោះ គឺថាគាត់បានលើកឡើងហើយគឺថា គាត់មិនបានពិនិត្យមើលប្រតិចារឹកនេះវិញ លោកចៅក្រម ឡាវែន៍ ក៏បានសួរទៅនឹងឯកសារសង្ខេបនេះដែរ ហើយនេះគឺជាបទដ្ឋានអនុវត្តជាក់ស្ដែងនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល។ ដូច្នេះខ្ញុំគិតថា មិនគួរអនុញ្ញាតឲ្យមេធាវីការពារក្ដីសួរតទៅទៀត។

[១០:១៣:៥៦]

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធានខ្ញុំសូមជំទាស់ជាមួយនឹងសហព្រះរាជអាជ្ញារង។

វាអាចមានចំណុចខុសគ្នាខ្លះៗ អ្វីដែលយើងខ្ញុំព្រួយបារម្ភនោះគឺ អង្គហេតុដែលបានស៊ើបអង្កេតគឺថាដែលបានបំពេញនេះគឺថាការជួយជំរុញ ឬនាំមុខទៅដល់សាក្សី ហើយហេតុដូច្នេះឯងបានជាយើងមកទីនេះ។ ហើយយើងខ្ញុំសូមលើកឡើងថា សេចក្ដីសង្ខេបនេះគឺថា វាមិនពិតប្រាកដ មិនស៊ីសង្វាក់គ្នាទៅនឹងប្រតិចារឹកពេញលេញនោះទេ។ នេះឯងបានជា-- គឺយើងចង់បានៗ-- ដោយសារតែចម្លើយទាំងអស់នេះ គឺថាអ្នកស៊ើបអង្កេតជាអ្នកសួរ ហើយបានចម្លើយពីសាក្សី។ យើងខ្ញុំចង់សួរសាក្សី ដោយ

ផ្ទាល់ដើម្បីចង់ដឹងពីចម្លើយ ដែលអ្នកស៊ើបអង្កេតបានមកនេះ ថាតើគាត់ពាក់ព័ន្ធទៅនឹងអ្នកស៊ើបអង្កេតដោយរបៀបម៉េច? ពីព្រោះដោយសារគាត់មិនចេះ មិនយល់ភាសាអន្តរជាតិ ហើយយើងក៏មានចៅក្រមក៏មិនបានទទួលនូវឯកសារជាអត្ថបទ ជាប្រតិចារឹកជាភាសាខ្មែរឲ្យបានពេញលេញនោះដែរ។ ហើយខ្ញុំគ្រេកអរណាស់ដែលថាសហព្រះរាជអាជ្ញាចូលរួមជាមួយយើងខ្ញុំ ហើយដែលថាគួរផ្ដល់ប្រតិចារឹកហ្នឹង។ ខ្ញុំសូមអភ័យទោសចំពោះចំណុចនេះ ប៉ុន្តែយើងខ្ញុំសូមសង្កត់ធ្ងន់ថា យើងខ្ញុំមានការព្រួយបារម្ភទាក់ទងទៅនឹងសេចក្ដីសង្ខេប ដែលបានរៀបចំឡើង ខ្ញុំមិនដឹងថាអ្នកណាជាអ្នករៀបចំសង្ខេបនូវប្រតិចារឹកនេះទេ។ តែយើងបានដឹងថា ការសម្ភាសន៍ស្ដាប់ចម្លើយទាំងមូលជាភាសាខ្មែរនោះ គឺថាយើងបានដឹង។ សូមអរគុណលោកប្រធាន។

**លោក ញ៉ែម សំណាង៖**

សាក្សីសូមទៅបត់ជើងតូច លោកប្រធាន។ ចាំបន្តិចបាន។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹង អង្គជំនុំជម្រះសម្រេចថា ការជំទាស់របស់សហព្រះរាជអាជ្ញាមានប្រសិទ្ធភាព ហើយអង្គជំនុំជម្រះមិនអនុញ្ញាតឲ្យមេធាវីការពារក្ដី អៀង សារី បន្តការសួរដល់សាក្សីរូបនេះទៅទៀតទេ។ ហើយសូម អង្គជំនុំជម្រះសូមអរគុណចំពោះលោក ឡុង នរិន្ទ ដែលបានផ្ដល់សក្ខីកម្មជូនដល់អង្គជំនុំជម្រះក្នុងអំឡុងពេលប៉ុន្មានថ្ងៃកន្លងមកនេះ ដោយឃើញកិច្ចប្រឹងប្រែងរបស់លោកក្នុងការចូលរួមស្វែងរកការពិតនៅក្នុងរឿងក្ដីនេះ ហើយសូមអរគុណ។ ហើយលោកអនុញ្ញាតទៅចុះ ទៅណាទៅចុះ ឥឡូវនេះចប់ហើយ សូមអរគុណ។

[១០:១៧:១៩]

**លោក ឡុង នរិន្ទ៖**

បាទ។

**ប្រធានអង្គជំនុំ៖**

ហើយដល់ពេលសមល្មមនឹងសម្រាកដែរ ដូច្នេះអង្គជំនុំជម្រះប្រកាសសម្រាក២៥នាទីចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយ ខ្វះម្ភៃនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តដំណើរការសវនាការ ហើយជម្រាបថាសវនាការលើកក្រោយនេះ គឺយើងស្ដាប់ចម្លើយជនជាប់ចោទ។

*(សវនាការសម្រាកពីម៉ោង ១០:១៨ នាទី ដល់ម៉ោង ១០:៤០ នាទី)*

[១០:៤១:២៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ អម្បាញ់មិញនេះ អង្គជំនុំជម្រះបានជម្រាបហើយថា ជាបន្តនេះ គឺបន្តការសួរចម្លើយជនជាប់ចោទ។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំខ្លួនលោក នួន ជា មកកាន់ឈើរាងវង់ក្រចកសេះនៅពីមុខអង្គជំនុំជម្រះនេះ។

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខណៈដែលលោក នួន ជា កំពុងធ្វើដំណើរមកឈើរាងក្រចកសេះនេះ ខ្ញុំសូមបន្តទៅលើព្រឹកមិញនូវការផ្តល់សក្ខីកម្ម។ យើងគ្រាន់តែចង់បញ្ជាក់ឲ្យបានច្បាស់លាស់ថា ឯកសារ D93/3 គឺកិច្ចសម្ភាសន៍របស់លោក ឡុង នរិន្ទ និងឯកសារ D93/3.1 គឺបានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយ។ ឯកសារដែលយើងបានដាក់បង្ហាញនេះ គឺវាមិនមាននៅក្នុងបញ្ជីសម្រាប់ភាគីនោះទេ ឯកសារ D93/3 យើងឯកភាពជាមួយនឹងមេធាវីការពារក្តី ដូចដែលគាត់បានលើកឡើង។ ដូច្នេះហើយនៅឱកាសក្រោយនោះ គឺថាភាគីយើងឯកភាពថា ភាគីគួរតែទទួលបាននូវឯកសារទាំងឡាយ ទោះបីជាដាក់ក្រោយក៏ដោយ។

**លោក ម៉ៃខល កាណាវាស៖**

(គ្មានការបកប្រែ)

**ប្រធានអង្គជំនុំ៖**

លោក កាណាវាស លោកដូចជាអាចជារៀបចំនូវសណ្តាប់ធ្នាប់បន្តិចបានទេ។ អង្គជំនុំជម្រះសង្កេតឃើញថា លោកងើបនិយាយដោយសេរី មិនដែលបានសុំការអនុញ្ញាតពីប្រធានអង្គជំនុំជម្រះពេលណាឡើយ។

លោកត្រូវការនិយាយទៀតទេ? សូមអញ្ជើញ!

**លោក ម៉ៃខល កាណាវាស៖**

សូមអភ័យទោសអម្បាញ់មិញ។ សំណើសុំរបស់ខ្ញុំមានច្រើនជាងនេះទៅទៀត គឺខ្ញុំសុំឲ្យបក

កំណត់ហេតុប្រតិចារឹកទាំងស្រុងនោះជាភាសាអង់គ្លេស និងបារាំង។ ហេតុដូច្នេះហើយវាជាការត្រៀមសម្រាប់ចៅក្រមដែលគាត់ចង់ពិនិត្យមើលទៅលើកំណត់ហេតុទាំងមូលនោះ។ ដូច្នេះនៅពេលដែលយើងមានកំណត់ហេតុនោះ គឺវាអាចអនុញ្ញាតឲ្យភាគីចុចយកចំណុចដែលមិនស៊ីសង្វាក់គ្នា ហើយក៏អនុញ្ញាតឲ្យអង្គជំនុំជម្រះយល់ផងដែរថា អ្នកស៊ើបអង្កេតអាចជាការ-- អ្នកដែលលើកចម្លើយឲ្យសាក្សីឆ្លើយទៅតាមអ្វីដែលគាត់ចង់បាន។ នេះគឺជាអ្វីដែលយើងខ្ញុំក៏បានលើកនៅក្នុងសំណើកាលពីព្រឹកមិញផងដែរ។

សូមអរគុណ។

[១០:៤៤:៣៩]

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណនូវការកត់សម្គាល់របស់ភាគីទាំងពីរសហព្រះរាជអាជ្ញា និងមេធាវីការពារក្ដី អៀង សារី។ ហើយអង្គជំនុំជម្រះសូមជម្រាបអស់លោកថា អង្គជំនុំជម្រះនឹងចេញអនុស្សរណៈពាក់ព័ន្ធនឹងបញ្ហាទាំងនេះនៅក្នុងអំឡុងពេលឆាប់ៗខាងមុខនេះហើយ។

ជាកិច្ចបន្ត អង្គជំនុំជម្រះសូមប្រគល់វេទិកាជូនទៅសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរចំពោះលោក នួន ជា។ សូមអញ្ជើញ!

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** អរុណសួស្ដីលោក នួន ជា។ ជាបឋមខ្ញុំសូមសួរត្រឡប់ទៅអ្វីដែលបានឆ្លើយកាលពីម្សិលមិញ។ ហើយខ្ញុំចង់សួរថា ក្នុងពេលដែលលោកជាអនុលេខានៃបក្សកុម្មុយនីស្តកម្ពុជា តើលោកបានទទួលនូវប្រវត្តិរូបរបស់កម្មាភិបាល ហើយបានសួរចម្លើយទៅដល់កម្មាភិបាលទាំងអស់នោះពាក់ព័ន្ធទៅនឹងនិន្នាការរបស់ពួកគេ ដូចដែលលោក ឡុង នរិន្ទ បានឆ្លើយកាលពីម្សិលមិញដែរឬទេ?

[១០:៤៦:០៨]

**លោក នួន ជា៖**

**ឆ៖** សូមគោរពលោកប្រធាន។ ការងារនេះ មិនមែនការងាររបស់ខ្ញុំទេ ការសួរចម្លើយការអីៗនេះ ពីព្រោះខ្ញុំនៅខាងនីតិបញ្ញត្តិ អានេះជាផ្នែកខាងរដ្ឋបាល។

**ស៖** ថាតើគោលបំណងឲ្យកម្មាភិបាលបក្ស ឬសមាជិកបក្សសរសេរប្រវត្តិរូបសង្ខេបនោះ គឺមានគោលបំណងអ្វីដែរ?

**ឆ៖** តាមខ្ញុំដឹង ទាំងអស់គ្នាអ្នកណាចូលបក្សត្រូវសរសេរទាំងអស់ ដើម្បីដឹងប្រវត្តិរូប ហើយដើម្បីដឹងអត្តចរិត ដឹងទស្សនៈ ដឹងគោលជំហរ ដឹងសមត្ថភាព ដើម្បីបក្សជួយណែនាំតម្រែតម្រង់ អប់រំឲ្យត្រូវតាមទិសដៅដែលជាអត្តចរិតរបស់មនុស្សនោះ។

[១០:៤៧:៥១]

**សៈ** នៅពេលដែលលោកនិយាយនិន្នាការ តើមានន័យយ៉ាងម៉េចដែរ លោកមានន័យយ៉ាងម៉េចដែរ ពាក្យថា "និន្នាការ" នេះ?

**ឆ៖** ពាក្យថា "និន្នាការ" គឺអានេះ បើនិយាយឲ្យត្រង់ទៅគឺថា "ការនិយម" ទៅខាងណា និន្នាការទៅខាងឆ្វេង ឬនិន្នាការទៅខាងស្តាំ ឬនិន្នាការអព្យាក្រឹត អានេះន័យ "និន្នាការ" មានន័យយ៉ាងនេះ។

**សៈ** ថាតើប្រវត្តិរូបនោះ ត្រូវបានគេប្រើប្រាស់ដើម្បីកំណត់ថា សមាជិករបស់បក្សនោះ គឺមានវណ្ណៈត្រឹមត្រូវ តើពិតជាដូច្នោះដែរឬទេ?

**ឆ៖** ត្រង់នេះ ខ្ញុំសូមជម្រាបលោកប្រធាន អាចនឹងវែងបន្តិច ប៉ុន្តែខ្ញុំខំសរុបឲ្យខ្លី។ បញ្ហាចូលបក្សកុម្មុយនីស្តកម្ពុជាមានលក្ខខណ្ឌជ្រើសរើសយកធាតុរបស់វណ្ណៈ។ ក៏ប៉ុន្តែ មិនមែនវណ្ណៈនិយមទេ គឺយកទស្សនៈគោលជំហររបស់វណ្ណៈអធន គឺរបស់វណ្ណៈបដិវត្តន៍ ហ៊ានលះបង់ផលប្រយោជន៍ផ្ទាល់ខ្លួនដើម្បីផលប្រយោជន៍រួម។ មិនប្រើអំណាច មិនប្រើអាជ្ញា មិនស្រី មិនស្រា មិនលុយកាក់ មិនពាលាអាវាសែ។

**សៈ** ថាតើគេប្រើប្រវត្តិរូបដើម្បីកំណត់ថា សមាជិកបក្សនោះវាមានចំណងពាក់ព័ន្ធទៅនឹងខ្មាំងរបស់បក្សដែរឬទេ? តើពិតជាដូច្នោះដែរឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបលោកប្រធាន គោរពលោកប្រធាន! ខ្លះមាន ប៉ុន្តែភាគច្រើនគ្មាន។ បើអ្នកណាមាន យើងគោរពដាស់-- យើងតឿនរំឭកឲ្យគេលះបង់ចោលគំនិតនោះចោលចេញ ហើយមកកាន់យកនូវគំនិតរបស់វណ្ណៈបដិវត្តន៍វិញ។

**សៈ** តើខ្ញុំឮលោកនិយាយដូច្នេះដែរឬទេ ថាសមាជិកបក្សទាំងអស់ គឺតម្រូវឲ្យសរសេរប្រវត្តិរូប តើពិតជាដូច្នោះដែរឬទេ?

**ឆ៖** ពិតដូច្នោះមែន។

**សៈ** ដូច្នេះការតម្រូវឲ្យសរសេរប្រវត្តិរូបនៅពេលចូលជាសមាជិកបក្សនោះ គឺធ្វើឡើងមុនថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥។ ប្រសិនបើដូច្នោះមែន តើនៅពេលណាដែលលោកចាប់ផ្ដើមរៀបចំឲ្យគេសរសេរប្រវត្តិរូបនោះ?

**ជះ** តាមខ្ញុំចាំ សរសេរប្រវត្តិរូបតាំងពីថ្ងៃសុំចូលបក្ស។

**សៈ** ខ្ញុំសូមបញ្ជាក់ថា នេះការតម្រូវឲ្យសរសេរប្រវត្តិរូបនេះ គឺជាទម្លាប់ដែលគេឲ្យធ្វើឡើងតាំងពីទសវត្សរ៍ទី៦០មកម្ល៉េះ។ តើពិតជាដូច្នោះដែរឬទេ?

[១០:៥២:៣១]

**ជះ** តាមខ្ញុំចាំ តាំងពីមុនសតវត្សរ៍ (ស៊ីក) ៦០មកម្ល៉េះ។

**សៈ** សូមអរគុណលោក នួន ជា។ នៅពេលនេះខ្ញុំសូមសួរសំណួរមួយចំនួនតូចទៀត ពាក់ព័ន្ធទៅនឹងលក្ខន្តិកៈរបស់បក្ស ដែលចៅក្រម ខាតវ៉ាយថ៍ បានដាក់នៅចំពោះមុខអង្គជំនុំជម្រះ។ ឯកសារនេះមានលេខ ឯកសារ D366/7.1.187 ខ្ញុំមិនដឹងថាតើលោកមានលក្ខន្តិកៈបក្សនេះមួយច្បាប់នៅចំពោះមុខដែរឬទេ? បើសិនជាអត់មានទេ ខ្ញុំសូមផ្ដល់ជូនលោក។

**ជះ** អត់មានទេ។

**សៈ** នៅពេលនេះខ្ញុំសូមឲ្យលោកមើលលេខ ERN ជាភាសាខ្មែរ 00442268, ERN ជាភាសាអង់គ្លេស គឺ00184037 បារាំងលេខ ERN គឺ00292926។

**លោក ឌេល លីសាក់៖**

លោកប្រធានជាទីគោរពខ្ញុំសូមអនុញ្ញាតដាក់ឯកសារនេះជាភាសាខ្មែរត្រង់លេខ ERN នោះនៅលើអេក្រង់ ដើម្បីឲ្យតុលាការ និងជនជាប់ចោទបានឃើញ។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត។ សូមអញ្ជើញ!

**សួរដោយលោក ឌេល លីសាក់៖**

**សៈ** ខ្ញុំចង់សួរលោកមួយចំនួនពាក់ព័ន្ធទៅនឹងមាត្រា៦ នៃលក្ខន្តិកៈបក្សចែងដូចតទៅ។ ខ្ញុំដកស្រង់សម្ដី៖ “បក្សកុម្មុយនីស្តកម្ពុជាប្រកាន់យកគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្ដុំ ធ្វើជាមូលដ្ឋានចាត់តាំងរបស់ខ្លួន”។ ដូច្នេះ សំណួរទីមួយរបស់ខ្ញុំគឺថា គោលការណ៍ប្រជាធិបតេយ្យប្រមូលផ្ដុំនេះ គឺជាអ្វីដែរ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** សូមគោរពលោកប្រធាន! ដែលហៅថា គោលការណ៍ប្រជាធិបតេយ្យប្រមូលផ្ដុំនេះ គឺប្រមូលផ្ដុំគំនិត ទស្សនៈ ការយល់ដឹង តាំងពីបក្ខជនរហូតដល់មជ្ឈិមបក្ស ហើយប្រជាធិបតេយ្យប្រមូលផ្ដុំនេះអនុវត្តទូទៅ សូម្បីតែសាខាបក្សដែលនៅតាមភូមិ ដែលនៅតាមឃុំ ក៏អនុវត្តនូវប្រជាធិបតេយ្យប្រមូលផ្ដុំនេះដែរ គឺយកមតិរបស់គ្រប់បក្សជនទាំងអស់ ហើយលេខាបក្សសរុប បើលេខាបក្សសរុបមិនត្រូវ បក្សជនមានសិទ្ធិបន្ថែម បន្ថយ ឬក៏តវ៉ា។

[១០:៥៧:០០]

**ស៖** ខ្ញុំក៏ចង់ឱ្យលោកមើលមាត្រា៦(២) ដែលក្នុងនោះចែងថា ខ្ញុំសូមដកស្រង់សម្ដី “គ្រប់ការសម្រេចផ្សេងៗរបស់បក្សត្រូវធ្វើឡើងដោយសមូហភាព”។ ដូច្នេះគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្ដុំ គឺជាផ្នែកមួយនៃប្រជាធិបតេយ្យប្រមូលផ្ដុំដែរឬទេ?

**ឆ៖** សូមជម្រាបលោកប្រធាន! មាត្រា២ គ្រប់ៗការសម្រេចផ្សេងរបស់បក្សត្រូវធ្វើឡើងដោយសមូហភាព បានន័យថា ការសម្រេចអ្វីៗទាំងអស់របស់បក្សត្រូវរួមគ្នាសម្រេច មិនមែនបុគ្គលសម្រេចទេ។

**ស៖** ដូច្នេះ សេចក្ដីសម្រេចជាសមូហភាពនេះ តើជាផ្នែកមួយនៃគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្ដុំ ហើយវាផ្នែកមួយនៃលក្ខន្តិកៈដែលត្រូវបានគេអនុម័តនៅដើមទសវត្សរ៍ទី៦០ តើមែនដែរឬទេ?

**ឆ៖** សូមគោរពលោកប្រធាន! ប្រជាធិបតេយ្យប្រមូលផ្ដុំនេះ ក៏វាផ្នែកមួយនៃសមូហភាពដឹកនាំដែរ។ ឯសមូហភាពដឹកនាំ ក៏វាជាផ្នែកមួយនៃប្រជាធិបតេយ្យប្រមូលផ្ដុំដែរ។

**ស៖** អ្វីដែលខ្ញុំសួរនោះ ថាតើគោលការណ៍នេះគឺជាគោលការណ៍មួយ ដែលត្រូវបានអនុម័ត និងទទួលស្គាល់នៅក្នុងមហាសន្និបាតបក្សក្នុងទសវត្សរ៍ទី៦០ តើមែនដែរឬទេ?

**ឆ៖** គោលការណ៍នេះ សម្រេចនិងអនុវត្តនៅគ្រប់សន្និបាតបក្ស គឺបក្សប្រកាន់យកនូវគោលការណ៍នេះជាស្ថាពរ។

[១១:០០:០៥]

**ស៖** ដូច្នេះ គឺវាជាគោលការណ៍ដែលមានប្រសិទ្ធភាព ទោះបីជាក្នុងពេលដែលលោកជាអនុលេខាបក្សក៏ដោយ តើពិតជាត្រឹមត្រូវដែរឬទេ?

**ឆ៖** សូមជម្រាបលោកប្រធាន! ត្រឹមត្រូវ។

**ស៖** ហើយគោលការណ៍នេះ ក៏ជាគោលការណ៍ដែលគេយកទៅអនុវត្តសម្រាប់សេចក្តីសម្រេចរបស់មជ្ឈិមបក្ស និងគណៈកម្មាធិការអចិន្ត្រៃយ៍ផងដែរ។ តើពិតជាដូច្នោះដែរឬទេ?

**ឆ៖** គ្រប់-- សូមគោរពលោកប្រធាន គ្រប់ការចាត់តាំងរបស់បក្សត្រូវអនុវត្តតាមគោលការណ៍នេះទាំងអស់។ ក៏ប៉ុន្តែ ខ្ញុំសូមជម្រាបថា វាមិនមែនបានមួយភាគរយទេ ចួនកាលវាមានខ្វះមានចន្លោះខ្លះដែរ ស៊ីសងទៅនឹងបុគ្គលអ្នកអនុវត្ត។ ខ្ញុំសូមលើកឧទាហរណ៍ឲ្យច្បាស់ បើអ្នកអនុវត្តនោះមានភាពបុគ្គលនិយម គឺបានសេចក្តីថា "អាត្មានិយម" ឬបើនិយាយថា ខ្ញុំសូមប្រើភាសាសាមញ្ញទៅចុះក្នុងតុលាការខ្ញុំសូមអនុញ្ញាត "អញនិយម" ស្អីក៏ "អញ" បើមាន "អញនិយម" ហើយ បើមាន "អញ" វាមាន "អញនិយម" បើមាន "អញនិយម" វាមាន "កម្មសិទ្ធិរបស់អញ" បើមាន "កម្មសិទ្ធិរបស់អញ" "អញអនុវត្តតាមគំនិតរបស់អញ"។ អានេះក៏មាន។ ត្រង់ណេះហើយដែលបក្សត្រូវខំអប់រំ កម្ចាត់នូវទស្សនៈ "អញនិយម" ហើយកសាងនូវទស្សនៈ "សមូហភាពនិយម"។

[១១:០២:១៥]

**ស៖** តើគោលការណ៍ សេចក្តីសម្រេចសមូហភាពនេះ គឺគេត្រូវអនុវត្តនៅក្នុងពេលប្រជុំរបស់គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ ដែលលោកបានចូលរួមប្រជុំនោះដែរឬទេ?

**ឆ៖** អនុវត្ត។ សូមគោរពលោកប្រធាន! អនុវត្តទាំងអស់។

**ស៖** តើលោកអាចពន្យល់និងរៀបរាប់ជូនអង្គសវនាការដែរឬទេ អំពីដំណើរការរបស់គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ តើគេធ្វើសេចក្តីសម្រេចសមូហភាពនោះ តាមរបៀបណា? ហើយគេធ្វើយ៉ាងម៉េច?

**ឆ៖** សូមជម្រាបលោកប្រធាន! "សមូហភាព" បានន័យថា ប្រជុំរួមគ្នាទាំងអស់ មានមតិជាប្រជាធិបតេយ្យប្រមូលផ្តុំ ប្រជុំអីក៏អ៊ីចឹងដែរ។ មិនមែនត្រឹមតែប្រជុំមជ្ឈិម ប្រជុំអចិន្ត្រៃយ៍ទេ ហើយលេខាអចិន្ត្រៃយ៍ ឬលេខាមជ្ឈិមបក្សជាអ្នកសរុប បើកាលណាសរុបហើយមិនពេញចិត្តអង្គប្រជុំៗមានសិទ្ធិដើម្បីមានមតិតទៅទៀត ឬមានមតិតរ៉ាវហូតដល់កាលណាឯកភាពគ្នាជាផ្លុងមួយ ជាសមូហភាពឯកភាពគ្នាជាផ្លុងមួយ ទើបចាត់ទុកជាបានការ។ បើមិនទាន់ឯកភាពគ្នាទេ ពិភាក្សាគ្នាតទៅទៀត។ សូមចប់។

[១១:០៤:១៧]

**ស៖** តើនេះជាការត្រឹមត្រូវទេ ដែលថារាល់សេចក្តីសម្រេចរបស់គណៈមជ្ឈិម និងគណៈ

អចិន្ត្រៃយ៍នៅក្នុងអំឡុងពេលដែលលោកជាអនុលេខាបក្ស ដែលទាក់ទងទៅនឹងដំណើរការនៃការសម្រេចជា សម្ហភាពនេះ សូមលោករៀបរាប់បន្តិចមក?

**ឆ៖** លោកប្រធាន ខ្ញុំមិនយល់សំណួរ សូមសួរម្តងទៀត។

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញាតាំងសំណួរសាជាថ្មីមក។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** តើការអនុវត្តដែលលោករៀបរាប់អំពីការឈានទៅដល់ការទទួលបានការសម្រេចជាសមូហភាព នេះគឺជាការអនុវត្តដែលអនុវត្តដោយគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ក្នុងអំឡុងពេលដែលលោកជាអនុលេខាបក្ស។ តើនេះជាការត្រឹមត្រូវដែរឬទេ?

**ឆ៖** មិនមែនតែក្នុងពេលដែលខ្ញុំធ្វើជាអនុលេខាទេ ទាំងអស់ គឺថាគ្រប់កាលៈទេសៈទាំងអស់។ អនុវត្តនូវមាគ៌ានេះទាំងអស់ជាទូទៅ។ គោលការណ៍នេះ ជាគោលការណ៍សកលរបស់បក្សកុម្មុយនីស្តកម្ពុជា។ អនុវត្តតាំងពីសាខាបក្សរហូតដល់មជ្ឈិមបក្ស។ មិនមែនតែក្នុងអំឡុងដែលខ្ញុំធ្វើអនុលេខាទេ។

**ស៖** សូមអរគុណ ដែលលោកបានឆ្លើយបញ្ជាក់នេះ លោក នួន ជា។ ខ្ញុំចង់បន្តសំណួរទៅក្រោយបន្តិចទាក់ទងទៅនឹងការ លោកទទួលបានការបណ្តុះបណ្តាលនៅវៀតណាម ចន្លោះពីឆ្នាំ១៩៥១ ដល់៥៣ តើលោកអាចជម្រាបជូនថាទីតាំង ឬក៏សាលាណាខ្លះដែលលោកបានទទួលបានការបណ្តុះបណ្តាលនៅអំឡុងពេលចន្លោះពីឆ្នាំ៥១ ដល់៥៣ នេះ?

[១១:០៦:៣២]

**ឆ៖** សូមគោរពលោកប្រធាន! ៥១ ខ្ញុំមិនទាន់ទៅវៀតណាម ទេ។ ៥២ ក៏នៅ ទើបទៅ៥៣។ ឯការទៅរៀនសូត្រនោះ គ្មាន មិនមាន-- រៀននៅក្នុងព្រៃ មានសាលាធ្វើអំពីស្លឹក មិនមែនមានសាលារៀនអីធំដុំជាឈើជាអីទេ។ ឯការរៀននេះ ខ្ញុំសូមជម្រាប គឺមានកម្មាភិបាលវៀតណាម ដែលធ្លាប់ទៅរៀននៅស្រុកចិន មកណែនាំអំពីវិធីរៀនសូត្រតាមរៀបថ្មី។ គឺមួយ ចែកឯកសារឲ្យបក្ខជនម្នាក់ៗពិនិត្យពិចារណា។

ខ ទីពីរ មកពិភាក្សាគ្នា។ ខទីបី ពាក់ព័ន្ធខ្លួនឯង តើក្នុងឯកសារហ្នឹង មានអ្វីដែលនិយាយដល់ខ្លួនឯងទេ។ ឧទាហរណ៍ ដូចជាខ្លួនឯងនេះ បក្ខជននេះ សេរីនិយម អាត្មានិយម បុគ្គលនិយម មិនគោរពការចាត់តាំង មិនគោរពថ្នាក់ដឹកនាំ អីៗអស់នេះ យកមកពាក់ព័ន្ធនិយាយឲ្យអង្គប្រជុំស្តាប់សិន រួចទៅ

អង្គប្រជុំដេញដោយសាកសួរ ហើយសរុប។ ក៏ប៉ុន្តែតាមខ្ញុំសង្កេត វាមិនមែនចេះតែបរិសុទ្ធទាំងអស់ទេ ពីព្រោះបក្ខជនខ្លះ ស្មោះត្រង់នឹងការរៀនសូត្រ គឺបញ្ចេញឲ្យអស់នូវទស្សនៈគោលជំហរខុសឆ្គងរបស់ខ្លួន ដើម្បីឲ្យសមូហភាពជួយ ប៉ុន្តែមានបក្ខជនខ្លះ មានសតិអារម្មណ៍ពីរ គឺសតិអារម្មណ៍មួយចំហសម្រាប់និយាយឲ្យអង្គប្រជុំស្ដាប់។ អាហ្នឹង គឺលើកតែស្រាលៗទេ។

[១១:០៩:៤៨]

ឯសតិអារម្មណ៍សម្ងាត់ ឧទាហរណ៍ ដូចជារឿងខូចកាចនឹងស្រីញី រឿងពុករលួយ លក់កៅស៊ូ ឬក៏លក់អីៗរបស់បក្ស អាហ្នឹងគេមិនដែលនិយាយទេ ទាល់តែដេញដោលសាកសួរសាចុះសាឡើងជួនណាមួយកន្លះខែ។

ដូច្នោះការរៀនសូត្រនេះ ដូចជាលោកបានសួរអ៊ីចឹង គឺថាមិនមែនជាបញ្ហាប្រយុទ្ធ ជាការប្រយុទ្ធខាងផ្នែកសតិអារម្មណ៍។ បើប្រយុទ្ធខាងយោធាណា! តាមខ្ញុំសង្កេតមើលវាស្រួលទេ ពិតមែនតែមានស្លាប់មានរស់។ ប៉ុន្តែដល់ប្រយុទ្ធរួចហើយ មកដេកលក់ ក៏ប៉ុន្តែការរៀនសូត្រប្រយុទ្ធខាងសតិអារម្មណ៍ពិបាកណាស់ មិនមែនងាយទេ។ តែនិយាយមិននិយាយ? ស្មោះត្រង់ចំពោះខ្លួនឯង ឬក៏មិនស្មោះត្រង់? ប៉ាននិយាយទេ ឬក៏មិនប៉ាននិយាយ? ឧទាហរណ៍ដូចជារឿងជាពិសេស រឿងស្រីញី ស៊ីផឹក លុយកាក់ មិនអនុវត្តមាគ៌ានយោបាយរបស់បក្ស ឬក៏ទាក់ទងជាមួយខ្មាំងក្បត់បក្ស។ បញ្ហានេះ ពិបាកឆ្អឹះកកាយណាស់ ទាល់តែជីកឲ្យជ្រៅ។ ក្នុងភាសារៀនសូត្រគេហៅថា "ជីកឲ្យជ្រៅ រកឲ្យឃើញបញ្ហាឲ្យអស់ឫស អស់គល់"។ នេះខ្ញុំសូមជម្រាប អនុញ្ញាតវែងបន្តិចដើម្បីឲ្យយល់។

[១១:១១:៥០]

**ស៖** អ៊ីចឹងច្បាស់ហើយថា លោកបានអញ្ជើញទៅវៀតណាមនៅឆ្នាំ៥១ ប៉ុន្តែលោកមិនបានចាប់ផ្ដើមបានរៀនសូត្រទេ រហូតដល់ឆ្នាំ៥៣ ទើបលោកបានទទួលការបណ្ដុះបណ្ដាល តើនេះត្រឹមត្រូវដែរឬទេ?

**ឆ៖** តាមខ្ញុំចាំ ត្រឹមត្រូវ។

**ស៖** តើលោកមានបានរៀនសូត្រអំពីសង្គ្រាមឧទ្ទាមនៅប្រទេសវៀតណាមភាគកណ្ដាលដែរឬទេ?

**ឆ៖** លោកប្រធាន គោរពលោកប្រធាន! ខ្ញុំចង់សួរបញ្ជាក់យ៉ាងម៉េចហៅថាសង្គ្រាមឧទ្ទាម? ខ្ញុំមិនដែលឮ?

**ស៖** តើលោកមានបានជម្រាបលោក ថេត សម្បត្តិ ថាលោកបានរៀនសូត្រអំពីសង្គ្រាមឈ្លប នៅភាគកណ្តាលនៃវៀតណាម ដែលក្នុងនេះមានការចូលរួមរៀនសូត្រពីបណ្តាមេដឹកនាំខ្មែរឥស្សរៈ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បើសង្គ្រាមឈ្លបមាន ប៉ុន្តែបើសង្គ្រាមខទ្មាមមិនដែលមានទេ។ ការរៀនសង្គ្រាមឈ្លបនេះ ខ្ញុំមិនដែលបានរៀនសូត្រជាខ្សែសង្វាក់អីទេ។ ក៏ប៉ុន្តែស្តាប់អ្នកដែលគេទៅធ្វើសង្គ្រាម គេនិយាយអំពីគោលការណ៍នៃសង្គ្រាមឈ្លប។ សង្គ្រាមឈ្លបនេះ គឺជាសង្គ្រាមរបស់ប្រជាជន ហើយគេមានគោលការណ៍របស់គេ។

**លោក នួន ជា៖**

បើលោកប្រធានអនុញ្ញាត ខ្ញុំនឹងនិយាយបន្ថែមបន្តិចទៀតអំពីសង្គ្រាមឈ្លបនេះ វាវែងណាស់។

[១១:១៥:០៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ! អង្គជំនុំជម្រះអនុញ្ញាត។

**លោក នួន ជា៖**

**ឆ៖** ខ ទីមួយ យ៉ាងម៉េចហៅថាសង្គ្រាមឈ្លប គឺប្រជាជនទាំងអស់ ក្មេងចាស់ ប្រុសស្រី ធ្វើសង្គ្រាមតាមគ្រប់រូបភាពបែបយ៉ាងទាំងអស់។ គោលការណ៍សង្គ្រាមឈ្លបទីមួយ គឺយកតូចវ៉ៃធំ ពីព្រោះវាឈ្លប មិនវ៉ៃទល់មុខ យកតិចវ៉ៃច្រើន។ យកគុណភាពវ៉ៃបរិមាណ វ៉ៃរហ័ស ឈ្នះរហ័ស ប្រមូលសម្ភារៈសឹករហ័ស ហើយដករហ័ស។ នេះជាគោលការណ៍ធំៗរបស់សង្គ្រាមឈ្លបដែលខ្ញុំបានធ្លាប់ឮមក ដែលធ្លាប់ស្តាប់មក ប៉ុន្តែខ្ញុំមិនដែលចូលរៀនសាលាសង្គ្រាមឈ្លបទេ ពីព្រោះដូចជាខ្ញុំបានជម្រាបហើយ ខ្ញុំមិនដែលបានចូលរៀនសាលាយោធាទេ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** តើ--

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី!

**លោក សុន អរុណ៖**

សូមគោរពលោកប្រធាន! ខ្ញុំសូមជំទាស់នឹងលោកព្រះរាជអាជ្ញា ដែលលោកព្រះរាជអាជ្ញាយក

ឯកសាររបស់ ថេត សម្បត្តិ យកមកនិយាយនៅពេលនេះ។ ពីម្សិលមិញខ្ញុំបានជំទាស់ម្តងរួចទៅហើយ សៀវភៅរបស់ ថេត សម្បត្តិ ដែលព្រះរាជអាជ្ញាបានបង្ហាញនោះមិនយកជាការបានទេ ព្រោះអី? ភាសាមានតែមួយ គឺអង់គ្លេស ខ្មែរអត់មាន បារាំងអត់មាន។ ហើយលោកយកមកប្រើជាផ្លូវការ ហើយមិនដឹងសៀវភៅហ្នឹងមកពីណាទៅណាទេ គេដាក់លក់ក្នុងផ្សារលោកយកមកប្រើផ្លូវការ ខ្ញុំមិនទទួលស្គាល់។ ម្ល៉ោះហើយខ្ញុំសូមបដិសេធម្តងទៀត ចំពោះព្រះរាជអាជ្ញាកុំឲ្យយកសៀវភៅរបស់ ថេត សម្បត្តិ មកប្រើសាជាថ្មី។

**ប្រធានអង្គជំនុំ៖**

អរគុណរបស់មេធាវីការពារក្តីរបស់ នួន ជា មានប្រសិទ្ធភាព សហព្រះរាជអាជ្ញាមិនអាចយកសៀវភៅអ្នកនិពន្ធរបស់ ថេត សម្បត្តិ មកដេញដោលបានទេ។ ពីព្រោះអង្គជំនុំជម្រះមិនទាន់បានដាក់សម្រេចដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅឡើយទេ លើសៀវភៅនេះ។ ពិតមែនតែការសុំមែន ប៉ុន្តែមិនទាន់បានដាក់ទេ កាលពីលើកមុន គឺលោកស្រីចៅក្រមបានជម្រាបជូនលោកហើយថា ប្រសិនបើលោកគ្រាន់តែលើកអំពីទំនាក់ទំនងបុគ្គល ដើម្បីបញ្ជាក់អំពីទំនាក់ទំនងបុគ្គល គឺមិនមាននូវការទាស់អីទេ។ ប៉ុន្តែ បើសិនជាសួរអំពីខ្លឹមសារនៃចេញអំពីសៀវភៅនិពន្ធនោះ គឺមិនទាន់អនុញ្ញាតទេ លុះត្រាតែអង្គជំនុំជម្រះសម្រេច ចំពោះឯកសារដែលត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះជាមុនសិន។

[១១:១៧:២៨]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសួរសំណួរបន្តទៅទៀត ប៉ុន្តែខ្ញុំមិនលើកឡើងអ្វីដែលបានហាមឃាត់នេះទេ។ ខ្ញុំចង់ជម្រាបជូនទៅមេធាវីការពារក្តីថា យើងមិនបានទទួលសៀវភៅនេះពីហាងលក់សៀវភៅណាមួយទេ។ ខ្ញុំបានទៅបណ្ណាល័យនៅវិមានឯករាជ្យ ហើយខាងបណ្ណាល័យរបស់យើងនេះ អ.វ.ត.ក គឺបានស្នើសុំទិញមកប៉ុន្មានខែមកហើយ ប៉ុន្តែខាងមេធាវីការពារក្តីមិនបានមើលថា ដឹងថាឯកសារហ្នឹងមាននៅក្នុងបណ្ណាល័យដែលបានដាក់ចូលទៅក្នុងសំណុំរឿងនោះទេ។ ប៉ុន្តែ ខ្ញុំនឹងចៀសវាងចំណុចនេះ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោក នួន ជា បណ្តាសាលារៀនទាំងឡាយដែលលោកបានចូលរួមរៀនសូត្រនៅក្នុងប្រទេសវៀតណាមនោះ តើលោកទទួលបានការបណ្តុះបណ្តាលនោះជាភាសាវៀតណាម មែនឬទេ?

**លោក នួន ជា៖**

**ជ៖** សូមជម្រាបលោកប្រធាន ជាភាសាខ្មែរ ពីព្រោះអ្នកដែលទៅរៀននោះចេះវៀតណាមខ្លះ ក៏ប៉ុន្តែភាគច្រើនវៀតណាម គេឧទ្ទេសនាម ប៉ុន្តែយើងមកពិភាក្សាគ្នាក្នុងចំណោមសិក្ខាកាមខ្មែរជាភាសាខ្មែរ។

**ស៖** នៅពេលដែលលោកចូលរួមការរៀនសូត្រនោះ តើលោកចេះអាន ឬក៏ចេះនិយាយភាសាវៀតណាមបានដែរឬទេ?

**ជ៖** សូមជម្រាបលោកប្រធាន ខ្ញុំចេះនិយាយតិចៗ ចេះអានតិចៗ។ ក៏ប៉ុន្តែជាភាសានយោបាយយល់បានខ្លះ ក៏ប៉ុន្តែភាសាធម្មតាគេហៅថាជាភាសាផ្សារ ខ្ញុំមិនសូវយល់ទេ។

**ស៖** តើនៅពេលណាដែលលោកចាប់ផ្តើមនិយាយភាសាវៀតណាម លោក នួន ជា?

[១១:២០:០៥]

**ជ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនចាំទេ។ ខ្ញុំជម្រាបអ៊ីចេះ ពេលដែលមកធ្វើបដិវត្តន៍ឆ្នាំ ១៩៥១ នៅមន្ទីរការិយាល័យទាំងអស់ មានខ្មែរមានវៀតណាមធ្វើការជាមួយគ្នា។ វៀតណាមរៀនភាសាខ្មែរ ខ្មែររៀនភាសាវៀតណាម។ ព្រឹកព្រហាមឡើង ក្រោយពីធ្វើភារកិច្ចស្អូនខ្លួនហើយ រៀនសូត្រមួយម៉ោង។ អ្នកណាចង់រៀនភាសាវៀតណាមរៀនទៅ អ្នកណាវៀតណាមណាចង់រៀនភាសាខ្មែរក៏រៀនទៅ។

**ស៖** តើលោកនៅចាំទេ នៅពេលលោកវិលត្រឡប់មកពីវៀតណាមមកកាន់ប្រទេសកម្ពុជាវិញ ថាតើការវិលត្រឡប់មកវិញនេះ គឺក្រោយពីកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ ឆ្នាំ១៩៥៤ ឬក៏យ៉ាងណាដែរ?

[១១:២១:២៨]

**ជ៖** សូមជម្រាបលោកប្រធាន ពេលនោះតាមខ្ញុំចាំដូចជាសម្រេចកិច្ចព្រមព្រៀងហ្សឺណែវហើយ។

**ស៖** នៅ-- ហើយនៅក្នុងចន្លោះពីឆ្នាំ៥៤ ទៅដល់ ៥៥ ក្រោយពីលោកវិលត្រឡប់មកពីប្រទេសវៀតណាមវិញ។ តើពេលនោះលោកត្រូវបានតែងតាំងជាអនុលេខា-- ជាលេខាគណៈកម្មាធិការបដិវត្តន៍ក្រុងភ្នំពេញមែនឬទេ?

**ជ៖** មិនមែនទេ។ អង្កាល់នោះ ខ្ញុំត្រឡប់មកវិញមានគេចាត់តាំងជាសាខា ជាគណបក្សភ្នំពេញ ហើយគឺ វន វ៉េត ឈ្មោះ វន វ៉េត ឯខ្ញុំនេះគ្មានភារកិច្ចអីឲ្យជាប់លាប់ទេ គ្រាន់តែជួយពីរនាក់ អង្កាល់

នោះជួយពីរនាក់ សាឡុត ស ជួយការងារនេះនោះ បន្តិចបន្តួចឲ្យលោកតា ទូ សាមុត ពីព្រោះលោកតា ទូ សាមុត អង្គាល់នោះតាមខ្ញុំចាំដូចជាគាត់គណៈមជ្ឈិម ហើយគ្មាននរណាជួយគាត់-- ជួយធ្វើការគាត់ បានជាឲ្យខ្ញុំហើយនិង សាឡុត ស នេះជួយធ្វើការ។ ដូចជាខ្ញុំបានជម្រាបម្តងឲ្យហើយ ខ្ញុំមិនបាច់ជម្រាបទៀតក៏បានដែរ។ កុំឲ្យវាងដែលៗខាតពេល។

**ស៖** ហេតុអ្វីបានជាលោកមិនជម្រាបជូនអង្គជំនុំជម្រះថា លោកបានជួបលោក សាឡុត ស ក្រោយមកគឺថា សាឡុត ស នេះបានដាក់ឈ្មោះថា ឈ្មោះ ប៉ុល ពត តាំងពីមុននោះមក?

**ឆ៖** តាមខ្ញុំចាំ-- ជម្រាបលោកប្រធាន! តាមខ្ញុំចាំខ្ញុំបានជម្រាបហើយតើ។ សាឡុត ស ឬក៏ ប៉ុល ពត ហៅ ប៉ុល ពត។

**ស៖** លោកប្រធាន ខ្ញុំមិនបានចាំចំណុចនេះទេ ប៉ុន្តែខ្ញុំចង់សួរទៅសាក្សីថា ពេលណាដែលគាត់ជួប សាឡុត ស ដើម្បីឲ្យពន្យល់អំពីចំណុចនេះ?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំជួប សាឡុត ស រវាងឆ្នាំ១៩៥៤-៥៥។

[១១:២៥:១៥]

**ស៖** ថាតើអ្នកណាគេដែលគេឧទ្ទេសនាមលោកឲ្យស្គាល់ សាឡុត ស?

**ឆ៖** សូមជម្រាបលោកប្រធាន! អ្នកដែលឧទ្ទេសនាមខ្ញុំឲ្យស្គាល់ សាឡុត ស នោះឈ្មោះ ចាន់ សាម៉ន ហៅ ខ្មៅ។ គេធ្វើការនៅក្រុងភ្នំពេញមុន។

**ស៖** តើលោក ចាន់ សាម៉ន មានតួនាទីអ្វីនៅក្នុងបក្សនៅពេលនោះ នៅពេលដែលគាត់ឧទ្ទេសនាមលោកឲ្យស្គាល់ សាឡុត ស?

**ឆ៖** តាមខ្ញុំចាំ សូមជម្រាបលោកប្រធាន! ចាន់ សាម៉ន នេះគាត់ធ្វើការជាសមាជិកបក្សក្រុង។

**ស៖** តើលោក និង សាឡុត ស ធ្វើការជាមួយគ្នាដែរឬទេ នៅក្នុងបក្សក្រុងហ្នឹង?

[១១:២៦:៤៦]

**ឆ៖** សូមជម្រាបលោកប្រធាន! ខ្ញុំ និង សាឡុត ស ធ្វើការជាមួយគ្នាជាអ្នកជំនួយការលោកតា ទូ សាមុត។ មិនទាន់មានការចាត់តាំងអីទេ។

**ស៖** ដើម្បីឲ្យច្បាស់នោះ តើមាននៅពេលណាមួយដែលគេតែងតាំងលោកជាលេខាបក្សក្រុងដែរឬទេ?

**ឆ៖** តាមខ្ញុំចាំ គេអត់តាំងខ្ញុំជាលេខាបក្សក្រុងទេ។

**ស៖** តើលោក និង សាឡុត ស ក្រោយមកមានការចូលរួមពី អៀង សារី ដើម្បីធ្វើការរួមគ្នានៅក្នុងបក្សក្រុងដែរឬទេ?

[១១:២៨:០០]

**ឆ៖** សូមជម្រាបលោកប្រធាន! ដំបូងឡើយ ខ្ញុំមិនដែលស្គាល់ អៀង សារី ទេ។ ខ្ញុំស្គាល់តែខ្លួនខ្ញុំ ហើយនិង សាឡុត ស ហើយនិងលោកតា ទូ សាមុត ប៉ុណ្ណឹងទេ។ ឯ អៀង សារី ខ្ញុំគ្រាន់តែឮឈ្មោះ ប៉ុន្តែខ្ញុំមិនដែលជួបគាត់ ហើយមិនដែលស្គាល់គាត់ទេ។

**ស៖** តើលោក អៀង សារី បានមកចូលរួមជាមួយនឹងលោក និងលោក ប៉ុល ពត ហើយបានចូលរួមជាមួយកម្មាភិបាលផ្សេងទៀតដែរឬទេ មកធ្វើការនៅក្នុងបក្សក្រុង ក្រោយពីគាត់វិលត្រឡប់មកពីបារាំងវិញនៅក្នុងឆ្នាំ១៩៥៧?

**ឆ៖** សូមជម្រាបលោកប្រធាន! ដូចជាខ្ញុំបានជម្រាបអ៊ីចឹង គឺថាខ្ញុំមិនដែលស្គាល់គាត់ទេ ធ្លាប់ឮតែឈ្មោះ។ ក៏ប៉ុន្តែដល់ការរៀបចំ អំ អង្កាល់នោះ ស៊ីវ ហេង ធ្វើលេខាបក្ស អំ ធ្វើលេខាមជ្ឈិមបក្ស។ ដល់ ស៊ីវ ហេង នេះចេញពីបក្សទៅសារភាព លន់ នល់ ឆ្នាំ១៩៥៩ ដល់អ៊ីចឹងត្រូវរៀបចំបក្សឡើងវិញ ពីព្រោះវាបក្ស វាគ្មានលេខា រៀបចំអ្នកណា គឺមានតែលោកតា ទូ សាមុត ដែលគាត់ជាចាស់ទុំ ក្នុងឆ្នាំ ១៩៦០, ៦១ អំ ៦០ៗ អត់ទោស ឆ្នាំ១៩៦០។ ដល់ឆ្នាំ១៩៦១ បក្សធ្វើមហាសន្និបាតបក្សលើកទី១ នៅនឹងរទេះភ្លើង ន៎ៃ កន្លែងធ្វើការរទេះភ្លើង ដែលមាន អ៊ុក សុគន្ធ ជាម្ចាស់ផ្ទះ។ ដូច្នោះការរៀបចំបក្សតាំងពីពេលនោះមក បានជួបគ្នានឹង អៀង សារី ដែរ។

**ស៖** លោក នួន ជា នៅក្នុងកំណត់ត្រាដែលលោកជួបប្រជុំជាមួយនឹង ខឹម នួន នៅក្នុងឆ្នាំ ១៩៩៨ លោកបានលើកឡើងថា លោក អៀង សារី និងបានមកចូលរួមធ្វើការជាមួយលោក ជាមួយនឹង ប៉ុល ពត នៅក្នុងបក្សក្រុង? តើពិតជាត្រឹមត្រូវដែរឬទេ? សម្រាប់លោកចៅក្រម ដើម្បីជាកំណត់ហេតុ ប្រតិចារឹក ឯកសារយោងនោះគឺ--។

**ឆ៖** ខឹម នួន ណាខ្ញុំមិនដែលស្គាល់ទេ។

[១១:៣១:៥៦]

**អ្នកបកប្រែ៖**

អ្នកបកប្រែសូមកែតម្រូវ។ ខឹម ងន់។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ខ្ញុំគិតថា ពេលនេះជនជាប់ចោទ ក៏មានឯកសារនៅចំពោះមុខខ្លួនផងដែរ គឺឯកសារលេខ IS 20.28 ដែលយើងបានកំណត់អត្តសញ្ញាណកាលពីម្សិលមិញ ដែលនៅក្នុងហ្នឹងមានលេខខ្មែរ ERN 00078190 គឺលេខ ERN ជាភាសាអង់គ្លេស គឺ 00184660 ហើយបារាំងមានលេខ ERN គឺ 00596183។ ប្រសិនបើយើងអាចបញ្ចាំងនៅលើអេក្រង់នេះ គឺខ្ញុំសូមបញ្ចាំងទំព័រលេខ 00078190។

[១១:៣៣:៣១]

**ឆ៖** សូមគោរពលោកប្រធាន! ខឹម ងន់ នេះខ្ញុំស្គាល់មកក្រោយហើយទេ។ ធ្វើការនៅជាមួយតាម៉ុក។ ឯប្រវត្តិ ខឹម ងន់ នេះដូចជាខ្ញុំបានជម្រាបមកហើយ គឺជាភ្នាក់ងាររបស់លោកនាយក ហ៊ុន សែន ឲ្យចូលទៅក្នុងជួររបស់បដិវត្តន៍ ដើម្បីយកការណ៍ នេះឈ្មោះ ខឹម ងន់។ ហើយក៏ខ្ញុំក៏មិនដឹងពេលនោះមានការអីក៏ចេះតែនិយាយគ្នាទៅ នេះជាការពិតមានអីចឹង។ ឯលេខសញ្ញារបស់ ខឹម ងន់ នេះគឺ 09។ ដូចខ្ញុំបានជម្រាបមកហើយ។

**ស៖** លោក នួន ជា ខ្ញុំមិនមែនសួរថាតើអ្នកណាគេជា ខឹម ងន់ នោះទេ? ក៏ប៉ុន្តែខ្ញុំចង់សួរថា នៅពេលដែលលោកនិយាយជាមួយនឹងលោក ខឹម ងន់ លោកបានជម្រាប ខឹម ងន់ ថា អៀង សារី បានមកចូលរួមធ្វើការជាមួយនឹងលោក ជាមួយនឹង ប៉ុល ពត នៅក្នុងបក្សក្រុង? តើពិតជាដូច្នោះដែរឬទេ?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនចាំទេ ព្រោះនិយាយគ្នាច្រើនណាស់ មិនដឹងជាការអី ជាការអីខ្លះ។

**ស៖** លោកបានបញ្ជាក់ថា លោកនិយាយដោយស្មោះត្រង់នៅពេលដែលនិយាយជាមួយលោក ខឹម ងន់ តើពិតជាត្រឹមត្រូវដែរឬទេ?

**ឆ៖** តាមខ្ញុំចាំ ខ្ញុំប្រាប់ ខឹម ងន់ ថាខ្ញុំនិយាយនេះក្រៅផ្លូវការទេ កុំយកជាបានការ។ ឯស្មោះត្រង់ ឬមិនស្មោះត្រង់ អាហ្នឹងសម្រេចលើខ្ញុំមើលសភាពការណ៍។ តើ ខឹម ងន់ នេះជាមនុស្សយ៉ាងម៉េច? មានការខ្លះ ខ្ញុំប្រាប់ការពិតឲ្យ ខឹម ងន់ ហ្នឹងយល់ ហើយមានការខ្លះក៏ខ្ញុំមិននិយាយដែរ ពីព្រោះមនុស្សនេះ ខ្ញុំក៏ក្តាប់មិនសូវបានដែរ ពីព្រោះមិនមែនជាមនុស្សរបស់-- ព្រោះជាមនុស្សរបស់ តាម៉ុក។

**ស៖** នៅពេលនេះ ខ្ញុំសូមឲ្យលោកមើលទំព័របន្ទាប់នៃឯកសារនេះ។ ឯកសារនេះជាភាសាខ្មែរ 00078191 ហើយអង់គ្លេស 00184661 ហើយបារាំង លេខ ERN គឺ 00596184 នៅក្នុង ឯកសារនេះ។ សេចក្តីប្រកាសនៅក្នុងនោះគឺបានលើកឡើងថា គឺលោកបាននិយាយអំពី អៀង សារី ។ លោក

បាននិយាយថា “អៀង សារី គេហៅថាគាត់ជាអ្នកឆ្វេងនិយម ហើយគាត់ងាកទៅខាងឆ្វេងនេះ” តើលោកចាំថា លោកបាននិយាយអ៊ីចឹង អំពី អៀង សារី ដែរឬទេ? ហើយលោកចាំទេថា តើលោកមានន័យយ៉ាងម៉េចនៅពេលដែលលោកថា គាត់ឆ្វេងនិយមនោះ?

**លោក ម៉ៃខល ផេសមិន៖**

សូមអភ័យទោសលោកប្រធាន! ខ្ញុំសូមជំទាស់សំណួរមួយនេះ យើងមិនអាចសន្និតថា កូនក្តីរបស់ខ្ញុំប្រាប់ទៅបុគ្គលរូបនោះអំពី អៀង សារី នោះទេ។ យើងក៏មិនដឹងថា តើឯកសារនេះ វាឆ្លុះបញ្ចាំងអំពីការលើកឡើងដោយ-- ពីកូនក្តីរបស់ខ្ញុំ ឬក៏យ៉ាងណានោះទេ។

**លោក ឌេល លីសាក់៖**

លោកប្រធាន គឺខ្ញុំគ្រាន់តែចង់សួរថា តើជនជាប់ចោទមានបាននិយាយអ៊ីចឹងអំពី អៀង សារី ដែរឬទេ?

**ប្រធានអង្គជំនុំ៖**

បាទ, ជំទាស់គ្មានប្រសិទ្ធភាព ហើយលោក នួន ជា ត្រូវឆ្លើយនឹងសំណួរដែលសួរដោយសហព្រះរាជអាជ្ញានេះ។

[១១:៣៨:២២]

**ឆ៖** លោកប្រធាន ខ្ញុំមិនចាំទេ។ ពីព្រោះម៉េចបានមិនចាំ? ពីព្រោះនៅផ្ទៃក្នុងបក្ស មានការខ្លះឆ្វេង មានការខ្លះស្តាំ វាចម្រុះគ្នា ដូច្នោះមិនដឹងជាអ្នកណាអ្នកណី ការកិច្ចការណាខ្លះស្តាប់ សូម្បីតែខ្លួនខ្ញុំក៏ដោយ ចួនណាយល់ទៅឆ្វេងទៅ ចួនណាទៅស្តាំទៅ។ ទាល់តែមានការប្រជុំ មានការអី កែប្រែគ្នាទៅអីទៅ។ វាមិនបរិសុទ្ធទាំងអស់ទេ ខ្ញុំសូមជម្រាបអ៊ីចឹង។ ពីព្រោះបក្សកុម្មុយនីស្តកម្ពុជា មិនមែនជាដែកថែបមួយដុំទេ វាមានឆ្វេង វាមានស្តាំ វាមានកណ្តាល។

**ស៖** តើលោកចាត់ទុកលោក អៀង សារី ថា ឆ្វេងនិយមដែរឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបលោកប្រធាន ខ្ញុំមិនដែលបានចាត់ទុកលោក អៀង សារី ជាឆ្វេងនិយមទេ ជាបក្ខជនមួយ។ ប៉ុន្តែចួនកាល ការងារខ្លះគាត់ឆ្វេងក៏ជួយកសាងទិតៀនគ្នាទៅ បើមាន ប៉ុន្តែបើគ្មានទេហើទៅ។

[១១:៤០:១២]

**ស៖** តើលោកចាត់ទុកលោក អៀង សារី ថារឹងរូស ហើយចចេសដែរឬទេ?

**ឆ៖** សូមជម្រាបលោកប្រធាន! ខ្ញុំមិនដែលចាត់ទុកលោក អៀង សារី ជាអ្នករឹងរូសអីៗទេ ពីព្រោះផ្ទៃក្នុងបក្សមានការអីណ៎ា កុំនិយាយប្រាប់ខាងក្រៅ យកមកទិតៀនគ្នាផ្ទៃក្នុង បើអ្នកណារឹងរូសចចេស ទិតៀនកែប្រែទៅ កុំយកទៅនិយាយក្រៅបក្ស។ នេះជាវិន័យរបស់បក្ស។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក សុន អរុណ៖**

សូមគោរពលោកប្រធានសាជាថ្មី ខ្ញុំសូមជំទាស់សំណួររបស់ព្រះរាជអាជ្ញា ដែលសួរពីរឿងលោក អៀង សារី។ ខ្ញុំយល់ថា ហាក់ដូចជាព្រះរាជអាជ្ញាក្លិចសង្ការឲ្យជល់គ្នា ដើម្បីផលប្រយោជន៍ដាក់បន្ទុករបស់ព្រះរាជអាជ្ញាពេលនេះ។ សូមអរគុណ។

**លោក ឌេល លីសាក់៖**

ខ្ញុំមិនមែនព្យាយាមធ្វើដូច្នោះនោះទេ។ ការលើកឡើងនៅក្នុងការសម្ភាសន៍នេះ គឺជាការលើកឡើងអំពីទំនាក់ទំនង អៀង សារី ជាមួយនឹង នួន ជា នៅក្នុងចុងទសវត្សរ៍៥០ គណៈពួកគេនៅក្នុងទីក្រុងភ្នំពេញ ហើយខ្ញុំគ្រាន់តែសួរព័ត៌មានដែលមានរៀបរាប់នៅក្នុងឯកសារនេះតែប៉ុណ្ណោះ។

[១១:៤២:៣៤]

**ប្រធានអង្គជំនុំ៖**

ជំទាស់គ្មានប្រសិទ្ធភាព។ សហព្រះរាជអាជ្ញាអាចតាំងសំណួរបន្ត សួរពាក់ព័ន្ធនឹងបញ្ហានេះបាន។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** នៅពេលនេះ ខ្ញុំសូមចូលសួរទៅដល់ចំណុចមួយទៀត គឺការផ្តាច់ខ្លួនរបស់ ស៊ីវ ហេង នៅក្នុងឆ្នាំ១៩៥៨ ដូចដែលលោក នួន ជា បានលើកឡើង។ នៅពេលដែលឪពុកមាថ្កៃរបស់លោក ស៊ីវ ហេង បានផ្តាច់ខ្លួននៅក្នុងឆ្នាំ១៩៥៨។ តើនៅពេលនោះ លោកក្លាយទៅជាអនុលេខាស្តីទីនៃបក្សដែរឬទេ? ឬក៏លោកមិនត្រូវបានតែងតាំងរហូតទៅដល់សន្និបាតបក្សលើកទីមួយនៅក្នុងឆ្នាំ១៩៦១?

[១១:៤៣:៣៦]

**លោក នួន ជា៖**

**ជ៖** សូមគោរពលោកប្រធាន! តាមខ្ញុំចាំ ស៊ីវ ហេង មិនមែនផ្ដាច់ខ្លួនឆ្នាំ១៩៥៨ ទេ គឺឆ្នាំ១៩៥៩ ទេ ដែល ស៊ីវ ហេង ផ្ដាច់ខ្លួននោះ។ ហើយពេលនោះ ក៏មិនទាន់មានចាត់តាំងជាលេខាបក្សអីជំនួសទេ នៅធ្វើការជាធម្មតា មានតែលោកតា ទូ សាមុត គាត់ជាអនុ តាមខ្ញុំចាំ ពីព្រោះអានេះ ខ្ញុំសូមជម្រាបឲ្យការពិតចុះ។ ខ្ញុំមិនដឹងគេចាត់តាំងពីណាអីមកណាទេ គឺខាងវៀតណាមទេ គេអ្នកចាត់តាំង ហើយយកមកឲ្យចូលមកក្នុងស្រុកខ្មែរ។ ឯយើងខ្ញុំគ្រាន់តែទទួលស្គាល់ថា ឱ! ប្រហែលជា ស៊ីវ ហេង ហើយលេខា ប្រហែលជាលោកតាហើយ ពីព្រោះចាស់ទុំ។

[១១:៤៤:៤៤]

ដូច្នោះ បក្សខ្លួនឯងហ្នឹងក៏មិនដឹងអ្នកណាលេខា អ្នកណាជាអនុលេខា ក៏ប៉ុន្តែការស្មានទៅវាឃើញអ៊ីចឹង។ ដូច្នោះដល់ ស៊ីវ ហេង នេះមានការទំនាស់ខាងទស្សនៈ ទំនាស់យ៉ាងម៉េចបានជា ស៊ីវ ហេង ចេញមួយ? គ្មានលុយ កូនចៅរៀនសូត្រ អត់មានលុយជីវភាព។ ពីរ ស៊ីវហេងខ្លាចត្រូវចាប់។ បីទាក់ទងជាមួយ លន់ នល់ ហើយមានការជជែកជាមួយខ្ញុំដែរ។ ស៊ីវ ហេង ថា ពេលណាសភាព-ការណ៍លំបាក យើងត្រូវក្រាបសិន យើងត្រូវឱនសិន កុំធ្វើអី នៅស្ងៀម សំងំសុខ។ ខ្ញុំថា មិនត្រូវទេ ពេលណាសភាពការណ៍លំបាក យើងកាន់តែត្រូវធ្វើការឲ្យខ្លាំងឡើង ដើម្បីកុំឲ្យបក្ខជនបាត់ស្មារតី។ នេះមានការទំនាស់គ្នាខាងទស្សនៈគោលជំហរជាមួយខ្ញុំដែរ។

នេះខ្ញុំសូមជម្រាបការពិត ទោះបីជាបងប្អូនក៏ដោយ ពីព្រោះអានេះរឿងបក្ស មិនមែនរឿងបងប្អូនឯណា។

**ស៖** ខ្ញុំយល់ពីការឆ្លើយរបស់លោកថា រហូតមកទល់ទសវត្សរ៍ឆ្នាំ១៩៦០ ទើបលោកត្រូវបានគេតែងតាំងជាលេខា-- អនុលេខារបស់បក្ស។ តើមែនដែរឬទេ?

**ជ៖** ឆ្នាំ-- មែន។

**ស៖** ខ្ញុំសូមត្រឡប់ទៅឯកសារ IS20.28 ដដែលនេះ នៅក្នុងឯកសារនេះ លោកបានលើកឡើងថា ខ្ញុំសូមដកស្រង់សម្ដីរបស់លោកថា "ខ្ញុំបានទទួលបន្ទុក និងទាក់ទងជាមួយនឹងខាងជនបទ ហើយខាង ហើយ សាឡុត ស ទទួលបន្ទុកនៅក្នុងក្រុង និងបូព៌ា"។ បន្ទាប់មកលោកបន្តនិយាយទៀតថា "ទូ សាមុត មិនមានប្រយោជន៍នោះទេ ដោយសារគាត់ចាស់ ហើយមិនសូវចេះដឹង។ ដូច្នេះមានតែ សាឡុត ស ហើយខ្ញុំទេ ដែលធ្វើការងារនេះ"។ សម្រាប់ប្រតិចារឹកវាមាននៅក្នុងកំណត់សម្គាល់ មានឯកសារ

លេខ D300-- អ៊ីចឹងឯកសារនេះគឺ មានលេខ D366/7.1410។

ឯកសារនេះគឺមានលេខ ERN គឺ 006206 ដល់ 07, 00716419 ជាភាសាអង់គ្លេស និង 00721004 ឯកសារជាលេខ ERN គឺ 00078191 ហើយមួយទៀតគឺ 00184662។ លោក នួន ជា ខ្ញុំចង់សួរថា ហេតុអ្វីបានជានៅពេលនោះ លោកនិយាយថា លោក ទូ សាមុត អត់ធ្វើអីកើត? ហើយគាត់មិនសូវយល់ដឹងអ្វីទេ។ នៅពេលដែលលោកនិយាយជាមួយនឹង ខឹម ងន់។

[១១:៤៩:០១]

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំសូមជំទាស់សាជាថ្មី។ សំណួរដែលសួរនេះ គឺមិនដឹងថាកូនក្តីរបស់ខ្ញុំនិយាយ ឬក៏មិននិយាយនោះទេ។ យើងក៏មិនដឹងថា សេចក្តីប្រកាសនេះវាត្រឹមត្រូវ ឬក៏មិនត្រឹមត្រូវ ហើយក៏មិនដឹងថាវាជាការលើកឡើងរបស់កូនក្តី របស់ខ្ញុំឬទេ។ ដូច្នេះសហព្រះរាជអាជ្ញា គួរតែសួរឲ្យបានជាក់លាក់ទៅលើចំណុចហ្នឹង។

**ស៖** តើលោកចាំដែរឬទេ លោក នួន ជា តើលោកបានប្រាប់នរណាគេម្នាក់ ឬប្រាប់គេថា លោក ទូ សាមុត នោះគឺគាត់អត់សូវយល់អ្វីផង?

**ឆ៖** សូមជម្រាបគោរពលោកប្រធាន! ខ្ញុំនេះមិនមែននិយាយថា លោកតា ទូ សាមុត នោះគាត់មិនដឹងអីនោះទេ។ ខ្ញុំអត់ដែលប្រើពាក្យអីអ៊ីចឹងទេ ព្រោះខ្ញុំគោរពគាត់ គាត់ជាចាស់ទុំ។ ខ្ញុំនិយាយថា ចំពោះសភាពការណ៍នៅទីក្រុងភ្នំពេញ លោកតាគាត់មិនសូវយល់ទេ។ ដូច្នោះបានជាប្រគល់ភារកិច្ចឲ្យសាឡុត ស នេះទទួលភារកិច្ចស៊ើបពិនិត្យក្តាប់សភាពការណ៍នៅភ្នំពេញ។ ក៏ប៉ុន្តែ យើងទាំងអស់គ្នាបក្ខជនទាំងអស់គ្នាគោរពនូវសីលធម៌បដិវត្តន៍ នូវគុណធម៌បដិវត្តន៍ នូវចរិយាធម៌បដិវត្តន៍របស់លោកតា ទូ សាមុត។ ក៏ប៉ុន្តែពិតមែនហើយ ពីព្រោះគាត់អង្គាល់នោះ គាត់នៅខាងវៀតណាមខាងត្បូងឯណោះ។ គាត់មិនទាន់យល់សភាពការណ៍នៅភ្នំពេញយ៉ាងម៉េចៗ គាត់មិនយល់ទេ។ អានេះខ្ញុំនិយាយប្រាប់ទាំងអស់គ្នាថា យើងត្រូវជួយពន្យល់សភាពការណ៍គាត់ បើមិនអ៊ីចឹងទេន៎ លោកតាគាត់មិនយល់សភាព-ការណ៍ទេ។ ហើយខ្ញុំនិយាយឲ្យត្រង់ ពេលនោះ បើគ្មានលោកតា ទូ សាមុត ជាចាស់ទុំ ដើម្បីបង្រួបបង្រួមសាមគ្គីបក្សសម្ងាត់ ហើយនិងក្រុមប្រជាជនន៎ វាបែកបាក់គ្នាអស់ហើយ។ ក៏ប៉ុន្តែលោកតា ទូ សាមុត នេះគាត់ជាបង្គោលមួយសម្រាប់បង្រួបបង្រួមក្រុមប្រជាជនដែលចេញចំហ និងបក្សដែលធ្វើការសម្ងាត់នៅទីក្រុងភ្នំពេញ។ ទាំងខ្ញុំក្តី ទាំង ម៉ី ម៉ាន់-- ។ កាលនោះមាន ម៉ី ម៉ាន់ ដែរ ម៉ី ម៉ាន់,

សាឡុត ស អ្នកណាក៏គោរពនូវគុណធម៌ សីលធម៌ របស់លោកតា ទូ សាមុត ដែរ។ ក៏ប៉ុន្តែជាទស្សនៈសភាពការណ៍ជាអីៗគាត់ក្ដាប់មិនទាន់បានទេ។ អានេះការពិតអ៊ីចឹង។

[១១:៥២:១៥]

**ស៖** សូមអរគុណ។ ខ្ញុំលើកឡើងនូវការលើកឡើងមួយទៀត ដែលលោកលើកឡើងនៅក្នុង IS 20.28 គឺនៅមានឯកសារ-- នៅក្នុងឯកសារលេខ 78190 និងអង់គ្លេស 184660 ហើយបារាំងគឺ 596183។ នៅក្នុងការលើកឡើងនោះ គឺលោកបាននិយាយដូច្នេះថា "នៅពេលនោះការដឹកនាំបក្សរបស់យើងមិនទាន់មានមាគ៌ាយុទ្ធសាស្ត្រ និងយុទ្ធវិធីនៅឡើយទេ។ យើងគ្រាន់តែធ្វើការលើកិច្ចការដែលមានស្រាប់ និងការកសាងឡើងវិញនូវពួកកងទ័ពរប៉ាត់រប៉ាយ"។ លោកបានបញ្ជាក់ទៀតថា "លោកបានទាក់ទងជាមួយនឹងមនុស្សពីរនាក់នៅខេត្តនីមួយៗ គឺខេត្តបាត់ដំបង កំពង់ឆ្នាំង កំពត តាកែវ កោះកុង ស្វាយរៀង ព្រៃវែង និងកំពង់ចាម ដើម្បីរៀបចំសាខាបក្សជាថ្មីឡើងវិញ"។

ខ្ញុំចង់សួរថា បុគ្គលដែលទទួលខុសត្រូវទាក់ទងជាមួយនៅតាមទីជនបទ និងខេត្តដូចដែលលោកបានបញ្ជាក់នុ៎ង ថាតើលោកជ្រើសរើសកម្មាភិបាលនៅក្នុងតំបន់នីមួយៗនោះដោយរបៀបណា ដើម្បីឲ្យពួកគេអាចជួយរៀបចំសាខាបក្សជាថ្មីឡើងវិញ?

[១១:៥៣:៤៤]

**ឆ៖** សំណួររបស់លោកវែងបន្តិច ដូច្នេះខ្ញុំឆ្លើយជូនណាមិនអស់សំណួរ។ ខ្ញុំសូមគោរពលោកប្រធាន! កាលនោះតាមខ្ញុំចាំ ទាក់ទងកម្មាភិបាលចាស់ៗដែលនៅល្អក្រោយពីកិច្ចព្រមព្រៀង-- អាហ្នឹងត្រូវនិយាយក្រោយកិច្ចព្រមព្រៀងហ្សឺណែវ។ ក្រោយពីកិច្ចព្រមព្រៀងហ្សឺណែវហើយ មានការបង្ក្រាបរាតត្បាតខ្លាំងណាស់។ ដូច្នោះអ្នកតស៊ូសម័យហ្នឹង ហៅថា "ខ្មែរវៀតមិញ" នោះ នៅតែក្នុងព្រៃ ហើយខ្លះរត់ពីខេត្តមួយទៅខេត្តមួយ។ ឯខាងអ្នកដែលខ្ញុំទាក់ទងនែ៎ ខ្ញុំមិនបានទាក់ទងច្រើនខេត្តដូចជាលោកមានប្រសាសន៍ទេ ខ្ញុំទាក់ទងបានខាងពាយព្យ គឺ មូល សម្បត្តិ។ ទាក់ទងខាងកំពង់ឆ្នាំង គឺ ម៉ា ម៉ង់។ ទាក់ទងខាងនិរតី គឺ តា ម៉ុក នៅល្អ គាត់នៅល្អ។ គាត់អារឈើលក់នៅក្នុងព្រៃទេ មិនប៉ានចេញក្រៅទេ។ នៅបូព៌ាទាក់ទងបាន សោ ភឹម ព្រោះ សោ ភឹម នេះគាត់មកធ្វើកម្មករសំណង់នៅភ្នំពេញ។ ឯនៅកន្លែងឯទៀតៗ ទាក់ទងមកក្រោយនេះ ខ្ញុំក៏មិនសូវចាំដែរ ពីព្រោះអ្នកដែលទាក់ទងបានចាស់នេះ គេទៅទាក់ទងតទៅទៀត បន្តទៅទៀត មិនមែនខ្ញុំជាអ្នកទៅទាក់ទងទេ។ ដូចជាខាងក្រចេះ ខាងស្ទឹងត្រែងអីនេះ ខ្ញុំមិនដែលស្គាល់ ខ្ញុំមិនសូវស្គាល់ទេ។ នេះខ្ញុំសូមជម្រាប។ ព្រោះខ្ញុំម្នាក់ឯង ខ្ញុំទៅទាក់ទងស្គាល់

ឯណាអស់។

**ស៖** សំណួររបស់ខ្ញុំនោះ គឺថាលោកបាននិយាយក្នុងពេលមួយចំនួនថា មានសាខាបក្សចំនួនពីរ ហើយលោកបានលើកឡើងទីកន្លែងចំនួនពីរ គឺសាខាបក្សរបស់ តាម៉ុក នៅនិរតី ដែលមានភាពរញ៉េរញ៉ៃ ហើយនិង ម៉ា ម៉ង់ នៅក្នុងខេត្តកំពង់ឆ្នាំង។ ខ្ញុំចង់សួរថា តើលោកបានធ្វើអ្វីខ្លះ ដើម្បីកសាងមូលដ្ឋានរបស់បក្ស ឬក៏សាខារបស់បក្សនៅតំបន់ផ្សេងៗទៀតនោះ?

**ជ៖** ខ្ញុំសូមជម្រាបឲ្យច្បាស់ សូមគោរពលោកប្រធាន។ សាខាបក្សកាលនោះនៅសល់ពីរមែន គឺមួយសាខាបក្សនៅនិរតី សាខាបក្សឃុំត្រាំកក់។ ឯមួយទៀតនៅកំពង់ឆ្នាំង សាខាបក្សឃុំពាម មានបីនាក់។ ក្នុងការរៀបចំសាខាបក្សឡើងវិញនេះ គឺទាក់ទងជាមួយអ្នកដែលគេចាស់ទុំពីដើមនោះ ដែលនៅល្អ ដូចជា ម៉ា ម៉ង់ គាត់នៅល្អ។ តាម៉ុក ពិតមែនតែគាត់កាចបន្តិច មាត់កអី ក៏ប៉ុន្តែគាត់ស្មោះត្រង់ ប្រគល់ការងារអីទៅ គាត់ធ្វើភ្លាម។ ឯការរៀបចំបក្ស មិនមែនរៀបចំបក្សភ្លាមទេ ត្រូវរៀបចំបណ្តើរៗ តាំងពីចាត់តាំងជាសមាគមស្រូវ ចាត់តាំងជាសមាគមរក្សាជំងឺ ចាត់តាំងជាសមាគមប្រវាស់ដៃ ចាត់តាំងជាសមាគមរៀនសូត្រ ជួយគ្នាទៅវិញទៅមក ហើយចាត់តាំងជាសមាគមដុតខ្មោច ពីព្រោះសុទ្ធតែក្រៗ។

[១១:៥៨:២៧]

ដូច្នោះចាត់តាំងៗពីតូចៗៗទៅអ៊ីចឹងទៅ បានទៅជាប្រមូលរៀបចំ អ្នកណាដែលល្អ ដែលសកម្មរៀបចំឲ្យចូលជាសមាជិកបក្សបណ្តើរៗទៅ។ អានេះខ្ញុំសូមជម្រាបអំពីដំណើរនៃការរៀបចំបក្ស មិនមែនដាក់ភ្លាម ទៅចាប់ដាក់បញ្ចូលទេ រៀបចំតាំងពីតូចៗទៅ។ ដូចខ្ញុំជម្រាបអ៊ីចឹង តាំងពីសមាគមស្រូវតាំងអីៗឡើងទៅ សមាគមជួយសង្គ្រោះគ្នាទៅវិញទៅវិញ សមាគមអីៗ អ៊ីចឹងទៅ។ តែប៉ុណ្ណឹងទេ។

**ស៖** ខ្ញុំសូមសួរដូច្នេះលោក នួន ជា។ ឃុំឃីម នៅក្នុងខេត្តកំពង់ឆ្នាំង តើពិតជាត្រឹមត្រូវដែរឬ?

[១១:៥៩:៣១]

**ជ៖** អត់ទោសឃុំអីអាហ្នឹង?

**ស៖** ស្រុកកំពង់ត្រឡាច។

**ជ៖** ឃុំអី?

**ស៖** ខ្ញុំសួរអំពីឃុំឃីម?

**ជ៖** ឃុំឃីម ដូចគ្មានទេ សូមគោរពលោកប្រធាន។ ខ្ញុំមិនដែលស្គាល់ឃុំឃីម។ ឃុំពាមមាន!

**ស៖** បាទ, អ៊ីចឹងតើឃុំហ្នឹង គឺនៅក្នុងស្រុកអីដែរ?

[១២:០០:១៣]

**ឆ៖** ឃុំពាម សូមគោរពលោកប្រធាន! ឃុំពាម នៅក្នុងស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។

**ស៖** តើឃុំនោះនៅតែជាសាខាបក្សដ៏រឹងមាំមួយរហូតមកដល់ទសវត្សរ៍ទី៦០ និងទសវត្សរ៍ទី៧០។ តើមែនដែរឬទេ?

**ឆ៖** សាខាបក្សនោះនៅរឹងប៉ឹងៗ ក៏ប៉ុន្តែមិនមែនរឹងប៉ឹងណាស់ណាទេ ពីព្រោះសភាពការណ៍វាច្របូកវាច្របល់។ ដូច្នោះក៏ៗប៉ុន្តែ បើប្រៀបធៀបនឹងសាខាបក្សដែលវារលាយ សាខាឃុំពាមហ្នឹងវានៅល្អជាងគេ។ ពីព្រោះអ្នកនាំ គឺ ម៉ា ម៉ង់ ហ្នឹង គាត់ជាអ្នកដឹកនាំមួយត្រឹមត្រូវ អ្នកដឹកនាំដែលល្អ។ ដូច្នោះគាត់មានឥទ្ធពលនៅក្នុងប្រជាជននៅក្នុងឃុំហ្នឹងទាំងមូល ហើយក៏មានឥទ្ធិពលនៅក្នុងសមាជិកបក្សហ្នឹងដែរ។ គេគោរពរាប់អានគាត់ ព្រោះគាត់ជាអ្នកតស៊ូចាស់ នៅស៊ូទ្រាំលំបាកវេទនា មិនដែលបានជួបប្រពន្ធកូនទេ ដេកតែព្រៃទេ។ គាត់បាននិយាយប្រាប់ខ្ញុំថា ថ្ងៃមួយគាត់បានទៅនៅផ្ទះគេអ្នកក្រមួយ ហើយគាត់ឮសូរមាត់ប្រពន្ធគាត់ទៅរកខ្ចីស្រូវគេ គាត់ហែកជញ្ជាំងមើលឃើញប្រពន្ធគាត់ទូលកញ្ជើទៅរកខ្ចីគេ គាត់សឹងស្រក់ទឹកភ្នែក។ ក៏ប៉ុន្តែ នាទីរបស់បក្សមិនដឹងធ្វើម៉េច ស៊ូអត់ធ្មត់ទៅ។ នេះរហូតដល់ប៉ុណ្ណឹង។

[១២:០២:២២]

**ប្រធានអង្គជំនុំ៖**

អរគុណលោកព្រះរាជអាជ្ញា អរគុណលោក នួន ជា។

ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកពិសាអាហារថ្ងៃត្រង់ហើយនៅពេលនេះ។ ហេតុដូច្នេះអង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាថ្ងៃត្រង់ ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយនិងសាមសិបនាទីរសៀលហ្នឹង សូមអញ្ជើញចូលវិញ។

ដូច្នេះភាគី និងសាធារណជនជ្រាប ហើយអនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទទៅកាន់បន្ទប់ខាងក្រោម ហើយនិងឲ្យនាំខ្លួនគាត់មកកាន់សាលសវនាការវិញនៅរសៀលនេះឲ្យមុនម៉ោងមួយ និងសាមសិបនាទីជាកំណត់។

សូមអញ្ជើញសម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១២:០៤ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣០:៤២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយនៅក្នុងដំណើរការសវនាការនៅរសៀលនេះ អង្គជំនុំជម្រះនឹងការបន្តសួរចម្លើយជនជាប់ចោទពាក់ព័ន្ធនឹងអង្គហេតុដែលធ្វើនៅសវនាការនៅវគ្គទីមួយ។ ប៉ុន្តែមុននឹងផ្តល់វេទិកាទៅឲ្យសហព្រះរាជអាជ្ញា អង្គជំនុំជម្រះសូមជម្រាបជូនភាគី សាធារណជន ការិយាល័យរដ្ឋបាល ព្រមទាំងអង្គភាព មន្ត្រី បុគ្គលិក ដែលមានភារកិច្ចគាំទ្រកិច្ចដំណើរការសវនាការរបស់អង្គជំនុំជម្រះសាលាដំបូងជ្រាបថា កាលពីម្សិលមិញ អង្គជំនុំជម្រះបានជម្រាបជូនដំណឹងដល់ភាគី និងសាធារណជន ព្រមទាំងការិយាល័យរដ្ឋបាល និងមន្ត្រីដែលពាក់ព័ន្ធថា អង្គជំនុំជម្រះមានបំណងក្នុងការធ្វើសវនាការនៅព្រឹកថ្ងៃស្អែក គឺថ្ងៃសុក្រ ទី១៦ ខែធ្នូ ឆ្នាំ២០១១ នេះមួយព្រឹកទៀត។ ប៉ុន្តែឥឡូវនេះ ដោយសារស្ថានភាពនៃបញ្ហាចំពោះមុខរបស់អង្គជំនុំជម្រះដែលមានច្រើនត្រូវរៀបចំ ដើម្បីប្រជុំពិភាក្សាដកហូតនូវបទពិសោធន៍ដែលបានដំណើរក្នុងរយៈពេលពីរសប្តាហ៍កន្លងមកនេះ ហើយនិងរៀបចំផែនការការងារសម្រាប់គ្រប់គ្រងកិច្ចដំណើរការសវនាការនៅដើមឆ្នាំ ២០១២ ចាប់ពីថ្ងៃទី១០ ខែមករា តទៅ។

[១៣:៣២:៤៥]

ហេតុដូច្នេះ អង្គជំនុំជម្រះបានសម្រេចថា សវនាការដែលគ្រោង-- ខ្លួនមានបំណងធ្វើការនៅព្រឹកថ្ងៃស្អែកហ្នឹង គឺមិនធ្វើទេ។ ហេតុនេះ សូមភាគីនិងសាធារណជនជ្រាប។

សូមអញ្ជើញលោកមេធាវី!

**លោក អាកទួរ វែកគែន៖**

សូមអភ័យទោសលោកប្រធាន។ អ៊ីចឹង ស្អែកហ្នឹងបានន័យថាមិនមានសវនាការទេ? អំមិញហ្នឹងខ្ញុំចង់សួរ-- សុំសេចក្តីបំភ្លឺមួយទាក់ទងទៅនឹងការដាក់ភស្តុតាង ដែលជាកម្មវត្ថុនៃសំណើរបស់សហព្រះរាជអាជ្ញា គឺថាសៀវភៅ "ឃាលលីងហ្វៀល (Killing Field)" ហើយនិងកិច្ចសម្ភាសន៍មួយ។ ខ្ញុំយល់ឃើញថា នៅពេលដែលយើងលើកនិយាយអំពីបញ្ហាហ្នឹងជាលើកទីមួយនោះ បញ្ហាហ្នឹងត្រូវបានរកដំណោះស្រាយឃើញ ពីសំណាក់សហព្រះរាជអាជ្ញាហើយ។ ក៏ប៉ុន្តែឥឡូវនេះ-- ក៏ប៉ុន្តែការដាក់ភស្តុតាងនេះ មិនមានបានសុំអីទេ។ ឥឡូវនេះ ខ្ញុំយល់ឃើញថាមានសំណើនៃភស្តុតាងហ្នឹង ដែលថា

សុំដាក់ឲ្យសហព្រះរាជអាជ្ញា ហើយលោកស្រីចៅក្រម ខាតវ៉ាយថ៌ បានប្រាប់ថា សេចក្ដីសម្រេចហ្នឹងនឹងផ្ដល់ជូននៅពេលក្រោយ។ ហើយខ្ញុំចង់ដឹងថា តើតុលាការចាត់ទុកថាមានការពិភាក្សាគ្រប់ជ្រុងជ្រោយហើយឬនៅ ទាក់ទងនឹងចំណុចនេះ? តើតុលាការត្រូវគិតពិចារណាពីបញ្ហាហ្នឹង មុននឹងចេញសេចក្ដីសម្រេច ឬក៏យើងត្រូវជជែកតវ៉ាគ្នា ដើម្បីឲ្យយើង គឺថាភាគីទាំងអស់គ្នាហ្នឹង អាចបញ្ចេញមតិរបស់ខ្លួនបាន?

**លោក វីល្លៀម ស្មីត៖**

សូមគោរពលោក លោកស្រីចៅក្រម! តាមអ្វីដែលយើងហ្នឹង គឺថាយើងនឹងជាពិសេសមេធាវីការពារក៏មានបំណងនឹងពិនិត្យមើលចម្លើយមួយចំនួន។ ហើយទាក់ទងទៅនឹងការទទួលយកថាជាភស្តុតាងហ្នឹង គឺត្រូវបំបែកចេញក្នុងរបៀបមួយអំពីការតាំងសំណួរទៅសាក្សី គឺថាមូលហេតុនោះ គឺថាប្រសិនបើយើងដេញដោលពីភាពទទួលយកបានគ្រប់ដំណាក់កាលទាំងអស់នោះ គិតថា យើងនឹងបាត់លំដាប់លំដោយ ឬក៏លំហូរនៃការផ្ដល់សក្ខីកម្ម។ បើយើងនិយាយពីឯកសារជាងប្រាំមួយពាន់ឯណោះ គឺថា សំណើគឺវាត្រូវរង់ចាំការសម្រេច សេចក្ដីនឹងត្រូវចេញជាក្នុងឆាប់ៗដែលចៅក្រមបានបញ្ជាក់។

[១៣:៣៦:១៤]

ហើយលោកចៅក្រមបានជូនដំណឹងយើងផងដែរថា វាមានឯកសារមួយចំនួននឹងត្រូវពិភាក្សានៅថ្ងៃក្រោយ។ នេះហើយគឺជាឆន្ទានុសិទ្ធិរបស់តុលាការ ហើយថ្ងៃណាមួយគឺថា យើងនឹងនិយាយកំណត់ការបរិច្ឆេទដើម្បីនិយាយអំពីភាពអាចទទួលយកបានពីបញ្ហានោះ។ ហើយសហព្រះរាជអាជ្ញាបានដាក់ឯកសារមួយចំនួន ដើម្បីគ្រាន់តែកំណត់ពីឯកសារទេ មិនបានបញ្ជាក់ថាសូមថាឲ្យទទួលស្គាល់ពេលនេះទេ។ ហើយយើងទទួលស្គាល់ថា យើងត្រូវមានទទ្បីករណ៍ហើយយើងស្នើសុំថា រីឯការបញ្ជាក់នោះនឹងត្រូវធ្វើឡើងនៅក្នុងសវនាការ និយាយពីការទទួលស្គាល់យកឯកសារមកដាក់នេះ។

**លោក អាកទួរ វែកគែន៖**

បាទ, ខ្ញុំសូមអរគុណលោកប្រធាន។ នេះជាបញ្ហាមួយស្មុគស្មាញណាស់ពីព្រោះ គឺថាជាប្រហែលជាកាតព្វកិច្ចរបស់ភាគីការពារក្ដីនៅពេលដែលថា សហព្រះរាជអាជ្ញាចង់ដាក់ឯកសារមួយជូនទៅដល់សាក្សីនោះ ហើយដើម្បីយកមកជជែកតវ៉ានោះ លើភាពសមស្របនៃឯកសារហ្នឹង ឬក៏ភាពពាក់ព័ន្ធនៃឯកសារហ្នឹង។

[១៣:៣៧:៣០]

ខ្ញុំគិតឃើញថា តុលាការកំណត់វិធានឲ្យច្បាស់លាស់ឲ្យបានកាន់តែឆាប់ នៅឯកសារទាំងឡាយណាដែលថា យើងយកមកប្រើដើម្បីជាមូលដ្ឋាននៃការផ្តល់សេចក្តីសម្រេច។ ខ្ញុំបានកត់សម្គាល់ឃើញថា អ្នកស្រីចៅក្រម ខាតវ៉ាយថ៍ បាននិយាយនៅថ្ងៃទី៥ ធ្នូ នោះ ថាលើកលែងតែមានការជំទាស់នៅនឹងកំណត់ហេតុនៅក្រោមទំព័រនោះ ជើងទំព័រ។ ឥឡូវនេះ យើងនិយាយអំពីដីកាដំណោះស្រាយ អ៊ីចឹងទាំងអស់ហ្នឹងចាត់ទុកថា ជាភស្តុតាងដែលអង្គជំនុំជម្រះប្រើដើម្បីជាមូលដ្ឋានក្នុងការធ្វើសេចក្តីសម្រេចរបស់ខ្លួន។ អ៊ីចឹងខ្ញុំគិតថា តើនៅពេលណាយើងនឹងនិយាយអំពីបញ្ហាទាំងអស់នេះ ពិភាក្សាគ្នា។

[១៣:៣៨:៣៥]

មានបញ្ហាមួយទៀតដែលចែងដោយវិធាន៨៧ នៃវិធានផ្ទៃក្នុង។ ក្នុងការបន្ថែម គឺថាសំណើសុំបន្ថែមភស្តុតាងនោះនៅក្នុងសវនាការដោយភាគីហ្នឹង ក្នុងពេលដែលថាភស្តុតាងទាំងអស់ហ្នឹងវាមិនមាននៅក្នុងហ្វូតណូត ហើយក៏មិនទាន់នៅក្នុងបញ្ជីដែលដាក់ដោយភាគី ហើយបញ្ហាទាំងអស់ហ្នឹងក៏អត់ទាន់បានពិភាក្សាគ្នាដែរ។ អ៊ីចឹងខ្ញុំចង់ធ្វើការបូកសរុបកន្លែងទាំងហ្នឹង ដើម្បីគូសបញ្ជាក់នូវលក្ខណៈពិសេសសំខាន់បំផុត ដើម្បីឲ្យការជជែកតវ៉ាហ្នឹងមិនត្រូវអាក់ខានរាល់ដងជជែកគ្នាអំពីបញ្ហាឥតប្រយោជន៍។ អ៊ីចឹងខ្ញុំចង់ដឹងអំពីគោលជំហររបស់អង្គជំនុំជម្រះ ថាតើយើងនឹងលើកយកបញ្ហាទាំងអស់នេះ មកពិភាក្សាគ្នានៅពេលណា?

[១៣:៤០:០០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៤៣:២៩]

**ប្រធានអង្គជំនុំ៖**

ដើម្បីជូននូវបញ្ហាដែលលើកឡើងដោយ មេធាវីការពារក្តីលោក ខៀវ សំផន អម្បាញ់មិញនេះ យើងប្រគល់ភារៈនេះទៅលោក ហ្សង់ម៉ាក ដើម្បីធ្វើការឆ្លើយបំភ្លឺ បញ្ជាក់អំពីបញ្ហានេះ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ, សូមអរគុណលោកប្រធាន។ ខ្ញុំនិយាយក្រោមការត្រួតពិនិត្យរបស់លោកប្រធាន ហើយនិងចៅក្រមផ្សេងទៀត ដែលអាចនឹងកែតម្រូវបើសិនជាខ្ញុំ និយាយទៅមិនត្រឹមត្រូវ។

ជាបឋម អង្គជំនុំជម្រះចង់បញ្ជាក់ថា ខ្លួនបានទទួលសំណើមួយចំនួនដើម្បីពិចារណា ឬក៏ឯកសារមួយចំនួនដែលថា យើងនឹងយកមកជជែកដេញដោលនៅក្នុងសវនាការ ហើយខ្លួនក៏បានទទួលផងដែរនូវ

ការដាក់ជាលាយលក្ខណ៍អក្សររបស់ភាគី ទាក់ទងទៅនឹងភាពទទួលយកបាននៃឯកសារមួយចំនួននោះ។ ដូច្នេះ យើងបានធ្វើសេចក្តីសម្រេចលើសំណើទាំងអស់នេះ ហើយដែលតម្រូវឲ្យចំណាយពេលជាច្រើន ហើយអ៊ីចឹងយើងមិនទាន់បានធ្វើសេចក្តីសម្រេចទេ ហើយយើងនឹងចង់ធ្វើសេចក្តីសម្រេចទាំងអស់នៅដើមឆ្នាំក្រោយ។ ហើយម៉្យាងទៀត គឺថាអង្គជំនុំជម្រះកំពុងតែពិនិត្យមើលគម្រោងកាលវិភាគរបស់យើងនៅសម្រាប់ខែក្រោយៗទៀត។ ហើយអ៊ីចឹង យើងនឹងមានសវនាការពិសេសដែលនឹងធ្វើឡើងសម្រាប់ក្នុងការបង្ហាញភស្តុតាង ធាតុផ្សំនៃភស្តុតាងដែលថា មានលក្ខណៈពាក់ព័ន្ធសម្រាប់-- នៅភាគផ្នែកមួយចំនួននៃដីកាដំណោះស្រាយដែលយើងយកត្រួតពិនិត្យ។ អ៊ីចឹងគឺថានៅក្នុងសវនាការនេះ យើងនឹងស្តាប់អំណះអំណាងរបស់ភាគីទាក់ទងនឹងភាពទទួលយកបាននេះ។ ក៏ប៉ុន្តែទន្ទឹមនឹងនេះ គឺថាវាជាការសំខាន់ណាស់ក្នុងការបែងចែកឲ្យច្បាស់ពីភាពទទួលយកបាន ហើយនិងការវាយតម្លៃនៃតម្លៃភស្តុតាងនៃធាតុផ្សំនីមួយៗ។ នេះគឺជាការពិភាក្សាលើ-- សំខាន់បំផុតដែលយើងនឹងពិភាក្សានៅពេលក្រោយ ប៉ុន្តែអ្វីលើកនេះគឺយើងចង់ដឹងថា តើមានការជំទាស់ទាក់ទងនឹងអ្វីមួយ។ ឧទាហរណ៍ ដូចជាការបង្ហាញភស្តុតាងអីមួយ ឬក៏ការបង្ហាញនៃប្រភេទឯកសារអីមួយនោះ។ ខ្ញុំសង្ឃឹមថា អ្វីដែលខ្ញុំបានលើកឡើងនេះគឺថាអាចជួយបំភ្លឺទាក់ទងនឹងសំណួរដែលលោកបានចោទអម្បាញ់មិញ។

**លោក អាកទួរ វែកគែន៖**

សូមអរគុណលោកប្រធាន គឺថា លោកចៅក្រមអ្វីដែលខ្ញុំនិយាយអម្បាញ់មិញហ្នឹងគឺថាចង់គូសបញ្ជាក់ថា គឺថាឥឡូវនេះយើងស្ថិតនៅក្នុងភាពងងឹត ហើយយើងមិនច្បាស់លាស់ទាក់ទងទៅនឹងព័ត៌មានច្បាស់លាស់ដែលថាៗ ចៅក្រមយកគិតដើម្បីជាមូលដ្ឋាននៃសេចក្តីសម្រេចរបស់ខ្លួន។ អ៊ីចឹងគឺថាសំណួរ គឺថាៗអ្វីដែលជាបញ្ហាគឺថា តើឲ្យតម្លៃទៅលើឯកសារ ឬក៏ភស្តុតាងមួយចំនួនដែលថានឹងយកមកជជែកនៅពេលក្រោយដែរឬក៏អត់នោះ។ ក៏ប៉ុន្តែអ្វីដែលខ្ញុំចង់កំណត់ ឬក៏ថាចង់ឲ្យទៅមុខនៅក្នុងការពិភាក្សារបស់យើងនោះគឺថា តើបញ្ហាទាំងអស់នេះដែលថាទាក់ទងទៅនឹងភស្តុតាងនឹងបន្ថែម ឬក៏នៅក្នុងហ្វូតណូតនៃដីកាដំណោះស្រាយនេះ យើងនឹងពិភាក្សាគ្នានៅពេលណា ដែលថាអង្គជំនុំជម្រះហ្នឹងចាត់ទុកថាជាឯកសារ ដែលថាខ្លួននឹងយកទៅប្រើប្រាស់នៅពេលក្រោយនោះ។ អ៊ីចឹងឥឡូវនេះ ខ្ញុំយល់ថាយើញនឹងមានការពិភាក្សាគ្នានៅពេលក្រោយ គឺថារួមបញ្ចូលទាំងភស្តុតាងដែលថាភ្ជាប់ទៅនឹងដីកាដំណោះស្រាយហ្នឹងផងដែរ។

អ៊ីចឹង ខ្ញុំសង្ឃឹមថាយើងនឹងពិភាក្សាគ្នានៅពេលដែលយើងជជែកតវ៉ាគ្នាហ្នឹងតែម្តង។

[១៣:៤៨:០០]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ, យើងមិនបាននិយាយថា យើងមិនបានចាំ នៅពេលសវនាការចុងក្រោយ ដើម្បីឲ្យអស់លោកទាំងអស់គ្នាធ្វើការជំទាស់នោះទេ។ ខ្ញុំគិតថាយើងទាំងអស់គ្នានឹងច្បាស់ទាំងអស់គ្នាហើយ គឺថាៗ ធាតុផ្សំនៃភស្តុតាងទាំងអស់ដែលមាននៅក្នុងហ្វូតណូតនោះ នឹងគិតថាជាឯកសារនឹងយកមកជជែកតវ៉ាគ្នា គឺថា សន្មតៗថាវាបានទទួលយកបានហើយ បើសិនជាអត់មានបញ្ហាដែលថា យើងលើកឡើងមកជំទាស់ទេ ដែលថាឯកសារហ្វូតណូតទាំងនេះគឺថាបានទទួលស្គាល់នេះ ហ្នឹងហើយអ្វីដែលខ្ញុំចង់បាន។ ព្រោះថាឧទាហរណ៍មួយ ខ្ញុំមិនចង់ឲ្យមានសង្គ្រាមស្លាប៉ាកាអី នៅទីនេះទេ។

គឺថាឯកសារមួយដែលភ្ជាប់ទៅនឹងដីកាដំណោះស្រាយនេះ ឧទាហរណ៍: ឯកសារទាំងអស់នេះអត់មានបានបកប្រែទៅជាភាសាផ្លូវការទាំងបីនោះទេ។ អ៊ីចឹងគឺថាយើងមានការលំបាកខ្លាំងក្នុងការបញ្ចេញមតិលើលក្ខណៈវិនិច្ឆ័យលើភាពទទួលយកបាននេះណាស់។ អ៊ីចឹង តើយើងថា តើយើងអាចមានការពិភាក្សាគ្នាមួយលើបញ្ហាបកប្រែនេះដែរឬក៏អត់?

[១៣:៤៩:៥៧]

**ប្រធានអង្គជំនុំ៖**

បាទ, បញ្ហាអម្បាញ់មិញលើកឡើងអំពីបញ្ហាការដាក់ឯកសារនៅចំពោះមុខអង្គជំនុំជំម្រះ ហើយបញ្ហានេះត្រូវបានដោះស្រាយរួចហើយ។ ឥឡូវចេញបញ្ហាមួយទៀត លើការបកប្រែ។ អ៊ីចឹងបញ្ហានេះវាវែង ហើយបញ្ហានេះបានលើកឡើងជាញឹកញាប់ណាស់មកហើយ។ ដូច្នេះបញ្ហាការដាក់ឯកសារនេះតាមដែលយើងបានពិនិត្យនូវអនុស្សរណៈជាចុងក្រោយរបស់អង្គជំនុំជម្រះបានចេញអម្បាញ់មិញនេះ គឺបានបង្ហាញដល់អំពីពេលវេលាសមស្របដែលនឹងតម្រូវឲ្យភាគី ឬក៏បើកសិទ្ធិឲ្យភាគក្នុងការដាក់ឯកសារចំពោះមុខអង្គជំនុំជម្រះនៅក្នុងអង្គហេតុនៃ ដែលបានធ្វើសវនាការនិងវគ្គទីមួយ ព្រមទាំងវគ្គទីពីររួចហើយ។

អ៊ីចឹងអាចពិនិត្យមើលបន្ថែមទៀត លើអនុស្សរណៈចុងក្រោយដែលទើបតែចេញថ្មីៗនេះ ហើយបញ្ហាផ្សេងទៀត គឺយើងទុកមួយឡែកនៅពេលណាដែលសមស្រប ថាតើគួរតែពិភាក្សាដោះស្រាយបញ្ហានោះយ៉ាងដូចម្តេច ពីព្រោះបញ្ហានេះលើកឡើងច្រើនលើកច្រើនសារួចហើយ។

[១៣:៥១:២២]

**លោក អាកទួរ វែកគែន៖**

លោកប្រធាន គឺខ្ញុំករណីខ្លះខ្ញុំមិនបានលើកឡើងទេ ហើយខ្ញុំគិតថាអនុស្សរណៈដែលលោកប្រធានបាននិយាយនេះ ខ្ញុំមិនដឹងថា តើឋានៈផ្លូវច្បាប់នៃអនុស្សរណៈហ្នឹងយ៉ាងម៉េចនោះទេ ប៉ុន្តែអ្វីដែលខ្ញុំដឹងឬក៏អ្វីដែលខ្ញុំយល់នោះ គឺថា គឺវាហាក់ដូចជាមានការបញ្ជាថា ឯកសារដែលភាគីប្រើប្រាស់នៅក្នុងតុលាការនោះត្រូវតែបកប្រែជាភាសាផ្លូវការទាំងបីរបស់តុលាការ។ ទោះយ៉ាងណាក៏ដោយ ទោះជាមានអនុស្សរណៈនេះ គឺថាជាការដាក់បន្ទុកមួយទៅដល់ខាងមេធាវីការពារ ហើយចំពោះកាតព្វកិច្ចក្នុងការបកប្រែនេះ មិនមែនជាកាតព្វកិច្ចរបស់ខាងមេធាវីការពារក្តីទេ គឺយើងធ្វើម៉េចដើម្បីឱ្យយើងអាចទទួលបានឯកសារដើម្បីយើងប្រើប្រាស់នៅក្នុងសវនាការ ហើយឯកសារទាំងអស់នេះ គឺមាននៅក្នុងកំណត់សម្គាល់ជើងទំព័រនៅក្នុងដីកាដំណោះស្រាយរួចហើយ។ ហើយឯកសារទាំងអស់នោះ គឺគ្មានការបកប្រែទាល់តែសោះ។

[១៣:៥២:១៨]

ដូច្នេះជាមួយនឹងការសម្រេច ឬក៏អនុស្សណៈនេះ ខ្ញុំមិនដឹងថា តើអនុស្សណៈនេះមានឋានៈផ្លូវច្បាប់បែបណានោះទេ ហើយទោះជាយ៉ាងណាក៏ដោយ គឺថា គឺជាការរុញបន្ទុកមួយទៅឱ្យមេធាវីការពារក្តីក្នុងការធ្វើការបកប្រែ ហើយនៅពេល-- ហើយគឺថាយើង គឺចាប់បង្ខំឱ្យខាងយើងហ្នឹង បកប្រែឱ្យបានគ្រប់ឯកសារនៅក្នុងតុលាការនេះ។ ហើយឯកសារទាំងអស់នេះ គឺជាឯកសារដែលនឹងប្រើប្រាស់ជាការដោះបន្ទុក ឬដាក់បន្ទុកទៅលើជនជាប់ចោទ។

[១៣:៥២:៥២]

ដូច្នេះ ករណីនេះគឺថាមិនអាចទទួលយកបានទេ វាគឺជាវិធីមួយ ឬក៏របៀបមួយក្នុងការបង្វែរទំនួលខុសត្រូវ ឬក៏កាតព្វកិច្ច ជាផ្លូវការដែលមានចែងនៅក្នុងអត្ថបទច្បាប់ទាំងឡាយ ដែលអនុញ្ញាតឱ្យភាគីដែលមានវត្តមាននៅទីនេះ ហើយដែលនិយាយភាសាបី ភាសាផ្សេងគ្នានោះ គឺត្រូវតែទទួលបានឯកសារ។ គឺថាដូច្នេះ យើងមានបញ្ហាហើយនៅពេលនេះ ហើយខ្ញុំមិនយល់ស្របជាមួយនឹងតុលាការទេដែលតុលាការយល់ថា បញ្ហានេះបានដោះស្រាយហើយ។ គឺខ្ញុំចំពោះខ្ញុំគិតថា គឺមិនមានការដោះស្រាយទេ ហើយខ្ញុំត្រូវតែមានការបំភ្លឺ ហើយត្រូវតែមានការជជែកដេញដោលមួយឱ្យបានច្បាស់លាស់នៅចំពោះមុខសាធារណជន ដើម្បីឱ្យអ្នកទាំងអស់ដែលមានវត្តមាននៅទីនេះដឹងច្បាស់ថា តើភាគីនៅទីនេះមានការលំបាកយ៉ាងណាខ្លះនៅក្នុងសវនាការ។

**ប្រធានអង្គជំនុំ៖**

យើងបាននិយាយអម្បាញ់មិញ ដូចជាមានពីរលក្ខខណ្ឌខុសគ្នា រវាងការដាក់ឯកសារចំពោះមុខសវនាការរបស់ភាគី ដែលដាក់សម្រាប់ជាការបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះរវាងឯកសារដែលសម្រាប់ពាក់ព័ន្ធនឹងការធ្វើសវនាការវគ្គទីមួយ ហើយនិងវគ្គទីពីរនៃការកំណត់កន្សោមអង្គហេតុនៅក្នុងបណ្តាកថាខណ្ឌនៅក្នុងដីកាដំណោះស្រាយ។

ដោយឡែក យើងមិនបាននិយាយអំពីការបកប្រែភាសាទេ យើងគ្រាន់តែលើកថាបញ្ហា ការបកប្រែភាសានេះ វាមានបញ្ហាហ្នឹងរ៉ាំរ៉ៃយូរណាស់ហើយ ហើយយើងថា ទុកបញ្ហាហ្នឹងមួយដុំ យើងមិនយកមកពិចារណាសម្រេចលើឥឡូវហ្នឹងទេ លើបញ្ហាឯកសារបកប្រែ ឬក៏មិនទាន់បកប្រែនេះ។ អ៊ីចឹងពីរខុសគ្នា។

[១៣:៥៤:៥0]

ជាកិច្ចបន្ត អនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក នួន ជា មកកាន់ឈើវាងវង់ក្រចកសេះនៅចំពោះមុខអង្គជំនុំជម្រះ។

**លោក អាកទួរ វែកគែន៖**

(គ្មានការបកប្រែ)

[១៣:៥៥:០០]

**ប្រធានអង្គជំនុំ៖**

យើងមិនអនុញ្ញាតឲ្យលោកនិយាយទៀតទេ បញ្ហានេះគឺយើងបន្តនីតិវិធី។ យើងអត់ឲ្យទេ យើងបន្តនីតិវិធី។

សូមអញ្ជើញលោក ហ្សង់ម៉ាក។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ដើម្បីជម្រាបជូនលោកចំណុចមួយនោះ គឺថាមុននឹងលោកត្រូវបានតែងតាំងជាមេធាវីផ្លូវការរបស់លោកនោះ គឺថាយើងមានបានចេញសេចក្តីសម្រេច ហើយនិងអនុស្សរណៈមួយចំនួន។ ប្រហែលជាលោកមិនបានដឹងពីចំណុចទាំងអស់នោះ។

ដូច្នេះខ្ញុំគិតថា វាមានសារៈសំខាន់ណាស់ គឺថាយើងបានចំណាយពេលយ៉ាងច្រើនទៅលើបញ្ហាដែលថាមានការបកប្រែនេះ។ ហើយខ្ញុំគិតថា ទោះជាក្នុងករណីណាក៏ដោយ គឺអង្គជំនុំជម្រះមិនបាន

បញ្ជាក់ថាឯកសារ ដើម្បីទទួលបានគឺត្រូវតែបកប្រែជាបីភាសានោះទេ។

ដូច្នេះ នៅក្នុងដំណាក់កាលនេះ ខ្ញុំសូមឲ្យលោកអាននូវសេចក្ដីសម្រេចមុនៗរបស់តុលាការមុននឹងចង់ឲ្យមានការពិភាក្សាដេញដោលទៅលើចំណុចនេះ។

[១៣:៥៦:៣៤]

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត អង្គជំនុំជម្រះសូមប្រគល់វេទិកាទៅសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរចំពោះជនជាប់ចោទ នួន ជា។ សូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោក នួន ជា នៅពេលដែលយើង-- យើងបានសម្រាកនោះ យើងបាននិយាយអំពីកន្លែងពីរដែលយើងស្គាល់ថាមូលដ្ឋានសំខាន់ដែលបក្សបានមានទីតាំង ហើយលោកបាននិយាយម៉ា ម៉ង់ ហើយនិងឃុំពាម។ ខ្ញុំចង់ដឹងពីលោក អំពីតាម៉ុក អំពីមូលដ្ឋានរបស់គាត់នៅត្រាំកក់ ឬក៏ជាការពិតដែរឬទេថានៅត្រាំកក់ មូលដ្ឋាននោះគឺជាមូលដ្ឋានសំខាន់មួយរបស់បក្សនៅក្នុងអំឡុងពេលឆ្នាំ១៩៦០ ដល់១៩៧០ តើត្រឹមត្រូវឬទេ?

**លោក នួន ជា៖**

**ឆ៖** សូមក្រាបថ្វាយបង្គំព្រះសង្ឃ សូមគោរពលោកប្រធាន សូមគោរពបងប្អូនរួមជាតិទាំងអស់។ ខ្ញុំភ្លេចសំណួរទៅហើយ លោកសំណួរថាម៉េច ភ្លេចទៅហើយ។ សូមស្នើសួរ សុំលោកប្រធានស្នើសួរម្ដងទៀត។

**ស៖** ខ្ញុំអាចសួរសំណួររបស់ខ្ញុំ ថាតើត្រាំកក់ជាមូលដ្ឋានរបស់តាម៉ុក ក៏ជាមូលដ្ឋានដ៏ខ្លាំងមួយរបស់បក្សដែរឬទេក្នុងអំឡុងឆ្នាំ១៩៦០ ដល់១៩៧០?

**ឆ៖** សូមគោរពលោកប្រធាន។ មូលដ្ឋានសាខាត្រាំកក់ ថាខ្លាំងណាស់ក៏មិនខ្លាំងណាស់ ក៏ប៉ុន្តែល្មមកណ្ដាល ល្មមអាចដំណើរការទៅបាន។

**ស៖** តើវាមិនមែនជាករណីទៀតទេ ដែលថាឆ្នាំ១៩៧៦ ដែលគណៈមជ្ឈិមបានផ្ដល់កិត្តិយសជាទង់ក្រហម ទៅឲ្យស្រុកបី គឺស្រុកត្រាំកក់ កំពង់ត្រឡាច ជាមូលដ្ឋានពីរដែលយើងកំពុងបានពិភាក្សា

តើជារឿងត្រឹមត្រូវ ឬក៏មិនត្រឹមត្រូវ លោក នួន ជា?

**ឆ៖** សូមគោរពលោកប្រធាន! ខ្ញុំភ្លេចហើយ មិនដឹងជាប្រគល់ទង់ក្រហម ឬទង់អីឲ្យទេខ្ញុំភ្លេចទៅ ពីព្រោះយូរឆ្នាំណាស់ទៅហើយ។

**លោក ឌេល លីសាក់៖**

លោកប្រធាន! ឥឡូវនេះ ខ្ញុំសូមជូនឯកសារដល់ជនជាប់ចោទ D2/15.4។

**ប្រធានអង្គជំនុំ៖**

មន្ត្រីច្បាប់យកឯកសារជូនគាត់។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ខ្ញុំបានបានបង្ហាញជូនទង់អំពីបដិវត្តន៍ គឺ D2/15.4 ហើយនិងឲ្យលោកមើលទំព័រដូចខាងក្រោមនេះ ក្នុងជាភាសាខ្មែរ ERN0006279 រហូតទៅដល់ 2262728។ នៅក្នុងភាសាអង់គ្លេស ERN00446848 រហូតទៅដល់ 446852 ហើយភាសាបារាំង ERN00487709 រហូតដល់ 714។ ខ្ញុំនឹងសួរលោកជាពិសេស សូមលោកទៅដល់ទំព័រមួយចំនួនដែលមានចែងព័ត៌មាននេះដូចខាងក្រោមនេះ។ ដកស្រង់៖ ចំពោះអ្នកដែលត្រូវទទួលទង់ក្រហមបដិវត្តន៍របស់បក្សកុម្មុយនីស្តកម្ពុជានោះ ទៅដល់កម្មាភិបាលទាំងអស់ ហើយនិងកសិករ ហើយនិងសហករណ៍នៅក្នុងខេត្តពោធិសាត់ កំពង់ត្រឡាចលើនៅភូមិភាគបស្ចិម ហើយនិងស្រុកត្រាំកក់នៅក្នុងភូមិភាគនិរតី។ តើជារឿងត្រឹមត្រូវទេ ដែលគណៈអចិន្ត្រៃយ៍ដែលជាកិត្តិយសជាទង់បដិវត្តន៍ ឬក៏ថាទង់ក្រហមទៅដល់ស្រុកទាំងនេះនោះ?

[១៤:០២:៣៨]

**លោក នួន ជា៖**

**ឆ៖** គោរពលោកប្រធាន! ខ្ញុំ-- ឯកសារនេះ ខ្ញុំមើលមិនសូវឃើញទេ។ ពីព្រោះពុម្ពវាតូចពេក ហើយវាខ្មៅ ក៏ប៉ុន្តែបើថាអាច បើថាសាខាទាំងនោះ គេដំណើរទៅល្អតាមមាគ៌ាន៍ មជ្ឈិមបក្សអាចនឹងប្រគល់ទង់ក្រហម ឬក៏អាចប្រគល់ស្អីឲ្យ អាចក៏មានដែរ។ ប៉ុន្តែឯកសារនេះ ខ្ញុំមើលមិនឃើញទេ។ ភ្នែកខ្ញុំងងឹតហើយ។

**ស៖** តើលោកអាចប្រាប់តុលាការបានទេ ថាតើទង់កិត្តិយស ទង់ក្រហមបដិវត្តន៍នោះ វាមានអត្ថន័យដូចម្តេចដើម្បីឲ្យស្រុក ឬក៏កន្លែងណាមួយទទួលបានទង់នេះនោះ?

**ឆ៖** ជម្រាបលោកប្រធាន! ទង់ក្រហម កិត្តិយសប្រគល់ឲ្យសម្រាប់សាខាបក្សណាដែលមានថ្វីដៃ៖ ១) ក្នុងការដោះស្រាយជីវភាពប្រជាជន ២) សាមគ្គីផ្ទៃក្នុងបក្សល្អ ៣) ពង្រីកបក្ខជនបានល្អ។ ឯក្រៅពីនេះ អាចនឹងមានគុណសម្បត្តិឯទៀតៗជាច្រើន ដូចជាទាក់ទងល្អជាមួយបក្សដទៃៗផ្សេងៗទៀត។ អានេះ បើតាមខ្ញុំចាំខ្លះ គឺវាមានលក្ខណៈសម្បត្តិពិសេសរបស់វា មិនមែនចេះតែប្រគល់ឲ្យទៅដោយប្រថុយៗទេ ហើយនេះក៏មកអំពីការស្នើៗរបស់ភូមិភាគ គេស្នើមក។

**ស៖** អ៊ីចឹង គឺខ្ញុំចូលទៅដល់សំណួរមួយទៀត លោក នួន ជា ថាតើគណៈមជ្ឈិមសម្រេចថាយកស្រុកណាដែលត្រូវទទួលទង់កិត្តិយស ទង់ក្រហមនេះ?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនចាំទេ ពីព្រោះយូរណាស់ហើយ។

**ស៖** ខ្ញុំចូលទៅដល់ចំណុចមួយទៀត ទាក់ទងទៅនឹងការទទួលខុសត្រូវចំពោះការអប់រំនយោបាយដល់សមាជិកបក្ស។ លោកបានផ្តល់សក្ខីកម្មអំពីនេះ គឺសំណួរទីមួយ ខ្ញុំចង់ឲ្យលោកបំភ្លឺនោះ គឺអំពីការទទួលខុសត្រូវរបស់លោកទាំងមុន ហើយនិងក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ។ សំណួររបស់ខ្ញុំហ្នឹង ថាតើលោកទទួលខុសត្រូវក្នុងការអប់រំនយោបាយទៅដល់បក្ខជន ទៅដល់-- មុនឆ្នាំ១៩៧៥ដែរឬទេ?

[១៤:០៦:៣០]

**ឆ៖** សូមគោរពលោកប្រធាន! ខ្ញុំទទួលខុសត្រូវតាំងពីមុខឆ្នាំ១៩៧៥ មក គឺនិយាយរួម តាំងពីក្រោយកិច្ចព្រមព្រៀងហ្សឺណែវ ខ្ញុំទទួលភារកិច្ចតែមួយហ្នឹងទេ គឺអប់រំ។ ពីព្រោះអី? ពីព្រោះសភាពការណ៍វាប្រែប្រួល។ ពីដើមមុនកិច្ចព្រមព្រៀងហ្សឺណែវ មានការតស៊ូអាវុធ។ ដូច្នោះយើងពឹងលើនយោបាយផង អាវុធផង។ ក៏ប៉ុន្តែដល់មានកិច្ចព្រមព្រៀងហ្សឺណែវទៅ ត្រូវរំសាយទ័ពទៅរួមរស់នៅក្នុងរាជក្នុងរាជរដ្ឋាភិបាលកម្ពុជា។ កាលដែលបក្ខជនទៅរួមរស់នៅៗក្នុងសង្គមជាតិតែមួយនេះ វាពិបាកណាស់។ ពិបាកយ៉ាងម៉េច? ពីព្រោះអ្នកដែលគេដែលមិនបានតស៊ូនោះ គេច្រើនមើលងាយមើលថោក ហើយហៅឈ្មោះថា "ខ្មែរវៀតមិញ" វាអាក្រក់យ៉ាងនេះ វាអាក្រក់យ៉ាងនោះ។ ដូច្នោះ បញ្ហានេះត្រូវអប់រំយ៉ាងច្រើន អប់រំច្រើនណាស់ គ្មានពេលទំនេរទេ។ គឺយកការអប់រំធ្វើជាការងារសំខាន់ នេះសម្រាប់ដោះស្រាយខាងទស្សនៈ ខាងគោលជំហរ កុំឲ្យមានការប្រកែប្រកាន់អីគ្នា។ ក្រៅពីការអប់រំខាងគោលជំហរទស្សនៈនយោបាយ បុគ្គលនិយម ផលប្រយោជន៍និយមហើយ គឺអប់រំឲ្យបន្តភារកិច្ចស្នេហាជាតិ ស្នេហាប្រជាជនតទៅទៀត កុំប្រកែប្រកាន់។ នេះ ខ ទីពីរ។

ខ ទីបី អប់រំឲ្យខិតខំបង្កបង្កើនផលឲ្យបានច្រើន ដើម្បីនឹងឧបត្ថម្ភខ្លួន ពីព្រោះគ្មានប្រទេសណាគេជួយយើងទេ មានតែខ្លួនជាទីពឹងខ្លួន ខ្លួនដោះស្រាយជីវភាពដោយខ្លួនឯង។ ដូច្នោះមាន ខ ទាំងប៉ុន្មាននេះដែលអប់រំជាប់។

[១៤:០៩:៣៩]

**សៈ** ខ្ញុំចង់ឲ្យលោកបំភ្លឺមួយ ប្រហែលជាការបកប្រែទៅចន្លោះ បង្ហាញថា ជាដំបូង គឺថា ការទទួលខុសត្រូវរបស់លោក គឺថាមុនឆ្នាំ១៩៧៥ ប៉ុន្តែលោកបានឆ្លើយថា វាជាការត្រឹមត្រូវដែលគេប្រគល់ការទទួលខុសត្រូវរបស់លោកតាំងពីក្រោយពីឆ្នាំ១៩៥៧ មកម្ល៉េះ។ តើអ៊ីចឹងមែនឬទេ?

**ឆៈ** ៥៤, ៥៥, ៥៦។ និយាយរួម-- ខ្ញុំសូមគោរពលោកប្រធាន! អប់រំចប់ មិនមែនតាំងពីហាប៉ុន្មានដូចទេ គឺតាំងពីក្រោយកិច្ចព្រមព្រៀងហ្សឺណែវមកអប់រំជាប់ ពីព្រោះពេលដែលរំលាយកងទ័ពរំលាយកងប្រដាប់អាវុធ ត្រូវទៅចូលរស់នៅក្នុងសង្គមចាស់ ក្នុងសង្គមដែលភ្លើតភ្លើន សង្គមដែលពុករលួយ សង្គមស្រីញីស្រា អីជាដើម។ ដូច្នោះបក្ខជនយើងដែលធ្លាប់រស់នៅក្នុងព្រៃ តស៊ូ ស្អាតស្អំមានការប្រជុំ មានការជីវភាព ហើយមានការជួយឧបត្ថម្ភគ្នាទៅវិញទៅមក។ ដល់ទៅប៉ះនៅក្នុងសង្គមបែបនេះន៎ សតិអារម្មណ៍វាប្រែប្រួល។ មិនត្រឹមតែដូច្នោះក្នុងឋានៈខ្ញុំជាអប់រំ ខ្ញុំត្រូវក្តាប់ ត្រូវយល់សភាពការណ៍សតិអារម្មណ៍របស់សមាជិកបក្សឲ្យបានជ្រៅជ្រះ។ កុំឲ្យទៅភ្លើតភ្លើនដូចគេ ត្រូវរក្សាកិត្តិយសក្នុងឋានៈជាអ្នកបដិវត្តន៍។ យើងកុំបណ្តោយខ្លួនទៅស៊ីផឹក ឬទៅរក ទៅកេងប្រវ័ញ្ច ធ្វើមានធ្វើបាន ប៉ុន្តែខំរកទទួលទានខំទៅ ប៉ុន្តែខំតាមសម្មាអាជីវោរបស់ខ្លួន កុំទៅបោកប្រាស់គេ កុំទៅអីៗគេហើយតាមខ្ញុំចាំ ជាពិសេសចៀសវាង អបាយមុខបីយ៉ាង ស្រី ស្រា លុយកាក់ ល្បែងពាលា ធ្វើម៉េចចៀសវាងឲ្យផុតអានេះ។ បើថាចៀសវាងបញ្ហាអបាយមុខនេះបានហើយន៎ ក៏រក្សាកិត្តិយស រក្សាធាតុជាអ្នកបដិវត្តន៍ ជាអ្នកតស៊ូបានមួយកម្រិតដែរ។

[១៤:១២:៥៧]

ក៏ប៉ុន្តែបញ្ហានេះវាមិនមែនបានទាំងអស់១០០ភាគរយទេ។ ពីព្រោះអី? ពីព្រោះបងប្អូនអូសទាញជូនណាប្រពន្ធអូសទាញទៅ ឲ្យទៅរកស៊ីមានបានទៅ ណាំមើលគេណាំ គេរកស៊ីមានបានហើយ ឯងចេះតែ មិនគិតខំរកស៊ីអី គិតតែពីរៀនសូត្រ។ អានេះវាមានច្រើនណាស់។ ហើយខ្ញុំសូមជម្រាបឲ្យត្រង់ទៅចុះ ជាពិសេសប្រពន្ធ នារីៗ ដែលជាប្រពន្ធកម្មាភិបាល អូសទាញកម្មាភិបាលដែលល្អៗណាំ។ ជួនណាឲ្យទៅខូចទៅ ឲ្យទៅខូចខាងអី? ឲ្យទៅរកស៊ី ឲ្យទៅរកស៊ីមិនត្រឹមត្រូវ។ ឲ្យប្រកបរបររកទទួលទាន

មិនត្រឹមត្រូវ។

ដូច្នោះការប្រយុទ្ធ ខ្ញុំសូមជម្រាប ខ្ញុំទុកដូចជាការប្រយុទ្ធខាងផ្លូវសតិអារម្មណ៍នេះ វាលំបាកណាស់ វាមិនមែនស្រួលទេ។ ពីព្រោះវាប្រែ វាប្រួល អនិច្ចំ ទុក្ខ វាអនិច្ចំៗ ទុក្ខំ អនត្តា ធម៌ព្រះនិយាយនេះមិនខុសទេ។ សតិអារម្មណ៍ហ្នឹងវាប្រែប្រួលហើយ ពិតមែនតែជា យើងបញ្ហាវាមិនបាន ពីព្រោះសង្គមវាអូសទាញ។ ពេលនោះសង្គមអូសទាញខ្លាំងណាស់។ ដូច្នោះអ្នកដែលធ្លាប់តស៊ូ ខូចច្រើនណាស់ ខ្ញុំសូមជម្រាបអ៊ីចេះ។ នៅសល់មួយចំនួនតិចទេ ដូចជាបានជម្រាបលោកប្រធានហើយ នៅសល់តែពីរសាខាទេ ដែលនៅរឹងប៉ឹងគ្រាន់បើ។ ឯក្រៅពីនោះ ខិលខូចខ្លះទៅ អីទៅ។ នេះវាមានបញ្ហាអ៊ីចឹង។

[១៤:១៥:០៤]

ដូច្នោះសមរភូមិអប់រំ សមរភូមិប្រយុទ្ធនេះត្រូវធ្វើជាប់ ទោះបីសភាពការណ៍លំបាក សភាពការណ៍ខ្លាំងរករាតត្បាតចាប់ចងយើងម៉េចក៏ដោយ ពីរនាក់ក៏រៀន បីនាក់ក៏រៀន បួននាក់ក៏រៀន។ រៀនតិច រៀនច្រើន ចេះតែរៀនទៅ ហើយជួយរំឭកដាស់តឿនគ្នា ធ្វើម៉េចឲ្យរក្សាទុកនូវធាតុជាអ្នកបដិវត្តន៍ ជាអ្នកតស៊ូឲ្យបាន។ សូមជម្រាបលោកប្រធាន ប៉ុណ្ណឹង។

**ស៖** ចាតើការបោះផ្សាយទង់បដិវត្តន៍ ត្រូវបានប្រើប្រាស់សម្រាប់ការអប់រំដល់កម្មាភិបាល ឬក៏សមាជិកបក្សដែរឬទេ?

**ឆ៖** ទង់បដិវត្តន៍ សូមជម្រាបគោរពលោកប្រធាន! បានផ្សព្វផ្សាយ ប៉ុន្តែមិនបានគ្រប់គ្នាទេ។ ខ្លះក៏បានរៀនទៅ ខ្លះក៏មិនរៀនទៅ ពីព្រោះដូចខ្ញុំជម្រាបលោកប្រធានអ៊ីចឹង។ និស្ស័យបក្ខជនខ្លះចូលចិត្តរៀន ខ្លះមិនចូលចិត្តរៀន ខ្លះចូលចិត្តតែធ្វើ ដូច្នោះវាដូចមនុស្សតែមនុស្សយើងធម្មតាអ៊ីចឹងដែរ ខ្លះខ្ជិលរៀនផង មិនចង់កសាងខ្លួន។ ឯអ្នកដែលចង់កសាងខ្លួនក៏មានច្រើន ឯអ្នកដែលមិនចង់កសាងខ្លួនឲ្យទៅជាល្អ ឬរក្សាធាតុដើមរបស់ខ្លួននោះក៏វាមាន។ សូមជម្រាបលោកប្រធាន ប៉ុណ្ណឹង។

[១៤:១៦:៥២]

**ស៖** ចាតើទង់បដិវត្តន៍នេះ ត្រូវបានបែងចែងទៅអ្នកណាដែរ?

**ឆ៖** សូមជម្រាបលោកប្រធាន! ទង់បដិវត្តន៍ចែកទៅឲ្យគណៈកម្មាធិការភាគ ហើយសម្រេចនឹងគណៈកម្មាធិការភាគគេចែកតទៅទៀត។

**ស៖** តើលោកបានបើកវគ្គបណ្តុះបណ្តាលដល់កម្មាភិបាល ដោយបានប្រើប្រាស់អ្វីលើសពីទង់បដិវត្តន៍នេះទៀតដែរឬទេ?

**ឆ៖** ក្រៅ-- សូមគោរពលោកប្រធាន! ក្រៅពីទង់បដិវត្តន៍នេះក៏មានឯកសារមួយចំនួនដែរ។ ខ្ញុំសូមលើកឧទាហរណ៍ ដូចជាឯកសារលោកទស្សនៈ សង្គមទស្សនៈ ការបែកចែកវណ្ណៈក្នុងសង្គម ឯកសារសីលធម៌បដិវត្តន៍ ឯកសារគុណធម៌របស់អ្នកស្នេហាជាតិ ឯកសារនិយាយរួមច្រើនដែរ ប៉ុន្តែខ្ញុំភ្លេច ខ្ញុំចាំតែប៉ុណ្ណឹង។ ខ្ញុំសូមរំឭកឯកសារលោកទស្សនៈ ជីវទស្សនៈបដិវត្តន៍ ឯកសារសង្គមទស្សនៈចំពោះសង្គមជាតិយ៉ាងម៉េច? ការបែកចែកវណ្ណៈក្នុងសង្គមយ៉ាងម៉េច? ឯកសារសីលធម៌បដិវត្តន៍ម៉េច? ឯកសារគុណធម៌ជាអ្នកស្នេហាជាតិត្រូវដាក់ខ្លួនយ៉ាងម៉េច? អីយ៉ាងម៉េច? មានច្រើនឯកសារ។

**ស៖** នៅពេលដែលមានការបោះពុម្ពផ្សាយទង់បដិវត្តន៍មានឯកសារមួយ ដែលលោកបានប្រើប្រាស់ក្នុងការបណ្តុះបណ្តាលវគ្គនយោបាយដល់កម្មាភិបាលដែរឬទេ?

[១៤:១៩:១៨]

**ឆ៖** ខ្ញុំសួរ ខ្ញុំសូមសួរទង់បដិវត្តន៍ហ្នឹងមុនរំដោះ ឬក្រោយរំដោះ? ខ្ញុំសូមសួរលោក មុនរំដោះឬក្រោយរំដោះ?

**ស៖** ខ្ញុំសូមសួរលោកមុនរំដោះសិន ថាតើមុនរំដោះតើលោកបានពន្យល់ ឬក៏បានប្រើប្រាស់ទង់បដិវត្តន៍ជាឯកសារមួយប្រភេទ ដើម្បីធ្វើការអប់រំនយោបាយដល់សមាជិកបក្សដែរឬទេ?

**ឆ៖** គាត់ធ្វើការអប់រំដល់បក្ខជនខាងក្រោម ប៉ុន្តែសម្ងាត់ ធ្វើសម្ងាត់ ធ្វើទង់បដិវត្តន៍នេះសម្ងាត់។ ដូចជា ខ្ញុំសូមជម្រាបបន្តិច សរសេរនឹងក្រដាសក្រមួន ហើយយកក្រដាសក្រមួននោះកាលណោះមានឈើប៉ុណ្ណឹង ហើយយកកៅស៊ូអូសធ្វើស្ងាត់។ មានតែពីរនាក់ដែលអ្នកធ្វើទង់បដិវត្តន៍រឿងហ្នឹង ប្តីប្រពន្ធតែពីរនាក់ស្ងាត់ទេ។ ហើយចែកទៅឲ្យតាមភូមិភាគៗ គេមកយកទៅ ឯការដែលដាក់ឯកសារនោះទៀតក៏មានវិធីសម្ងាត់របស់គេ។ ប៉ុន្តែដល់ក្រោយមករំដោះបោះពុម្ពមានរោងពុម្ពបោះ ដល់មានរោងពុម្ពបោះវាចំហវាស្រួល បោះបានច្រើនម្តងបានរាប់រយក្បាលដែរ។

**ស៖** តើលោកមានបានទទួលទង់បដិវត្តន៍នេះដែរឬទេ? ទស្សនាវដ្តីទង់បដិវត្តន៍នេះដែរឬទេ?

**ឆ៖** ខ្ញុំធ្លាប់បានទទួលដែរ ព្រោះអ្នកធ្វើទង់បដិវត្តន៍ហ្នឹង គឺគណៈអចិន្ត្រៃយ៍ជាអ្នកសរសេរជាពិសេសលេខាបក្ស ហើយនិងខ្ញុំ។

[១៤:២២:០១]

**ស៖** ឥឡូវខ្ញុំសូមបង្ហាញលោកនូវផ្នែកខ្លះ នៃទង់បដិវត្តន៍ចុះខែកញ្ញា ឆ្នាំ១៩៧៧ ដែលគេបានបង្ហាញជូនដល់អង្គជំនុំជម្រះរួចមកហើយ គឺឯកសារ D243/2.1.12 ហើយទំព័រដែលខ្ញុំចង់បង្ហាញនោះ

គឺ ជាភាសាខ្មែរ 00063141 អង់គ្លេស 00486230 ហើយជាភាសាបារាំង 00492816។

**លោក ឌេល លីសាក់៖**

ហើយលោកប្រធាន ខ្ញុំសូមការអនុញ្ញាតឲ្យមានការបង្ហាញជូនលោក នួន ជា នូវឯកសារនេះ សូមការអនុញ្ញាតពីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជម្រះអនុញ្ញាត សូមអញ្ជើញ!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោក នួន ជា ខ្ញុំនឹងបង្ហាញជូននូវសេចក្ដីថ្លែងការណ៍ នៅក្នុងខែកញ្ញា ១៩៧៧ អំពីទង់បដិវត្តនេះ។ ហើយខ្ញុំសូមអាននូវសេចក្ដីថ្លែងការណ៍នេះ។ សូមដកស្រង់៖ “ភាពផ្ទុយគ្នាគឺកើតចេញអំពីការទំនាស់នេះ ដោយសារហេតុម៉េចក៏មានទំនាស់នេះដោយសារ ថាវណ្ណៈម្ចាស់ដី ទាមទារមានការក្ដោបក្ដាប់អំណាច ហើយអំណាច និងពួកគ្រូបាចារ្យ នៃវណ្ណជិះជាន់ ផ្សព្វផ្សាយនយោបាយទំនាស់នេះ។ មនោគមវិជ្ជាមានដូចជាមកពី អកុសលពីជាតិមុន មកពីព្រេងវាសនាពីជាតិមុន ជាការកាន់កាប់កសិករមិនឲ្យឃើញទំនាស់ គឺសេចក្ដីថ្លែងនេះបានធ្វើឡើងជាផ្នែកមួយនៃការពន្យល់អំពីមាគ៌ាបក្សដែលបានអនុម័តនៅក្នុងសន្និបាតឆ្នាំ១៩៧៦”។ ខ្ញុំសូមសួរថាតើឯកសារនេះគឺបានបង្ហាញនូវអំពីមនោគមវិជ្ជាទាក់ទងទៅនឹងវណ្ណៈជិះជាន់ ដើម្បីឲ្យខ្លួនក្លាយទៅជាម្ចាស់នៃអំណាចនោះឬក៏យ៉ាងម៉េចដែរ?

[១៤:២៤:៥៤]

**ឆ៖** សូមគោរពលោកប្រធាន ខ្ញុំសូមមើលឯកសារហ្នឹង។

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញាមានឯកសារជាលាយលក្ខណ៍អក្សរជាក្រដាសទេ។

សូមផ្ដល់ឲ្យទៅលោក នួន ជា តាមរយៈមន្ត្រីច្បាប់-- មន្ត្រីគ្រប់គ្រងតុលាការ។

[១៤:២៦:០៦]

**លោក នួន ជា៖**

សូមគោរពលោកប្រធាន ឯកសារទង់បដិវត្តន៍នេះមិនមែនធ្វើបែបនេះទេ ធ្វើជាឯកសារតែម្ដង។ ធ្វើជាសៀវភៅ ហើយដូច្នេះ អានេះមិនដឹងយកពីណា ខ្ញុំមិនដឹងដែរ។ អានេះមិនសមជាសៀវភៅដែលធ្វើជាទង់បដិវត្តន៍ ជាសៀវភៅ។ តើលោកមានទេ? ព្រោះអានេះអ្នកណាក៏ធ្វើបានដែរ បោះពុម្ពនេះ។

**លោក ឌេល លីសាក់៖**

លោក នួន ជា នេះគ្រាន់តែជាឯកសារថតចម្លង។ ហេតុដូច្នេះឯងវាមិនដូចគ្នាទៅនឹងសៀវភៅទស្សនាវដ្ដីទង់បដិវត្តន៍តែម្ដងនោះទេ គ្រាន់តែយើងស្រង់នូវពាក្យសម្ដី សុន្ទរកថាសំខាន់ៗមួយចំនួនទាក់ទងទៅនឹងសន្និបាតបក្ស១៩៧៧ ខួបបក្សដែលទាក់ទងទៅនឹងខួបកំណើតរបស់បក្ស បដិវត្តន៍កម្ពុជាដែលត្រូវប្រកាសឲ្យពិភពលោកដឹងនោះ។ អ៊ីចឹង ខ្ញុំសុំសួរលោកជាថ្មីម្ដងទៀត ដោយខ្ញុំមើលយកនូវការដកស្រង់សម្ដីនៅទំព័រ៤៤ នៃសុន្ទរកថារបស់ ប៉ុល ពត ហើយសូមឲ្យឆ្លើយសំណួររបស់ខ្ញុំ។ ឯកសារនេះគឺវាពាក់ព័ន្ធទៅនឹងគឺ ដើម្បីនិយាយពាក់ព័ន្ធទៅនឹងវណ្ណៈជិះជាន់ វណ្ណៈពួកម្ចាស់ដី កន្លែងនេះឯង គឺខ្ញុំសួរថា តើវាអ៊ីចឹងមែនទេ?

[១៤:២៧:៤៣]

**លោក នួន ជា៖**

សូមគោរពលោកប្រធាន ខ្ញុំទទួចសុំឯកសារ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី!

**លោក សុន អរុណ៖**

សូមអរគុណ ខ្ញុំមានគំនិតដូចលោក កូនក្ដីខ្ញុំអ៊ីចឹង អំមិញ ប៉ុន្តែគាត់មានប្រសាសន៍មុនទៅ។ ជាពិសេស ដើម្បីបង្ហាញជាសក្ខីកម្មមែនទែន សូមឲ្យយកឯកសារដើម ឬមិនបានដើមទេ សូមឲ្យបានទាំងមូល យកមកក្រដាសអ៊ីចឹង ដូចគាត់មានប្រសាសន៍អ៊ីចឹង មិនដឹងជាឯកសារអី មិនដឹងយកពីណាមកអ្នកណាជាចេញឯកសារហ្នឹងទាំងអស់មក មកជូនលោកព្រះរាជអាជ្ញា។ សូមអរគុណ។

[១៤:២៨:១៩]

**លោក ឌេល លីសាក់៖**

គឺឯកសារនេះបានដាក់ជូនលោកស្រីចៅក្រម ខាតវ៉ាយថ៍ នៅថ្ងៃអង្គារ ហើយក៏បានបង្ហាញជូននោះផងដែរ ដូច្នេះខ្ញុំសូមឲ្យចង់បន្តដំណើរការនីតិវិធីនេះតទៅទៀត ហើយសូមអនុញ្ញាតឲ្យជនជាប់ឆ្លើយទៅនឹងសំណួររបស់ខ្ញុំ។

**ប្រធានអង្គជំនុំ៖**

ជាទូទៅឯកសារ ដែលយើងប្រើប្រាស់នៅក្នុងប្រព័ន្ធព័ត៌មានវិទ្យានេះគឺត្រូវបានរៀបចំ។ ដូច្នេះ

មិនអាចនៅជាសៀវភៅ នៅជាក្រដាសដូចដែលឯកសារជាក្រដាសនោះឡើយ។ ឯកសារទាំងអស់ សូម្បីតែឯកសារនិពន្ធ១សៀវភៅ និពន្ធផ្សេងៗដែលយើងបញ្ចូលទៅក្នុងកម្មវិធីដែលសម្រាប់គ្រប់គ្រងសំណុំរឿងនៅក្នុងប្រព័ន្ធ *ហ្សាយឡេប* ប្រព័ន្ធព័ត៌មានវិទ្យានេះគឺទម្រង់ឯកសារ គឺដូច្នេះ។ ហើយឯកសារនេះគឺខាងសហព្រះរាជអាជ្ញាផ្អែកលើឯកសារដែលមាននៅក្នុងសំណុំរឿង ហើយកាលពីថ្ងៃមុនគឺលោកស្រី ខាតវ៉ាយថ៍ ដែលគាត់បានសួរដេញដោលដោយយោងទៅដល់ទស្សនាវដ្ដីនេះ បានសម្រេចដាក់ចំពោះមុខអង្គជំនុំជម្រះរួចហើយ។

ដូច្នេះ បញ្ហានេះគឺយើងអាចដំណើរការបាន ហើយប្រសិនបើយើងរកឯកសារផ្សេងទៀត ដូចទម្រង់ឯកសារដើមសុទ្ធសាធ ហើយនៅក្នុងគ្រប់ឯកសារទាំងអស់នោះ ប្រហែលជាយើងត្រូវការបច្ចេកទេសថ្មី ហើយនិងការរៀបចំជាថ្មីមិនខាន ពីព្រោះឯកសារមានច្រើនរាប់ជិតកន្លះលានទំព័រឯណោះ។

នេះជាបញ្ហាលើបញ្ហាបច្ចេកទេស លើការគ្រប់គ្រងសំណុំរឿងដែលមានទំហំធំធេងដូច្នេះ។

សូមអញ្ជើញលោក សុន អរុណ។

**លោក សុន អរុណ៖**

ខ្ញុំថា លោកប្រធានមានប្រសាសន៍អ៊ីចឹងវាស័ក្តិសមម្យ៉ាង ក៏ប៉ុន្តែនេះជាតុលាការ។ ហើយតុលាការហ្នឹងធំធេងណាស់ អ្វីដែលធ្វើដាក់មកមិនគ្រប់គ្រាន់ អ្វីដែលយកមកអ៊ីចឹង អាហ្នឹងហាក់ដូចជាមិនមានអីជាជាក់លាក់-- មិនមានអ្វីជាជាក់លាក់ទេ យកក្រដាសមក។ ហើយឥឡូវខ្ញុំសួរថា ឯកសារហ្នឹងក្លែង ឬក៏ឯកសារពិត? ខ្ញុំសូមសួរ ឆ្លើយឲ្យខ្ញុំអាហ្នឹងមុនសិនមក ថាឯកសារហ្នឹងក្លែង ឬពិត? បើសិនជាពិតទេ សូមឲ្យខ្ញុំជាមេធាវីការពារ សូមឲ្យកូនក្តីខ្ញុំមានជំនឿទុកចិត្តទៅលើតុលាការផង ទៅលើការដាក់ឯកសារហ្នឹងផង។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ឯកសារនេះបានដាក់ដោយអង្គជំនុំជម្រះ ដោយលោកស្រី ស៊ីលវៀ ខាតវ៉ាយថ៍ កាលពីអំឡុងពេលដែលគាត់បញ្ចប់នូវការសួរដេញដោលចំពោះជនជាប់ចោទ។ ហើយឯកសារនេះមាននៅក្នុងសំណុំរឿង។ ប្រសិនបើឯកសារនេះមានពិត មិនពិត គឺលោកមេធាវីអាចបដិសេធចោលតាំងពីនីតិវិធីនៃការបញ្ចប់កិច្ច ចេញដីកាដំណោះស្រាយឯណោះ ដើម្បីបដិសេធនូវឯកសារនេះ។

សូមអញ្ជើញលោកនួន ជា!

[១៤:៣២:០៨]

**លោក នួន ជា៖**

នឹងឲ្យជ្រះស្រឡះទាំងអស់គ្នា ពីព្រោះគោលការណ៍របស់តុលាការនេះ ថែងថា "ស្វែងរកការពិតយុត្តិធម៌" ហើយខ្ញុំថែមទៀតថា "មានប្រយោជន៍"។ ដូច្នោះ ឯកសារអ្នកណាក៏ធ្វើបានដែរ បើតាមខ្ញុំមើល ដូច្នោះបានជាខ្ញុំទទូចហើយទទូចទៀត សូមឯកសារដើមដែលបោះពុម្ពនោះ យកមកខ្ញុំមើល តើអ្នកណាសរសេរ? ហើយសរសេរយ៉ាងម៉េច? អានេះបានវាជាក់ច្បាស់ បញ្ជាក់ថាតុលាការនេះជាតុលាការស្វែងរកការពិតមែន ស្វែងរកយុត្តិធម៌មែន មិនមែនតុលាការក្លែងក្លាយទេ។

បើលោករកឯកសារការពិតមិនឲ្យខ្ញុំ-- ឯកសារដើមឲ្យខ្ញុំមិនបាន ខ្ញុំមិនទទួលទេឯកសារនេះ។ សូមបដិសេធ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៣៤:៥០]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះឯកសារគឺនៅក្នុងសំណុំរឿង ដែលគ្រប់គ្រងដោយតុលាការ ហើយបញ្ហានេះគឺយើងបានប្រើប្រាស់តាំងពីគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីតាំងពីស៊ើបសួររហូតដល់ពេលនេះ។ ហើយពេលនេះ គឺឯកសារកន្លងមកថ្មីៗជាច្រើនក៏យើងអនុវត្តទម្រង់ដូចគ្នា និងការបង្ហាញឯកសាររបៀបនេះដែរ។ បានន័យថាឯកសារហ្នឹងគឺ មានសុពលភាពនៅក្នុងការជាឯកសារសម្រាប់ដាក់ដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ។ ពីព្រោះជាឯកសារនៅក្នុងសំណុំរឿង ហើយភាគីអាចលើកយកមកដេញដោលបាន លើកលែងតែឯកសារថ្មីទេ ដែលថាត្រូវស្នើសុំការសម្រេចពីអង្គជំនុំជម្រះ។

ហេតុដូច្នេះគឺលោកពិនិត្យមើលទៅ បើសិនបើលោកពិនិត្យមើលកម្រិតមួយទំព័រមិនច្បាស់លាស់ទេ លោកអាចពិនិត្យមើលគ្រប់ទំព័រជាមុនសិនទៅ មុននឹងឆ្លើយនឹងសំណួរ ហើយលោកគប្បីឆ្លើយនឹងសំណួរដែលសួរនេះ។

[១៤:៣៦:០៣]

**លោក នួន ជា៖**

មិន-- របស់ឯកសារទង់ក្រហមទេ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន គឺថាកូនក្តីខ្ញុំលើកនូវចំណុចសំខាន់។ សំណួរថាតើឯកសារនេះ បានដាក់ជូននៅចំពោះមុខអង្គជំនុំជម្រះដែរឬទេ ឬក៏ជាឯកសារមួយដែលមិនពិតនោះទេ? ហើយនៅក្នុងពេលនេះ គឺថាកូនក្តីរបស់ខ្ញុំ គឺគាត់ៗចង់ឲ្យសុំបញ្ជាក់អំពីការពិតនូវយថាភាពរបស់ឯកសារនេះ។ អាចមានអ្នកណាម្នាក់កូពីឯកសារនេះមក ប៉ុន្តែយើងចង់ឲ្យបង្ហាញនៅឯកសារដើម្បីបង្ហាញនូវការពិត ថាឯកសារនេះគឺមានសុពលភាព។

អ៊ីចឹងយើងខ្ញុំសូម ខ្ញុំគិតថាឯកសារដើមប្រាកដជាវានៅកន្លែងណាមួយហើយ។

[១៤:៣៧:២៨]

**ប្រធានអង្គជំនុំ៖**

មន្ត្រីច្បាប់ មន្ត្រីរដ្ឋបាលតុលាការបញ្ចាំងនូវឯកសារទស្សនាវដ្តីទង់បដិវត្តន៍ឆ្នាំ៧៧នេះ ទាំងស្រុងនៅលើកញ្ចក់ទូរទស្សន៍ ដោយចាប់ពីទំព័រដំបូង រហូតជារៀង រហូតដល់ចប់ រួចហើយសុំស្តាយនូវទំព័រដែលសហព្រះរាជអាជ្ញាត្រូវសួរដេញដោល។

**លោក ខេល លីសាក់៖**

លោកប្រធាន មុននឹងចាប់ផ្តើមនេះ ខ្ញុំសូមសួរសំណួរទូទៅ ទៅនឹងសាក្សី ហើយសុំត្រឡប់មកកាន់ឯកសារនេះវិញបានដែរឬទេ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញ!

[១៤:៣៨:២៥]

**សួរដោយលោក ខេល លីសាក់៖**

**ស៖** ហេតុផលមួយ លោក នួន ជា ដែលខ្ញុំចង់សួរលោកនោះ ទាក់ទងទៅនឹងឯកសារយោងនេះគឺថា ខ្ញុំបានកត់សម្គាល់ឃើញថានៅក្នុងសេចក្តីថ្លែងការណ៍បើករបស់លោក លោកបានចាប់ផ្តើមប្រើដោយលោកធ្វើការគោរពចំពោះព្រះសង្ឃ ហើយថ្ងៃនេះក៏លោកបានគោរពចំពោះព្រះសង្ឃទៀត ហើយខ្ញុំបានពិនិត្យមើលទៅលើសុន្ទរកថាក្នុងពេលដែលលោកធ្វើជាមេដឹកនាំខ្មែរក្រហម ហើយខ្ញុំមិនដែលឃើញសុន្ទរកថាណាមួយរបស់លោកបានក្រាបថ្វាយបង្គំព្រះតេជព្រះគុណ ឬក៏ព្រះសង្ឃនោះទេ។ ដើម្បីពន្យល់ សូមលោកពន្យល់ជូនតុលាការផងបានទេ ថានៅពេលលោកថ្លែងសុន្ទរកថាទាំងឡាយ

នៅក្នុងរបបនោះ គឺថាលោកមិនដែលក្រាបថ្វាយបង្គំដល់ព្រះសង្ឃជាទីសក្ការៈទេ។

**លោក នួន ជា៖**

**ឆ៖** គោរពលោកប្រធាន សុន្ទរកថាមួយជាសុន្ទរកថានយោបាយ។ យើងខ្ញុំមិនចង់យកព្រះពុទ្ធសាសនាមកលាយឡំនឹងនយោបាយទេ។ ក៏ប៉ុន្តែពេលនោះ ហើយពេលនោះ ក៏គ្មានព្រះសង្ឃចូលរួមដែរ បើធ្វើបាតុកម្មធ្វើអីនោះ។ ដូច្នេះ បើយកព្រះសង្ឃមកលាយឡំនឹងនយោបាយ វាច្របូកវាច្របល់អស់ហើយ។ ដូច្នោះបានជាខ្ញុំមិនដែលនិយាយអំពីក្រាបថ្វាយព្រះសង្ឃអីទេ។

ក៏ប៉ុន្តែសួរថា តើយើងបដិសេធព្រះសង្ឃទេ អត់មានបដិសេធទេ។ ពីព្រោះអី? ការយល់ព្រះពុទ្ធសាសនានេះ ត្រូវយល់ឲ្យត្រូវ។ ខ្លឹមសារបេះដូងរបស់ព្រះពុទ្ធសាសនាគឺស្អី? បេះដូងរបស់ព្រះពុទ្ធគឺ សីល សមាធិ បញ្ញា នេះដែលអនុវត្តនៅជីវភាពប្រចាំថ្ងៃ។ ដូច្នោះអ្នកខ្លះដែលចោទថា កម្ពុជាប្រជាធិបតេយ្យបំផ្លាញព្រះពុទ្ធសាសនា បំផ្លាញអីនេះ នេះគាត់និយាយខុសទេ មិនយល់អំពីខ្លឹមសារ ឬបេះដូងរបស់ព្រះពុទ្ធសាសនាទេ។ ព្រះណ៎ា កាលពីសម័យព្រះមានកុដិមានអីណា។ ព្រះលោកប្រសូត្រក្នុងព្រៃ ហើយត្រាស់ដឹងក្នុងព្រៃទេ។ ដូច្នោះ កុំយកបញ្ហាហ្នឹងមកវ៉ៃកម្ពុជាប្រជាធិបតេយ្យនោះ វាមិនត្រូវទេ។ ត្រូវគិត ស្អីដែលជាព្រះពុទ្ធសាសនា មិនមែនវត្ត មិនមែនអារាមជាសំខាន់ទេ។ វត្តអារាម គ្រាន់តែជាបូជនីយដ្ឋានន ក៏ប៉ុន្តែខ្លឹមសារនេះ ដូចដែលខ្ញុំបានជម្រាបអំមិញអីចឹង។ ហើយក្រៅពីនេះ មេត្តា ករុណា មុទិតា ឧបិកា ហិរិឱត្តប្បៈ ខ្លាចបាប ខ្មាសបាប ស្អប់បាប មិនប្រព្រឹត្តអំពើបាប។ នេះហើយ សុទ្ធតែខ្លឹមសារព្រះពុទ្ធសាសនា។

[១៤:៤២:១៩]

តើព្រះពុទ្ធសាសនា ខ្លឹមសារនេះនៅក្នុងបេះដូងរបស់អ្នកព្រះពុទ្ធបរិស័ទគ្រប់គ្នាទេ? អត់ទេ។ ដូច្នោះរូបភាព វាផ្សេង ឯខ្លឹមសារនេះ វាផ្សេង។ ខ្លឹមសារនៅក្នុងបេះដូង ពិតមែនតែគេមិនបានថ្វាយព្រះបង្គំមិនបានអុជធុកក៏ដោយ ក៏ប៉ុន្តែក្នុងចិត្តបេះដូងរបស់គេណ៎ គេមាន មេត្តា ករុណា មុទិតា ឧបិកា ហិរិឱត្តប្បៈ ដែលជាធម៌ទ្រទ្រង់លោក។ នេះសុទ្ធតែព្រះពុទ្ធសាសនា ធាតុពិតនៃព្រះពុទ្ធសាសនាគឺអីចឹង។ ខ្ញុំមិនមែនជាអ្នកបួសអ្នកអីប៉ុន្មានទេ ប៉ុន្តែខ្ញុំរៀនដែរ។

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណ ដោយសារពេលវេលាសមល្មមនឹងសម្រាកហើយ។ អីចឹង អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅ រហូតដល់បី និងប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ច

ពិភាក្សាដេញដោល។ ហើយអនុរក្សមន្ទីរឃុំឃាំងនាំលោក នួន ជា ទៅកាន់កៅអីនៅពីក្រោយមេធាវីរបស់គាត់ ហើយឲ្យនាំគាត់មកកាន់ទីនេះ នៅឲ្យបានមុនពេលអង្គជំនុំជម្រះចូលមកកាន់អសនៈ។

*(សវនាការសម្រាកពីម៉ោង ១៤:៤៣នាទី ដល់ម៉ោង ១៥:១២នាទី)*

[១៥:១១:៥៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ។ សូមអង្គុយចុះ!

សូមអញ្ជើញ!

**លោក អាកឡូរ វែកគែន៖**

បាទ, សូមអរគុណលោកប្រធាន។ បាទ ខ្ញុំសូមត្រឡប់មកនិយាយអំពីបញ្ហាដែលយើងទើបលើកឡើងអម្បាញ់មិញនេះ ជាមួយនឹងឯកសារដែលថតចម្លងដែលដាក់ជូនលោក នួន ជា។ បើយើងដឹងថា-- យើងជាមេធាវីរបស់លោក ខៀវ សំផន ទេ ប៉ុន្តែក៏ថាជាបញ្ហាដែលពាក់ព័ន្ធនឹងយើងទាំងអស់គ្នាដែរ។ ពីព្រោះថានៅពេលដែលខ្ញុំធ្វើការស្រាវជ្រាវអម្បាញ់មិញនេះទាក់ទងស្ថាននេះនោះ គឺខ្ញុំបានឃើញសេចក្ដីសម្រេចមួយដែលចេញដោយអង្គជំនុំជម្រះនៅក្នុងរឿងក្ដីរបស់ ឌុច គឺជាសេចក្ដីសម្រេចចុះថ្ងៃទី២៦ ឧសភា ឆ្នាំ២០០៩ ដែលមានលេខ E43/4 ដែលនៅក្នុងសេចក្ដីសម្រេចនេះ អង្គជំនុំជម្រះបានបង្ហាញថា ភាពមិនស្របច្បាប់ដែលនឹងត្រូវអាចលើកឡើងដោយភាគី លើឯកសារដែលខ្លួនចង់បង្ហាញនោះជូនអង្គតុលាការមិនមានការការពារទេ។ គឺថានៅនឹងឯកសារ 76.7 ខ្ញុំគិតថា-- ខ្ញុំមិនដឹងថា ការបកប្រែនោះត្រឹមត្រូវដែរឬក៏អត់ទេ មុននឹងពេលដែលយើងកាត់ផ្ដាកអម្បាញ់មិញហ្នឹង ថាខ្លឹមសារនោះវាបញ្ជោសពីហ្នឹង ដូចលោកប្រធានបានប្រាប់អម្បាញ់មិញនោះ គឺថានៅពេលដែលពុំមានឯកសារណាដែលទទួលការបដិសេធមុនដីកាដំណោះស្រាយ គឺថាឯកសារទាំងអស់នេះ គឺត្រូវបានចាត់ទុកថា វាទទួលយកបានហើយ មិនចាំបាច់ពិភាក្សាអីទៀតនោះទេ។

[១៥:១៤:១៨]

បាទ, ខ្ញុំយល់ឃើញថា ដើម្បី គឺថាគោលជំហររបស់ខាង នួន ជា ហើយនិងខាងខ្ញុំ គឺថាព្រោះវាពាក់ព័ន្ធទាំងអស់គ្នានៅក្នុងរឿងក្ដីរបស់ ឌុច អង្គជំនុំជម្រះមិនបានធ្វើសេចក្ដីសម្រេចក្នុងទិសដៅនេះទេ គឺថាបញ្ជោសពីនេះវិញ។ អង្គជំនុំជម្រះបានបញ្ជាក់យ៉ាងច្បាស់ថា ដីកាដំណោះស្រាយមិនគ្របដណ្ដប់

លើមោឃភាពនៃឯកសារ ដែលនឹងដាក់ជូនមកអង្គជំនុំជម្រះនោះទេ។

ដូច្នេះ ដើម្បីបំភ្លឺស្ថានភាពនេះ ខ្ញុំគ្រាន់តែចង់សូមឲ្យ-- សួរដល់អង្គជំនុំជម្រះថា តើគោលជំហររបស់អង្គជំនុំជម្រះទាក់ទងនឹងប្រធានបទនេះ បញ្ហានេះគឺថាដូចនៅក្នុងករណី ឌុច ដែរ ឬក៏ដូចគ្នាដែរ ឬក៏ខុសពីនេះ? ខ្ញុំសូមបន្ថែមទៀតថា ពីព្រោះថាអម្បាញ់មិញនេះ គឺយើងបានរំឭកថាខ្ញុំទើបតែមកដល់តុលាការនេះ អ៊ីចឹងខ្ញុំមិនស្គាល់សំណុំរឿងគ្រប់គ្រាន់ ដូចជា អនុស្សរណៈ ឬក៏សំណើដែលបានដាក់ផ្សេងៗនោះ។ អ៊ីចឹងហើយបានថា ឲ្យខ្ញុំខឹងឆាប់ខឹងឆាប់អីអ៊ីចឹងទៅ ទាក់ទងនឹងបញ្ហាបកប្រែអីជាដើម។ ហើយយើងមានឯកសារជាសាធារណៈមួយដែលថា អនុស្សរណៈរបស់សាលាដំបូងដែលចុះថ្ងៃទី២៥ តុលា ឆ្នាំ២០១១ ដែលខ្ញុំបានដាក់នៅលើតុរបស់លោកចៅក្រម ឡាវែន៍ អម្បាញ់មិញហ្នឹង នៅទំព័រទីបី វាមានការចង្អុលបង្ហាញប្រាប់ភាគីថា ភាគីត្រូវតែសុំទទួលការបកប្រែឯកសារដែលខ្លួនចង់បង្ហាញនៅចំពោះមុខតុលាការហ្នឹង ជាបីភាសា។

[១៥:១៦:២១]

ហើយក៏ចង្អុលបង្ហាញផងដែរថា បើសិនជាធ្វើមិនបានទេ អ៊ីចឹងសមត្ថភាពនៃការប្រើប្រាស់ឯកសារនេះនឹងកាត់បន្ថយ។ បើថា-- ខ្ញុំយោងទៅលើបញ្ហានេះឯង នៅពេលដែលខ្ញុំបាននិយាយអម្បាញ់មិញនេះ គឺថាគោលជំហររបៀបនេះ គឺថាធ្វើឲ្យខាងភាគីការពារក្តី ឬក៏ខាងព្រះរាជអាជ្ញា ឬដើមបណ្តឹងរដ្ឋប្បវេណីនេះ មានបន្ទុកធ្ងន់ណាស់ដែលមិនអាចទទួលយកបានទេ។ ពីព្រោះថា ឯកសារទាំងអស់នេះ គួរតែត្រូវបានបកប្រែជាមុនហើយជាស្រេច។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញា!

**លោក វីល្លៀម ស្មីត៖**

គឺថាទាក់ទងទៅនឹងរឿងក្តី ឌុច ហើយនិងវិធាននៃការបង្ហាញភស្តុតាងហ្នឹងគឺត្រូវបានអនុវត្ត។ ក្នុងរឿងក្តី ឌុច នោះមកគឺថាកិច្ចប្រជុំពេញអង្គបានធ្វើវិសោធនកម្ម ហើយតុលាការនេះបានអនុវត្តហើយ។ ហើយភាគីចង់ដាក់ឯកសារចំពោះមុខអង្គជំនុំជម្រះអាចធ្វើបាន មុននឹងពេលសវនាការ ហើយតុលាការក៏បានសូមឲ្យភាគីធ្វើការជំទាស់ទៅនឹងឯកសារនោះ មុនពេលចូលដល់នីតិវិធីនេះ។ ហើយគឺថាការជំទាស់គឺត្រូវធ្វើនៅថ្ងៃទីមួយ ខែ១១ ប៉ុន្តែវាមិនឃើញមានការជំទាស់ពីមេធាវីរបស់ នួន ជា ទេ ទាក់ទងទៅនឹងទង់បដិវត្តន៍នេះ ដែលថាគាត់មិនជឿជាថាជាច្បាប់ចម្លងត្រឹមត្រូវ ឬមិនត្រឹមត្រូវនោះ។

[១៥:១៨:០៨]

ដូច្នេះគឺថា គេជំទាស់ថា តាមពិតមិនមែនជាច្បាប់ចម្លងចេញពីច្បាប់ត្រឹមត្រូវរបស់ទង់បដិវត្តន៍នេះជាបញ្ហា។ ចំពោះបញ្ហាមួយទៀត ទាក់ទងទៅនឹងចំណុចដែលតុលាការសួរឲ្យ-- សូមឲ្យតុលាការ-- សូមឲ្យសហព្រះរាជអាជ្ញាដាក់ជូន ហើយជូនដំណឹងដល់ភាគីទៅដល់តាមកាលវេលាដូចចៅក្រម ឡាវ៉ែន៍ បានធ្វើ។ ហើយអង្គជំនុំជម្រះនឹងធ្វើសេចក្តីសម្រេចអំពីភាពទទួលយកបាននៃភស្តុតាង ហើយថ្ងៃនេះតុលាការក៏បញ្ជាក់ដែរថា នឹងធ្វើសវនាការមួយទៅលើបញ្ហានេះ ដែលនិយាយអំពីការទទួលយកឯកសារជាភស្តុតាងហ្នឹង។ អ៊ីចឹងគំនិតនោះ គឺថាបញ្ហាហ្នឹងត្រូវតែយល់ ហើយមិនត្រូវលើកឡើងម្តងហើយម្តងទៀតទេ។ ពីព្រោះថាការប្រើច្បាប់ចម្លងនេះ គឺយើងនឹងលើកឡើងនិយាយនៅក្នុងវគ្គក្រោយ។ ដូច្នេះគឺថាមិនមានប្រការណាមួយដែលថាត្រូវ-- មិនត្រូវប្រើច្បាប់ចម្លងនោះទេ លើកលែងតែមានការជំទាស់នោះគឺថាការចម្លងហ្នឹងវាខុសពីអ្វីដែលជាច្បាប់ដើម។

[១៥:១៩:២៣]

ដោយផ្អែកលើមូលដ្ឋានថាច្បាប់ចម្លងនោះ គឺតាមពិតមិនមែនជាច្បាប់ចម្លងនៃច្បាប់ដើម។ អាហ្នឹងបានករណីដែលយើងមិនអាចទៅមុខបាន។ ប្រសិនបើយើងធ្វើការផ្អែកលើថាច្បាប់ចម្លងក៏ដាក់ដេញដោលបានដែរ បើសិនជាវាត្រឹមត្រូវតាមនីតិវិធីហើយនោះ។ អ៊ីចឹងមេធាវីការពាររបស់ នួន ជា នោះគឺមានឱកាសក្នុងការបញ្ជាក់ឲ្យច្បាស់លាស់ថា ទង់បដិវត្តន៍ ជាច្បាប់ចម្លងហ្នឹងមិនមែនជាកូពីច្បាប់ចម្លងចេញពីច្បាប់ដើម។ ប៉ុន្តែគាត់មិនបានឆ្លើយអ៊ីចឹងទេ នៅក្នុងការឆ្លើយតបនោះ ហើយមេធាវីការពារក្តីក្នុងករណីនេះមានពេលច្រើនឆ្នាំ ក្នុងការពិនិត្យមើលកាសែតទង់បដិវត្តន៍ ថាតើច្បាប់ចម្លងនេះពិតជាច្បាប់ដើមឬអត់នោះ។ គេមិនត្រូវរង់ចាំមកលើកនៅពេលនេះនោះទេ។ មេធាវីការពារក្តី បើសិនជាខ្លួនមានការជំទាស់រឹងមាំចំពោះច្បាប់ចម្លងនៃឯកសារនេះគាត់គួរតែលើកឡើងថា វាមិនពិតប្រាកដនោះវាមានមូលហេតុអីហើយត្រូវលើកឡើងនៅក្នុងមុនពេលសម្រេចដែលបើកសវនាការនេះ ឬដល់ពេលសវនាការមួយដែលនិយាយពីបញ្ហានោះ។ សូមអរគុណ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ ប៉ុន្តែលើកក្រោយលោកមេធាវីគួរតែត្រូវបានសុំការអនុញ្ញាតពីប្រធានអង្គជំនុំជម្រះជាមុនសិន មុននឹងផ្តល់ឲ្យលោកនិយាយ មិនអាចចុចហើយឡើងនិយាយដោយមិនមានរបៀបរៀបរយទេ។

[១៥:២១:១៥]

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំសូមអនុញ្ញាតទាល់តែមីក្រូហ្វូនឮបានខ្ញុំសូមអនុញ្ញាត បើតាមពិតគឺខ្ញុំក្រោកឈរដើម្បីបង្ហាញលោកប្រធានអំពីចេតនារបស់ខ្ញុំដើម្បីស្នើសុំ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំសូមអនុញ្ញាតឆ្លើយតបទៅនឹងខាងតំណាងសហព្រះរាជអាជ្ញា ហើយយើងបានបញ្ជាក់ពីការជំទាស់របស់យើង ដែលថា-- ដែលព្រះរាជអាជ្ញាចង់ដាក់ជូនដេញដោលនេះ យើងគិតថា យើងប្រកាន់ជំហរគឺថា យើងបានធ្វើលើសពីពីរបីដងដូច្នេះ ជាពិសេសគឺដំណាក់កាលដើម្បីបញ្ជាក់ពីយថាភាពនៃឯកសារ ហើយនៅក្នុងចំណុចជាទូទៅកូនក្ដីរបស់ខ្ញុំ គាត់បានលើកចំណុចជាក់លាក់ទៅនឹងចំណុចមួយដែលជាការជំទាស់របស់គាត់។ ខ្ញុំយល់ថា នេះជាការគ្រប់គ្រាន់ហើយ ជាការជំទាស់ ហើយយើងត្រូវតែបញ្ជាក់ពីយថាភាពនៃឯកសារទាំងនេះ មុនពេលយើងចូលដល់ការដេញដោល ហើយខ្ញុំឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញាអំមិញដែរ គឺថាទុករយៈពេលពីរបីសប្ដាហ៍ដើម្បីពិភាក្សាអំពីការទទួលយកឯកសារនេះមកដេញដោល។ ប៉ុន្តែ យើងនឹងនិយាយតែអំពីយថាភាពនៃឯកសារ និងការទទួលយកឯកសារនោះ។

[១៥:២២:៤៤]

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណនូវការសង្កេតរបស់ភាគីពាក់ព័ន្ធនឹងបញ្ហានេះ។

ហើយអង្គជំនុំជម្រះយល់ឃើញថា បញ្ហានេះគប្បីត្រូវបានយកទៅគិតគូរពិចារណា ហើយនិងសម្រេចពិភាក្សាសម្រេចអំពីបញ្ហានេះក្នុងវេលាសមស្របណាមួយ។ ឥឡូវនេះ យើងបន្តនូវកម្មវិធីនៃកាលកំណត់នៃកាលបរិច្ឆេទសម្រាប់ធ្វើសវនាការរបស់យើង តាមផែនការដែលបានគ្រោងទុក។ ហើយជាបន្តនេះអង្គជំនុំជម្រះសូមប្រគល់វេទិកាជូនទៅសហព្រះរាជអាជ្ញា ដើម្បីបន្តសួរសំណួរចំពោះលោក នួន ជា ប្រសិនបើនៅមានសំណួរផ្សេងទៀត ដែលមិនពាក់ព័ន្ធជាមួយនឹងទស្សនាវដ្ដីទង់បដិវត្តន៍នៅឆ្នាំ១៩៧៧។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សូមអរគុណលោកប្រធាន។ នៅពេលដែលយើងបានផ្អាកនោះលោក នួន ជា ខ្ញុំបានសួរលោកពីមូលហេតុថា ហេតុអីបានជាសុន្ទរកថារបស់លោក ក្នុងឋានៈជាមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ នោះមិនបានគោរពដល់ព្រះសង្ឃទេ។ ការពិតនោះគឺថា ហេតុផលនោះគឺថា បក្សបានហាមឃាត់ ឬក៏ផ្សឹកលោកសង្ឃទាំងអស់ហ្នឹងដែរឬទេ? តើនេះគឺជាការពិតឬក៏យ៉ាងម៉េចលោក នួន ជា?

[១៥:២៥:០០]

**លោក នួន ជា៖**

**ឆ៖** ខ្ញុំសូមជម្រាបលោកប្រធាន គោរពលោកប្រធាន! បក្សគ្មានវិធានការណាទៅបំបាត់ពុទ្ធសាសនាទេ។

**ស៖** នៅពេលដែលចៅក្រម ឡាវែន៍ សួរលោកពីម្សិលមិញនោះ លោក នួន ជា លោកបានពិភាក្សា ពីគោលការណ៍មួយចំនួនដែលថាពុទ្ធសាសនាដែលលោកជឿជាក់ថា គឺជា-- សមស្រប ឬក៏ស្របជាមួយនឹងបក្ស ការពិតនោះគឺថា ស្របទៅតាមគោលការណ៍ពុទ្ធសាសនាដែលមិនស្របទៅមាគ៌ាបក្សដែលរាប់ទាំងគោលការណ៍នៃកម្មផល ការជំនឿ អំពើអាក្រក់ពីជាតិមុន ហើយនិងផលវិបាក វាមកដល់ជីវិតបច្ចុប្បន្ន តើហ្នឹងជារឿងត្រឹមត្រូវដែរឬទេ ដែលថាទ្រឹស្តីកម្មផល គឺមិនស្របជាមួយនឹងមាគ៌ាបក្សទេ តើមែនឬទេ?

**ឆ៖** សូមជម្រាបលោកប្រធាន “កម្ម” ហើយនិង “ផល” ក្នុងព្រះពុទ្ធសាសនា តាមខ្ញុំពិចារណាខ្លះណ៎ា គ្មាន “កម្ម” ពីជាតិមុនជាតិណាទេ វា “កម្ម” បច្ចុប្បន្ននេះនែ៎ បច្ចុប្បន្ននេះដែលជា “កម្ម”។ ឯ “កម្ម” បច្ចុប្បន្ននេះ វាឲ្យ “ផល” បច្ចុប្បន្ននេះ។ “កម្ម”ល្អ វាឲ្យ “ផល” ល្អ “កម្ម” អាក្រក់ ឲ្យ “ផល” អាក្រក់។ ឯ “កម្ម” ពីជាតិមុនអ្នកណាទៅដឹង ទៅដឹងអាណាធ្វើ “កម្ម” អី ងាប់បាត់ទៅហើយ។ ក៏ប៉ុន្តែបច្ចុប្បន្ននៅរស់នេះនែ៎ ធ្វើអាក្រក់បានអាក្រក់ ធ្វើល្អបានល្អ។ ធ្វើកុសលកម្ម បានផលល្អ ធ្វើអកុសកម្ម បានផលអាក្រក់។ អានេះខ្ញុំជឿជាក់តែម្តង។ អ្នកណា កម្មរបស់អ្នកណា អ្នកនោះទទួល។

[១៥:២៧:២៧]

**ស៖** ខ្ញុំចង់សួរលោកថា១ តើបក្សចាត់ទុកថា គោលការណ៍ “កម្មផល” មិនស្របទៅនឹងគោលការណ៍ “កុម្មុយនីស្ត” ដែរឬទេ?

**ឆ៖** ខ្ញុំមិនយល់ពាក្យសំណួររបស់លោកទេ។

**សៈ** លោក នួន ជា តើលោកឆ្លើយដូចម្ដេចចំពោះសាក្សីរាប់ពាន់ដែលដាក់ចម្លើយនៅក្នុងសំណុំរឿងដែលនិយាយស្របគ្នាថា វត្តអារាមទាំងអស់ត្រូវបានបិទ ព្រះសង្ឃទាំងអស់ត្រូវបានផ្សឹក ហើយការប្រតិបត្តិសាសនាត្រូវបានហាមឃាត់ នៅអំឡុងពេលដែលលោកជាអនុលេខាបក្ស បើលោកមិនអាចឆ្លើយបានថា "គោលការណ៍ពុទ្ធសាសនា" វាផ្ទុយនឹង "គោលការណ៍បក្ស" នោះ?

[១៥:២៨:៣៣]

**លោក ម៉ៃខល ផេសមិន៖**

សូមទោសលោកប្រធាន ខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះ ដោយហេតុថា នេះដូចជាសេចក្ដីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាចង់ឲ្យកូនក្ដីរបស់ខ្ញុំឆ្លើយ។ ប៉ុន្តែសំខាន់បំផុតដែលខ្ញុំមិនអាចយល់អំពីផ្នែកនូវការពិភាក្សាថ្ងៃនេះនោះទេ។

**លោក ឌេល លីសាក់៖**

លោកប្រធាន យើងដឹងច្បាស់ហើយថា នៅក្នុងសំណុំរឿងសេចក្ដីសម្រេចក្នុងការហាមប្រាមព្រះពុទ្ធសាសនាគឺត្រូវបានធ្វើឡើងមុនខែមេសា ឆ្នាំ១៩៧៥ គឺសាក្សីច្រើនណាស់ដែលបង្ហាញភស្តុតាងបែបនេះ គឺនៅក្នុងតំបន់រំដោះដែលខ្មែរក្រហមបានកាន់កាប់នោះ។ ហើយយើងបានពិនិត្យមើលការអនុវត្តបែបនេះ ប៉ុន្តែចំណុចគ្នានេះគឺយើងចង់បញ្ជាក់សក្ខីកម្មរបស់សាក្សីអំពីបង្ហាញការពិតឲ្យគាត់បានដឹងថា តើខ្មែរក្រហមពិតជាបានបិទវត្តអារាម ហើយនិងផ្សឹកព្រះសង្ឃទាំងអស់ មែនឬក៏មិនមែន?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីការពារ នួន ជា មុន។

[១៥:៣០:០០]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ដែលខ្ញុំ ក្រែងតែខ្ញុំមិនយល់ថាហ្នឹងជាការពិតដូចសហព្រះរាជអាជ្ញា។ ប្រសិនបើលោកចង់តទល់ជាមួយកូនក្ដីរបស់ខ្ញុំ ដោយចម្លើយរបស់សាក្សីនោះ ម៉េចក៏លោកមិនលើកយកចម្លើយទាំងអស់នោះមក។ បើលោកគ្រាន់តែអាន គ្រាន់តែយោងបែបនេះ ថាតើលោកកូនក្ដីរបស់ខ្ញុំអាចនឹងតទល់ដូចម្ដេចបាន?

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ខ្ញុំបានឮពីខាងដើម ហើយប្រហែលថា ដោយមូលហេតុថា លោក នួន ជា

មិនមែនជាកូនក្ដីខ្ញុំទេ ប៉ុន្តែក្នុងពេលខ្លះ សហព្រះរាជអាជ្ញា គឺបង្ហាញ គឺនូវឯកសារយោងមួយចំនួន ហើយគឺនៅក្នុងសវនាការនេះ ចំណុចខ្លះ ហើយយើងនឹងអង្គជំនុំជម្រះនឹងធ្វើសេចក្ដីសម្រេច។ ប៉ុន្តែខ្ញុំគិតថាបើយើងចូលទៅដល់ចំណុចនេះ បញ្ហានេះ ដែលដូចសហព្រះរាជអាជ្ញាព្យាយាមនោះ គឺល្អបំផុតដោយគប្បីថា យើងប្រើសវនាការដំបូង ដើម្បីពិនិត្យមើលថាតើកំណត់ថាតើយើងត្រូវធ្វើនីតិវិធីដូចម្ដេច? បើមិនអ៊ីចឹងទេ យើងមិនដឹងច្បាស់ទេ ថាត្រូវទៅផ្លូវណា?

[១៥:៣១:១១]

ដើម្បីឲ្យបានរៀបចំសំណួររបស់យើងរបៀបណាទេ ពីព្រោះថា សហព្រះរាជអាជ្ញាបានទាញយកអត្ថប្រយោជន៍ ហើយដូចលោកស្រីចៅក្រម ខាត់វ៉ាយថ៍ បានជម្រាបគឺថាឯកសារ១៩៧៧ អ៊ីចឹងហើយលោកឮរឿងហើយ ប៉ុន្តែលោកសួរពីបញ្ហាក្រៅពីហ្នឹងទៅវិញ។ ហ្នឹងគឺថា យើងឃើញច្បាស់បែបនេះហើយ។ យើងមិនមានជំទាស់អ្វីនោះទេ ដរាបណាយើងដឹងថាស្ថិតនៅក្នុងបរិបទវង្វង់នៃនីតិវិធីនេះ។

ខ្ញុំត្រូវយកតែក្នុងដំណាក់កាលនីតិវិធីវគ្គទីមួយនេះ ដែលដាក់បញ្ចូលទាំងជនជាប់ចោទ ដែលត្រូវឆ្លើយ ដែលថានឹងត្រូវចោទសួរគ្រប់ដំណាក់កាលទាំងអស់នៅក្នុងសំណុំរឿងទាំងមូល ឬក៏ទៅតាមដំណាក់កាល? ឬក៏ថាអាចនឹងឆ្លើយពេលណាក៏បានប្រសិនបើភាគីអាចសួរត្រង់ណា ឆ្លើយត្រង់នុ៎ង? ហើយគេអាចចូលទៅដល់បញ្ហានោះបាន នៅពេលក្រោយ ឧទាហរណ៍ថា បើមិនទាន់ដល់ទេ យើងអាចពន្យារអ៊ីចឹងបានដែរឬទេ?

[១៥:៣២:១៨]

ខ្ញុំសូមអនុញ្ញាតបញ្ចប់។ ហើយបើសិនជាយើងគ្រាន់តែនិយាយថា យើងចង់រកការពិតតែប៉ុណ្ណឹងមិនគ្រប់គ្រាន់ទេ។ ខ្ញុំមិនគិតថា នោះជាចម្លើយនោះទេ កាលណាការមានការជំទាស់ ថាតើវាទាក់ទងទៅ ឬមិនទាក់ទងទៅនឹងដំណាក់កាលនៃសវនាការនោះ?

ដូច្នេះ យើងជំនុំជម្រះសវនាការរឿងក្ដីទាំងមូល ឬក៏យើងផ្អែកទៅលើតែវគ្គទីមួយនេះ? តើចំណុចណាមួយ? សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណច្រើន។ ដូច្នេះយើងកត់សម្គាល់ឃើញថា ផ្អែកតាមមតិជំទាស់របស់មេធាវីការពារក្ដីទៅនឹងសំណួរដែលសួរពាក់ព័ន្ធជាមួយនឹងកិច្ចការបញ្ហាសាសនានេះ ហើយបើយើងពិនិត្យលើឯកសារ

ឧបសម្ព័ន្ធ E124/7.2 នោះគឺមានកំហិតព្រំដែនដែលមិនលើកយកមកពិភាក្សា នូវបញ្ហាដែលពាក់ព័ន្ធធ្វើទុក្ខបុកម្នេញសាសនាទេ។ យើងធ្វើពិភាក្សាដេញដោលតែក្របខ័ណ្ឌនូវអង្គហេតុទាំងឡាយណា ដែលពាក់ព័ន្ធនឹងធ្វើទុក្ខបុកម្នេញខាងនយោបាយប៉ុណ្ណោះ។

[១៥:៣៣:២៧]

ដូច្នេះ ជំទាស់របស់មេធាវីមានប្រសិទ្ធភាព។ សហព្រះរាជអាជ្ញាកំហិតនូវសំណួរដែលពាក់ព័ន្ធជាមួយនឹងជនជាប់ចោទ ក៏ដូចជាជាមួយនឹងសាក្សីដទៃទៀតទៅតាមក្របខ័ណ្ឌនៃអង្គហេតុដែលបានកំណត់ធ្វើសវនាការដំណាក់កាលទីមួយ ហើយដោយឡែកចំពោះជនជាប់ចោទ គឺសូមលើកនូវអង្គហេតុដែលពាក់ព័ន្ធនឹងកន្សោមនៃកថាខណ្ឌ ដែលបានលើកឡើងនៅក្នុងការធ្វើសវនាការសម្រាប់វគ្គទីមួយ នៃអង្គហេតុសម្រាប់លើកមកធ្វើសវនាការ នៅវគ្គដំបូងនេះ។

លោកសហព្រះរាជអាជ្ញាអាចបន្តសំណួរបាន។ សំណួរផ្សេងទៀត ក្រៅពីសំណួរដែលពាក់ព័ន្ធជាមួយនឹងសាសនា។

[១៥:៣៤:២៦]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំអាចសូមបន្តទៅមុខបាន ប៉ុន្តែខ្ញុំសូមឆ្លើយតបទៅនឹងសំណួរដែលមេធាវីការពារក្តី គាត់បានលើកឡើងថា ដោយសារតែសេចក្តីថ្លែងការណ៍ធ្វើឡើងទាក់ទងទៅនឹងព្រះពុទ្ធសាសនានេះ គឺថាខ្ញុំចង់សួរ នួន ជា នេះគឺដោយសារវាជាផ្នែកមួយនៃការពិភាក្សា ការវិភាគរបស់ ប៉ុល ពត ទាក់ទងទៅនឹងសង្គមកម្ពុជានៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០។ នេះគឺជាបញ្ហាដែលពាក់ព័ន្ធទៅនឹងដំណាក់កាលនៃដំណើរការនីតិវិធីលើកទីមួយនេះ។ ហើយបានជាត្រូវការពិភាក្សាគ្នានេះ ហើយការពិភាក្សារបស់គាត់នៅពេលនោះ គឺថាវាមានរយៈពេលវែងមែនទែន វាទាក់ទងទៅនឹងការបោសសម្អាតខ្មាំងនេះ។ ហើយខ្ញុំទាក់ទងទៅនឹងសេចក្តីថ្លែងនេះគឺជាសេចក្តីថ្លែងដ៏ល្អបំផុតដែលត្រូវបានគេចាក់ផ្សាយវិទ្យុ ហើយការបដិសេធចំពោះយថាភាពនៃសុន្ទរកថានេះ គឺជារឿងមួយស្រួលណាស់ដែលគេអាចធ្វើនៅក្នុងតុលាការនេះ។ ហេតុផលដែលខ្ញុំសាកសួរនេះ គឺថាសុន្ទរកថា ប៉ុល ពត បង្ហាញច្បាស់ហើយថា វាជាផ្នែកមួយនៃការវិភាគ ហើយនិងគឺជាអ្វីដែលជនជាប់ចោទកំពុងនិយាយ ថាតើផ្នែកណាមួយនៃសង្គមកម្ពុជាដែលគេបានយោងថាវាពាក់ព័ន្ធទៅនឹងសាសនានោះ។ ហេតុដូច្នេះឯង បានជាខ្ញុំសាកសួរជនជាប់ចោទពាក់ព័ន្ធនឹងបញ្ហានេះ លោកប្រធាន។

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំសូមអន្តរាគមន៍តែមួយនាទី អ្វីដែលខ្ញុំបានស្តាប់ឮនេះគឺ មេធាវីការពារក្តីត្រូវតែមានការឆ្លើយតបអ៊ីចឹង។ ត្រូវតែបង្ហាញភស្តុតាង ការសួរសំណួរ និងបង្ហាញនូវភស្តុតាងមកដល់ជនជាប់ចោទ គឺយើងត្រូវបង្ហាញឡើងនៅក្នុងពេលធ្វើសេចក្តីថ្លែងបិទ។ ហើយការធ្វើ-- ការដែលគ្រាន់តែយកភស្តុតាងមកលាបពណ៌ឲ្យប្រឡាក់បែបនេះ ដែលវាមិនពាក់ព័ន្ធនេះ គឺថាជួនកាលគាត់មិនអាចនឹងឆ្លើយបានទេ។ ប៉ុន្តែមធ្យោបាយដែលធ្វើឲ្យល្អបំផុតនោះ គឺត្រូវធ្វើទៅតាមដំណាក់កាលនីមួយៗ ដោយបង្ហាញភស្តុតាងក្នុងទសវត្សរ៍ទី៦០ ហ្នឹងមក ហើយសួរសំណួរទាំងឡាយណាដែលទាក់ទងទៅនឹងផ្លូវដែលឈានទៅដល់ដែលគាត់អាចនឹងបង្ហាញនូវការពិត បង្ហាញនូវចម្លើយនេះ។

[១៥:៣៦:៤៧]

ហើយការឡើងមកក្រោកឈរ ហើយលើកយករបៀបជាសេចក្តីថ្លែងបិទសវនាការបែបនេះគឺថា ខ្ញុំសូមឲ្យលោកប្រធានដាក់ចូលនូវគោលការណ៍ណាមួយ ដើម្បីឲ្យយើងខ្ញុំទាំងអស់គ្នាអនុវត្តទាំងអស់គ្នាឲ្យល្អដូចគ្នា។

**ប្រធានអង្គជំនុំ៖**

យើងបានសម្រេចរួចហើយអម្បាញ់មិញ។ អ៊ីចឹង សហព្រះរាជអាជ្ញាមានសំណួរដែរទេ? បើអត់សំណួរ យើងនឹងតទៅនីតិវិធីផ្សេងទៀត ពីព្រោះយើងបានសម្រេចហើយ គឺជំទាស់មានប្រសិទ្ធភាព។ អ៊ីចឹង សំណួរពាក់ព័ន្ធនឹងបញ្ហាសាសនានេះ ដែលមិនសម្តែងចេញនៅក្នុងវិធានទាំងឡាយដែលជាកន្សោមសម្រាប់យកមកធ្វើការសវនាការនៅក្នុងវគ្គទីមួយនេះទេ ដែលមានប្រវត្តិបក្សកុម្មុយនីស្តកម្ពុជាដែលមាននៅក្នុងកថាខណ្ឌពី១៨ ដល់៣២។ ហើយបើសិនជាអត់មានសំណួរទេ យើងនឹងបន្តទៅនីតិវិធីផ្សេងទៀត។ សូមលោកបង្ហាញជំហរឲ្យបានច្បាស់លាស់ តើមានសំណួរទៀត ឬក៏អត់?

[១៥:៣៧:៤១]

**សួរដោយលោក ឌេល លីសាក់៖**

លោកប្រធាន ពិតណាស់ខ្ញុំមានសំណួរផ្សេងៗទៀត ខ្ញុំគ្រាន់តែចង់បង្ហាញនូវជំហររបស់ខ្ញុំសម្រាប់ជាការកត់ត្រានៅក្នុងប្រតិចារឹក នេះផង។ សូមអរគុណ។

**ស៖** លោក នួន ជា តើលោកនៅចាំបានទេ នូវសុន្ទរកថាដែល ប៉ុល ពត បានធ្វើឡើងនៅក្នុងខែកញ្ញា ឆ្នាំ១៩៧៧ ដែលគាត់ប្រកាសអំពីអត្ថិភាពនៃកម្ពុជាប្រជាធិបតេយ្យ តើលោកមានវត្តមាននៅពេល

ដែល ប៉ុល ពត ធ្វើសុន្ទរកថានោះទេ?

**លោក នួន ជា៖**

**ឆ៖** សូមជម្រាបលោកប្រធាន វាយូរឆ្នាំហើយ ខ្ញុំមិនចាំទេ។ លោកមានឯកសារយកមកមើល់។ ឯកសារមកបង្ហាញខ្ញុំមើល់ ឯកសារដែលសុន្ទរកថារបស់ ប៉ុល ពត។ តើលោកមានទេ? បើមានយកមក។

**ស៖** ដើម្បីជាការចុះប្រតិចារឹកឲ្យបានត្រឹមត្រូវ គឺនិយាយសុន្ទរកថារបស់ ប៉ុល ពត ដែលប្រកាសអំពីអត្ថិភាពនៃបក្សកុម្មុយនីស្តកម្ពុជា។ ដោយសារតែជនជាប់ចោទបដិសេធ ខ្ញុំសូមបង្ហាញឯកសាររឿងនេះ ជូនរឿងជនជាប់ចោទ។

[១៥:៣៩:២៣]

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញា បញ្ជាក់អំពីអត្តសញ្ញាណឯកសារផង លេខឯកសារ។

**សួរដោយលោក ឌេល លីសាក់៖**

លោកប្រធាន គឺឯកសារ D243/2.1.12។ ហើយខ្ញុំគ្រាន់តែសុំឲ្យលោក នួន ជា ពិនិត្យមើលទៅលើទំព័រ-- ប្រហែលជាទំព័រទីបី នៅក្នុងអត្ថបទជាភាសាខ្មែរ ថាតើនេះជាការរៀបរាប់នៃសុន្ទរកថាដូចទៅខាងក្រោមនេះដែរឬទេ? សូមដកស្រង់សម្តី៖ “វត្តមានរបស់បក្ស ទាក់ទងទៅនឹងខួបលើកទី១៧នៃការបង្កើតកុម្មុយនីស្តកម្ពុជា ហើយនៅក្នុងឱកាសនៃការប្រកាសឲ្យគេទទួលស្គាល់ទាំងនៅក្នុងស្រុកនិងនៅលើឆាកអន្តរជាតិ”។ សំណួររបស់ខ្ញុំ សួរថាតើលោកនៅចាំបានថា ប៉ុល ពត បានធ្វើសុន្ទរកថានេះទេ? គឺតែប៉ុន្មានថ្ងៃនៅមុនថ្ងៃទី៣០ ខែកញ្ញា នេះ ហើយលោក អៀង សារី បានធ្វើដំណើរតាមយន្តហោះទៅប៉េកាំង ដើម្បីធ្វើទស្សនកិច្ចផ្លូវការក្នុងនាមជាមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា តើលោកនៅចាំព្រឹត្តិការណ៍នេះបានទេ?

[១៥:៤០:៥៦]

**ឆ៖** នេះក៏ជាទង់បដិវត្តន៍ដែរ។ ដូច្នោះខ្ញុំបានបដិសេធហើយថា មិនមែនក្នុងទង់បដិវត្តន៍ មិនមានខ្លឹមសារអីដែលនិយាយអំពីរឿងសាសនាអីទេ។ នេះលោកយកទង់បដិវត្តន៍នេះមកឲ្យខ្ញុំទៀត ខ្ញុំបានបដិសេធម្តងទៅហើយ។

**ស៖** ដោយសារតែលោកជាអ្នកស្នើសុំឯកសារនេះ លោក នួន ជា លោកចាំទេសុន្ទរកថាដែល ប៉ុល ពត បានថ្លែងនៅក្នុងខែកញ្ញា ឆ្នាំ១៩៧៧ ដែលគាត់ប្រកាសជូនអំពីអត្ថិភាពរបស់បក្សកុម្មុយនីស្ត កម្ពុជាឲ្យពិភពលោកបានដឹងឮ?

**ឆ៖** ខ្ញុំមិនបានចាំទេ។ សូមគោរពលោកប្រធាន ព្រោះវាយូរឆ្នាំណាស់មកហើយ។

**ស៖** លោក នួន ជា ប្រសិនជាលោកមិនចាំទេ។ ថាតើម៉េចបានជាលោកជឿថាឯកសារនេះមិន មែនជាឯកសារថតចម្លងចេញពីសុន្ទរកថានៃច្បាប់ដើម?

**ឆ៖** ខ្ញុំមិនយល់ពីសំណួរលោកទេ។

**ប្រធានអង្គជំនុំ៖**

ឥឡូវផ្អាកការសួរសិនទៅលោកសហព្រះរាជអាជ្ញា បង្គាប់ឲ្យមន្ត្រីតុលាការបង្ហាញនូវឯកសារ ទស្សនាវដ្ដីទង់បដិវត្តន៍ឆ្នាំ១៩៧៧ នៅលើអេក្រង់ទូរទស្សន៍ មួយទំព័រម្ដង តាំងពីដើមរហូតដល់ចប់ ហើយនិងចុងក្រោយគឺត្រង់ចំណុចដែលពាក់ព័ន្ធនឹងសហព្រះរាជអាជ្ញាចង់សួរ ដើម្បីឲ្យលោក នួន ជា បានពិនិត្យ។

[១៥:៤៣:៥៩]

មិនទាន់ឃើញទេ។ មិនទាន់បានបញ្ចាំងទេ ឥឡូវហ្នឹងយើងបញ្ចាំងឲ្យលោកមើល ឲ្យមន្ត្រីច្បាប់ មន្ត្រីរបស់តុលាការបញ្ចាំងលើកញ្ចក់ទូរទស្សន៍ ទាំងមេធាវីរបស់លោកផង ដើម្បីឲ្យលោកមើលឯកសារ នេះ។ មួយទំព័រម្ដងតាំងពីដើមរហូតដល់ចប់។ ដើម្បីយើងមាននីតិវិធីការ ថាតើដោះស្រាយបញ្ហានេះ យ៉ាងដូចម្ដេច?

ហើយឲ្យមានការយឺតៗបន្តិច ដើម្បីឲ្យមានការពិនិត្យត្រឹមត្រូវ ហើយមើល ដូចជាឯកសារហ្នឹង ម៉េចក៏នៅចំហៀង មួយចំហៀងទៀតនៅទំព័រមួយទៀត ម៉េចក៏នៅចំហៀងម្ល៉េះ?

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

លោកប្រធានប្រសិនណាជា អ្វីដែល ខ្ញុំសូមថាឲ្យលោក នួន ជាទៅ លើទំព័រនីមួយៗ មួយទំព័រ ម្ដងៗ ដើម្បីឲ្យគាត់បានយល់។

**ប្រធានអង្គជំនុំ៖**

អញ្ជើញដាក់បញ្ចាំងស្លាយម្ដងទៀត ដាក់ឲ្យយឺតៗនៅពេលនេះរហូតដល់ចប់ម៉ោងហ្នឹង គឺគ្រាន់ តែពិនិត្យបញ្ហាប៉ុណ្ណឹងក៏បានដែរ។ ពិនិត្យបញ្ហាហ្នឹងឲ្យរួច ទោះបីដោះស្រាយមិនបានអង្គជំនុំជម្រះ បាន

ឬក៏មិនបាន អង្គជំនុំជម្រះនឹងមានការគិតគូរពិចារណា និងមានវិធានការលើកបញ្ហានេះទៅដោះស្រាយនៅពេលក្រោយ។ ដោយសារអំឡុងពេលបន្តិចទៀតនេះ គឺចាប់ពីសប្តាហ៍ក្រោយទៅអង្គជំនុំជម្រះនឹងសម្រាក មិនធ្វើសវនាការទេ។ អ៊ីចឹងអង្គជំនុំជម្រះនឹងមានវិធានការដើម្បីយកទៅត្រិះរិះពិចារណាជាមួយនឹងផ្ទៀងផ្ទាត់ជាមួយនឹងឯកសារដែលពាក់ព័ន្ធ ដូចជាវិធានផ្ទៃក្នុងដែលបានវិសោធនកម្ម ដូចជាឯកសារពីមុន ដូចជា ខាងមេធាវីការពារ ខៀវ សំផន បានលើកឡើង ដើម្បីផ្ទូវផ្ទងមើល ថាតើយើងដោះស្រាយបញ្ហាហ្នឹងយ៉ាងដូចម្តេច? ឬក៏មួយចាំបាច់យើងលើកបញ្ហានេះប្រជុំពិភាក្សានៅក្នុងចំណោមភាគីពាក់ព័ន្ធដើម្បីរកដំណោះស្រាយដែលជាដំណោះស្រាយមួយឲ្យបានត្រឹមត្រូវ ហើយនិងជាក់លាក់បំផុត ចៀសវាងបញ្ហានេះកើតឡើងម្តងហើយម្តងទៀត។

[១៥:៤៧:១០]

សូមអញ្ជើញសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណប្រធាន។ ខ្ញុំសូមៗស្នើជាជាងការបង្ហាញឯកសារ ដោយសារកំពុងពេលបង្ហាញឯកសារនេះ អ៊ីចឹងខ្ញុំសូមស្នើ ហើយយើងនឹងដោះស្រាយបញ្ហានេះនៅក្នុងអំឡុងពេលក្រោយនេះ ដើម្បីកុំឲ្យវាមានការរអាក់រអួល។ ថាតើបើធ្វើបែបនេះបានទេលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

យើងបានប្រាប់ហើយអំមិញ ហើយប្រាប់តាំងពីដើមទីមក តាំងពីភាគីដែលពាក់ព័ន្ធនឹងលើកឡើងនូវបញ្ហានេះ។ ប៉ុន្តែឥឡូវយើងចង់ច្បាស់លាស់ ពីព្រោះសូម្បីតែសហព្រះរាជអាជ្ញាក៏មិនស្តាប់យើងបានដែរ។ យើងបានប្រាប់ថា នៅពេលដែលចូលមកវិញ ប្រសិនបើសំណួរ ដែលលោកមានប៉ុនប៉ងសួរដល់ជនជាប់ចោទដែលមិនពាក់ព័ន្ធទៅនឹងទស្សនាវដ្តីទង់បដិវត្តន៍ សួរ អនុញ្ញាតឲ្យសួរបន្តឲ្យចប់ទៅដើម្បីយើងធ្វើនីតិវិធីនៃការបង្ហាញឯកសារនេះដល់ជនជាប់ចោទ ដើម្បីឲ្យគាត់ធ្វើអត្ថាធិប្បាយមើលថាតើគាត់ទទួល ឬក៏មិនទទួល?

[១៥:៤៨:២៧]

ដើម្បីយើងយកអាបញ្ហានេះទៅគិតពិចារណា រកមធ្យោបាយដោះស្រាយសម្រាប់ទូទៅលើការឯកសារទាំងអស់នេះទៅថ្ងៃក្រោយ។ ប៉ុន្តែលោកមិនស្តាប់យល់ពីបញ្ហាហ្នឹងទេ លោកទៅសួរសំណួរផ្សេងទៀត ដែលពាក់ព័ន្ធនឹងរឿងទស្សនាវដ្តីដដែល។ អ៊ីចឹងហើយបានជាបង្កើតនូវបញ្ហានេះ។

ឥឡូវនេះអង្គជំនុំជម្រះត្រូវការស្តាប់ ត្រូវការបង្ហាញឯកសារនេះដល់ជនជាប់ចោទ នួន ជា ដើម្បីឱ្យគាត់ពិនិត្យមើលមួយទំព័រម្តងៗ ទល់ចប់។ យើងនឹងឱ្យគាត់ធ្វើអត្ថាធិប្បាយលើការដែលគាត់ពិនិត្យលើឯកសារនេះ។ ថាតើគាត់មានយោបល់ថាម៉េច? រួចហើយយើងបញ្ចប់សវនាការថ្ងៃនេះ ដើម្បីយើងយកអាបញ្ហាទៅគិត ពិចារណា ថាតើរកដោះស្រាយយ៉ាងដូចម្តេច?

សូមអញ្ជើញមន្ត្រីរដ្ឋបាលតុលាការដាក់បញ្ចាំងឯកសារ ហើយបើអាចធ្វើបានអាចជូនលោក នួន ជា ដើម្បីលោកអាននូវឯកសារនេះ។

សូមអញ្ជើញលោក នួន ជា!

[១៥:៤៩:៣៥]

**លោក នួន ជា៖**

ថាខ្ញុំមិនទទួលស្គាល់នូវឯកសារទង់បដិវត្តន៍នេះទេ។ ដូច្នោះ យកឯកសារនេះមកបញ្ចាំងឱ្យខ្ញុំមើលទៀត ខ្ញុំក៏មិនទទួលទៀត ពីព្រោះទទួលយ៉ាងម៉េច? បើខ្ញុំមិនដឹង។

**ប្រធានអង្គជំនុំ៖**

អរគុណច្រើនដែលលោកប្រកាន់នូវជំហរច្បាស់លាស់ដូចនេះ។ ប៉ុន្តែ អម្បាញ់មិញនេះគឺលោកបានបង្ហាញនូវជំហររបស់លោកពីខាងដើម គឺឯកសារជាក្រដាសដោយសារសហព្រះរាជអាជ្ញាបញ្ជូនឯកសារជាក្រដាសទៅឱ្យលោក លោកថាឯកសារជាក្រដាសហ្នឹងជាហ្វូតូកូពីមិនដឹងយកមកពីណាទេ។ អ៊ីចឹងហើយបានជាអង្គជំនុំជម្រះដូរនូវវិធីសាស្ត្រមួយ គឺយកឯកសារដែលដាក់នៅក្នុងប្រព័ន្ធ*ហ្សាយឡេប* តាមប្រព័ន្ធព័ត៌មានវិទ្យា ដែលបានអនុវត្តគ្រប់គ្រងបែបនេះនៅក្នុងតុលាការនេះ តាំងពីដើមទីរហូតមកដល់ពេលនេះ។ ហើយវាមិនដែលមានបញ្ហាណាមួយទៅលើបញ្ហា ការប្រើប្រាស់ការដាក់ឯកសារសំណុំរឿងចូលទៅក្នុងប្រព័ន្ធហ្សាយឡេប ប្រព័ន្ធព័ត៌មានវិទ្យាទេ ទើបតែពេលនេះទើបវាកើតមាន។ អ៊ីចឹងហើយបានជាយើងផ្លាស់ប្តូរនូវរបៀបនៅក្នុងការបង្ហាញឯកសារ ដែលលោកមិនជឿជាក់ ដោយសារឯកសារនេះផ្តល់ដោយសហព្រះរាជអាជ្ញា ទើបយើងបញ្ជាក់បញ្ហានេះថាឯកសារនេះ គឺយកចេញពីកម្មវិធីគ្រប់គ្រងសំណុំរឿង០០២ នៅក្នុងប្រព័ន្ធហ្សាយឡេប ប្រព័ន្ធព័ត៌មានវិទ្យាដែលយើងប្រើប្រាស់ និងអនុវត្តនៅទីនេះតាំងពីដើមរហូតមក ទាំងសំណុំរឿង០១, ០២។

[១៥:៥១:៣៣]

ដើម្បីឱ្យវាមានការច្បាស់លាស់ ក្រែងលោលោក មិនបារម្ភលើបញ្ហាឯកសារនេះទៀត ដូច

ឯកសារដែលថតចម្លងជាក្រដាស។ តែប្រសិនបើលោកនៅតែជំទាស់បញ្ហានោះ នោះគឺជារឿងមួយទៀតដោយសារ-- អរគុណណាស់ដែលលោកបានបង្ហាញជំហរច្បាស់លាស់ នៅក្នុងការជំទាស់នូវឯកសារនេះ។

ហើយឥឡូវនេះដល់ពេលម៉ោងសមល្មមនឹងសម្រាកហើយសម្រាប់ថ្ងៃនេះ។ ដូច្នេះ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។

សូមអញ្ជើញ! សូមអញ្ជើញមេធាវី!

**លោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

សូមអរគុណលោកប្រធាន។ ចំណុចចុងក្រោយទេមុននឹងសម្រាក។ អ្វីដែលកើតនៅពីព្រឹកមិញនេះទាក់ទងទៅនឹងការសួរទៅនឹងលោក ឡុង នរិន្ទ ខ្ញុំបានកត់សម្គាល់ឃើញ ខ្ញុំចង់បញ្ជាក់ឲ្យច្បាស់ថា យើងខ្ញុំសូមជំទាស់ទៅនឹងសេចក្ដីសម្រេចទៅលើការសួររបស់ ផេសមិន ដែលអង្គជំនុំជម្រះបានបដិសេធទាក់ទងទៅនឹងលោក គាត ឈន់ ហើយថាមិនពាក់ព័ន្ធ។ ប៉ុន្តែអ្វីដែលយើងសាកសួរនេះ គឺថាសុទ្ធតែពាក់ព័ន្ធទៅនឹងដំណើរការនីតិវិធីទាំងអស់។ នេះគឺជាជំហររបស់ខាងមេធាវីការពារក្ដីយើងខ្ញុំ។ ហើយយើងខ្ញុំក៏សូមអរគុណដល់សហការីទាំងអស់ សហភាគាទាំងអស់ ដែលបានគាំទ្រដល់យើងខ្ញុំនៅក្នុងសវនាការនាថ្ងៃនេះ។ សូមអរគុណច្រើន។

[១៥:៥៣:១២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម! សូមអញ្ជើញ!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

គឺថា ការជំទាស់របស់លោកគឺត្រូវបានកត់ត្រា ហើយឲ្យបានសមស្របនេះគឺជាបញ្ហាមួយដែលយើងត្រូវដោះស្រាយឲ្យបានសមស្រប។ អរគុណណាស់ លោក អេនឌ្រូ។

**ប្រធានអង្គជំនុំ៖**

សាជាថ្មីម្ដងទៀត អង្គជំនុំជម្រះប្រកាសថា សវនាការសម្រាប់ថ្ងៃនេះគឺ ត្រូវផ្អាកត្រឹមប៉ុណ្ណេះ ហើយសវនាការនឹងលើកទៅបន្តធ្វើនៅថ្ងៃទី១០ ថ្ងៃអង្គារ ទី១០ ខែមករា ឆ្នាំ២០១២។ ហេតុដូច្នេះ សូមភាគីសាធារណជន ហើយនិងការិយាល័យរដ្ឋបាល និងអង្គភាពពាក់ព័ន្ធក្នុងកិច្ចខិតខំក្នុងការគាំទ្រដល់កិច្ចដំណើរការសវនាការ រៀបចំសវនាការរបស់អង្គជំនុំជម្រះសាលាដំបូង គឺសូមជ្រាប។

ហើយអនុរក្សមន្ទីរឃុំឃាំងឲ្យនាំខ្លួនជនជាប់ចោទទាំងបីរូប ទៅកាន់មន្ទីរឃុំឃាំងវិញ ហើយនិងឲ្យនាំគាត់មកកាន់បន្ទប់សវនាការនេះនៅព្រឹកថ្ងៃទី១០ ខែមករា ឆ្នាំ២០១២ ឲ្យបានមុនម៉ោងប្រាំបួនជាកំណត់។ សូមសម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៥:៥៥ នាទី)*